00776631

E1/38.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Feb-2012, 09:20
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី២៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោកស្រី សារ៉ាស អេនឌ្រូ

*(Ms.Sarah ANDREWS)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

(*Mr. Michiel PESTMAN*)

លោក ហ្សាស្ពើ ប៉ៅ(*Mr Jasper PAUW*)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វ៉ែកគែន

(*Arthur VERCKEN*)

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្ដម

លោក ម៉ៃខល កាណាវ៉ាស

(*Mr.Michael KARNAVAS*)

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

(*Ms. Elisabeth SIMONNEAU-FORT*)

លោក ឡៃ ជុនធី

លោក វ៉ែន ពៅ

លោក ហុង គឹមសួន

លោក សំ សុគង់

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ហ្សាស្ពើ ប៉ៅ | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ឆាំង យុ | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅលោក ឆាំង យុ

សួរដោយលោក អាកឡូវ វែកគែន ផ្តើមពី ....................................................................ទំព័រ ០៤
សួរដោយលោក គង់ សំអុន ផ្តើមពី .........................................................................ទំព័រ ២៨
សួរដោយលោក ហ្សាស្តើ ប៉ោ ផ្តើមពី .......................................................................ទំព័រ ៥២
សួរដោយលោកស្រីចៅក្រម ស៊ីលវៀ ខាត់វ៉ាយថ៍ ផ្តើមពី.................................................ទំព័រ ៦៥
សួរដោយលោក ហ្សាស្តើ ប៉ោ ផ្តើមពី .......................................................................ទំព័រ ៦៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតាមកាលវិភាគ នៃកិច្ចដំណើរការសវនាការក្នុងការស្តាប់សក្ខីកម្មប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ដល់ថ្ងៃនេះគឺវេទិកាត្រូវបានទៅលើខាងក្រុមមេធាវីការពារក្តីទាំងបីក្រុម ប៉ុន្តែដោយសាររយៈពេលដែលបែងចែកឲ្យគឺ ទាំងបីក្រុមទទួលការបែងចែកពេលវេលាពីរថ្ងៃ។ ដូច្នេះមុននឹងផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះសូមសួរទៅមេធាវី-- ក្រុមមេធាវីទាំងបីក្រុមមុន ថាតើការបែងចែកពេលវេលាពីរថ្ងៃដែលបែងចែកឲ្យទាំងបីក្រុមនេះយ៉ាងម៉េចដែរ?

មេធាវី-- ក្រុមមេធាវីការពារក្តី នួន ជា!

[០៩:០២:៣៣]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ជាការពិតគឺយើងបានចរចាជាមួយនឹងក្រុមការពារផ្សេងទៀត។ យើងគិតទុកថា យើងត្រូវការមួយថ្ងៃសម្រាប់យើងដេញដោលទៅលើសាក្សីរូបនេះ។ តាមអ្វីដែលខ្ញុំយល់ គឺភាគីមេធាវីការពារក្តីដទៃទៀតនោះ ពីរក្រុមហ្នឹងប្រហែលជាគាត់ត្រូវការមួយថ្ងៃ ដោយសារតែគាត់ត្រូវការចរចាគ្នា។ យើងដឹងហើយថា លោក ខៀវ សំផន គាត់មិនមានវត្តមាននៅថ្ងៃចន្ទនោះទេ ដូច្នេះហើយខាងមេធាវី ខៀវ សំផន នោះ គឺគាត់សូមអនុញ្ញាតសួរសំណួរនៅក្នុងថ្ងៃនេះ ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាតនោះ យើងខ្ញុំអាចធ្វើសម្បទានម៉ោងរបស់ខ្ញុំមួយម៉ោងទុកឲ្យគាត់សួរសិនទៅ បន្ទាប់មកខ្ញុំនឹងយកម៉ោងរបស់គាត់មួយម៉ោងនៅថ្ងៃចន្ទវិញ ដែលពាក់ព័ន្ធទៅនឹងការតាំងសំណួរទៅលើសាក្សីរូបនេះ។ ដូច្នេះហើយចំពោះក្រុមយើងខ្ញុំ គឺខ្ញុំត្រូវការមួយថ្ងៃពេញ ហើយនៅក្នុងថ្ងៃនេះប្រសិនបើអង្គជំនុំជម្រះអនុញ្ញាតនោះ គឺខ្ញុំសូមសម្បទានពេលវេលារបស់ខ្ញុំមួយចំនួនឲ្យទៅខាងមេធាវី ខៀវ សំផន នៅក្នុងថ្ងៃនេះ ហើយថ្ងៃចន្ទ ខ្ញុំនឹងប្រើពេលវេលារបស់គាត់វិញ។ សូមអរគុណ។

[០៩:០៣:៥៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញក្រុមមេធាវីការពារក្តី ខៀវ សំផន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមបញ្ជាក់អំពីការបកប្រែជាភាសាខ្មែរបន្តិចអំមិញថា លោក ខៀវ សំផន នឹងមិនមានវត្តមាននៅថ្ងៃចន្ទ។ ការពិតមិនមែនអ៊ីចឹងទេ គឺសហមេធាវីអន្តរជាតិគាត់មិនមានវត្តមាននៅថ្ងៃចន្ទ ដូច្នេះគាត់សូមសួរ តាំងសំណួរនៅថ្ងៃនេះពេលរសៀល។ បាទសូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:០៥:១២]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅក្រុមការពារក្តីលោក អៀង សារី ការលើកឡើងរបស់ក្រុមមេធាវីការពារក្តី នួន ជា អម្បាញ់មិញនេះលោកយល់យ៉ាងម៉េចដែរ?

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីនៅក្នុងនេះ និងនៅក្រៅបន្ទប់សវនាការ។

យើងមិនជំទាស់ទៅនឹងការលើកឡើងរបស់លោកមេធាវី នួន ជា ដែលអនុញ្ញាតឲ្យខាងមេធាវីលោក ខៀវ សំផន ចំណាយពេលមួយម៉ោងនៅក្នុងថ្ងៃនេះ ហើយគាត់នឹងយកមួយម៉ោងនៅថ្ងៃចន្ទវិញ។ ចំពោះខាងក្រុមមេធាវីការពារក្តីខាងយើងខ្ញុំវិញ យើងប្រហែលជាត្រូវការមួយម៉ោងកន្លះទៅពីរម៉ោង ក៏ប៉ុន្តែតាមមើលទៅប្រហែលជាអាចតិចជាងហ្នឹងទៅទៀត។

ដូច្នេះហើយបើសិនជាតិចជាងនោះ ប្រហែលជាអាចពីសែសិបប្រាំនាទីទៅមួយម៉ោង វាអាស្រ័យទៅនឹងការតាំងសំណួរនៅក្នុងថ្ងៃនេះ វាពិបាកក្នុងការទាយស្មានផងដែរ ដោយសារតែពេលខ្លះខ្ញុំដឹងថាមេធាវីការពារក្តីដទៃទៀតនោះគឺគាត់មិនបានក្តោបទៅលើមូលដ្ឋានជាក់លាក់ ដូច្នេះហើយគឺខ្ញុំមិនចង់ចំណាយពេលវេលាពន្យារនីតិវិធីនោះទេ។ ដូច្នេះ ប្រសិនបើនៅពេលដែលខ្ញុំសួរនោះប្រហែលជាត្រឹមតែសែសិបប្រាំនាទី ទៅមួយម៉ោងតែប៉ុណ្ណោះ។ សូមអរគុណលោកប្រធាន។

[០៩:០៦:៣១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ចុះក្រុមមេធាវីការពារក្ដី ខៀវ សំផន?

**លោក គង់ សំអុន៖**

បាទ ដោយខាងសហមេធាវីអន្តរជាតិ គាត់នឹងសុំពេលតាំងសំណួរនៅរសៀលនេះ រយៈពេលមួយម៉ោង ហើយខ្ញុំអាចប្រើប្រាស់នៅថ្ងៃចន្ទ នៅពេលវេលាដែលសល់ ហើយប្រហែលជាអាចខ្វង់មួយម៉ោង ឬក៏លើសពីនេះបន្តិចបន្តួច។ បាទ សូមអរគុណ។

[០៩:០៧:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាទៅក្រុមមេធាវីការពារក្ដី នួន ជា ដើម្បីមានឱកាសនៅក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

ឈប់ៗ!

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:០៩:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដោយសារមានបញ្ហានៃសំណើសុំរបស់មេធាវី ក្រុមមេធាវីការពារក្ដី ខៀវ សំផន ដែលមានបញ្ហាថានឹងមានអវត្តមាននៅ-- ចំពោះមេធាវីអន្តរជាតិការពារក្ដី ខៀវ សំផន នៅថ្ងៃចន្ទ ថ្ងៃទី០៦ សប្ដាហ៍ក្រោយ ដែលទំនងមិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅក្នុងថ្ងៃនោះបាន ហើយការដែលសុំឆ្លាស់គ្នា គឺវានឹងបង្កនូវបញ្ហាលំបាកគ្រប់គ្រងនៅក្នុងកិច្ចដំណើរការសវនាការ។ ដូច្នេះ ដើម្បីសម្រួលដល់សំណើសុំនេះ អង្គជំនុំជម្រះសម្រេចប្ដូរលំដាប់នៃការសួរដេញដោលចំពោះសាក្សីរូបនេះ ដោយផ្ដល់វេទិកាទៅឲ្យក្រុមមេធាវីការពារក្ដី ខៀវ សំផន តាំងសំណួរសួរទៅសាក្សីនេះមុនក្រុមមេធាវីផ្សេងទៀត។

សូមអញ្ជើញក្រុមមេធាវីការពារក្ដី ខៀវ សំផន!

សូមអញ្ជើញចៅក្រម ហ្សង់ម៉ាក! ចង់និយាយអី?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ ដោយបានទទួលដំណឹងថាមេធាវីរបស់ ខៀវ សំផន មិនទំនេរនៅ

សប្តាហ៍ក្រោយនោះ អ៊ីចឹងផ្តល់លទ្ធភាពដល់មេធាវី ខៀវ សំផន ចាប់ផ្តើមសួរចម្លើយសាក្សីលោក ឆាំង យុ។ ប៉ុន្តែអ្វីដែលថា អង្គជំនុំជម្រះមិនចង់បាននោះគឺថា មិនចង់ឲ្យមេធាវីការពារក្តីហ្នឹងផ្អាក ហើយបន្តឡើងវិញ។ អ៊ីចឹងគឺថា អង្គជំនុំជម្រះចង់ផ្តល់លទ្ធភាពឲ្យក្រុមមេធាវី ខៀវ សំផន ចាប់ផ្តើមឥឡូវ ហើយបន្ទាប់មកទៀតតាមលំដាប់លំដោយនៅពេលក្រោយ។

[០៩:១២:៣០]

**លោក អាកទូរ វែកគែន៖**

បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គុយចុះសិនលោកមេធាវីអន្តរជាតិការពារក្តី ខៀវ សំផន! ដោយមានការឈរមានបំណងចង់លើកឡើងបញ្ហារបស់មេធាវីការពារក្តី នួន ជា។

សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គប្រជុំ សូមគោរពលោកប្រធាន ខ្ញុំគាំទ្រនឹងយោបល់របស់លោក ហ្សង់ម៉ាក ជូនវេទិកាទៅខាងក្រុមលោក ខៀវ សំផន ហ្នឹងទាំងអស់តែម្តងទៅ ហើយបន្ទាប់មកសឹមខាងខ្ញុំ ខាងលោក នួន ជា ហ្នឹងបន្តបន្ទាប់។ សូមអរគុណ។

[០៩:១៣:០៦]

**ប្រធានអង្គជំនុំ៖**

អរគុណនូវការបញ្ជាក់បន្ថែមអំពីជំហរនេះ លើការសម្រេចរបស់អង្គជំនុំជម្រះ។ សូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក អាកទូរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា មានឯកសារដាក់ជូនដល់សាក្សី អ៊ីចឹងដោយសារមូលហេតុនេះហើយគឺថា ខ្ញុំចង់ចោទសំណួរទៅគាត់រសៀលនេះវិញ។ ក៏ប៉ុន្តែបើសិននេះជាបញ្ហារបស់អង្គជំនុំជម្រះ ខ្ញុំអាចចោទសំណួរទៅគាត់។

លោកសាក្សីជាទីគោរព ខ្ញុំឈ្មោះ អាកទូរ វែកគែន ជាមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ។

សំណួរដែលខ្ញុំចង់សួរទៅកាន់លោក និងនិយាយអំពីឯកសារដែលគិតថា នៅសម័យកម្ពុជាប្រជាធិប-តេយ្យ។ អ៊ីចឹងក្នុងចំណោមឯកសារដ៏ច្រើនដែលអង្គការរបស់លោកបានប្រមូលយកមករក្សាទុកនោះ។ អ៊ីចឹងសំណួរខ្ញុំនឹងពាក់ព័ន្ធតែឯកសារដែលធ្វើឡើងនៅសម័យកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ។ សំណួរទីមួយរបស់ខ្ញុំមានដូចតទៅនេះ៖

[០៩:១៤:៥៤]

**ស៖** តើតាមលោក ចំពោះលោកតើអ្វី តើអ្វីៗដែលប្រាកដជាងគេក្នុងការធ្វើការស្រាវជ្រាវ តើជាឯកសារច្បាប់ដើម ដែលសរសេរនៅសម័យនោះ ឬក៏ជាឯកសារចម្លងចំពោះលោក? តើឯកសារប្រភេទណា ដែលគួរឲ្យទុកចិត្តបានជាងគេនោះ?

**លោក អាប់ឌុលឡាក់ ថាវីក៖**

យើងខ្ញុំសូមជំទាស់ទៅនឹងសំណួរបែបនេះ ដោយសារតែវាមិនមែនជាសំណួរពាក់ព័ន្ធទៅនឹងគុណវុឌ្ឍិរបស់សាក្សីនោះទេ។ ចំពោះការស៊ើបអង្កេតសួរបញ្ហាស៊ើបអង្កេតនេះ វាជាបញ្ហាដែលអង្គជំនុំជម្រះជាអ្នកសួរ និងជាអ្នកសម្រេចដោយអង្គជំនុំជម្រះ។ សូមអរគុណ។

**លោក អាកទូរ វែកគែន៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ កាលពីម្សិលមិញ នៅពេលដែលគេស្តាប់ចម្លើយគាត់ ដែលដើមបណ្តឹងរដ្ឋប្បវេណីស្តាប់ចម្លើយគាត់ សាក្សីបានបង្ហាញថាគាត់ចាត់ទុកថា អង្គការរបស់គាត់អាចធ្វើការស៊ើបអង្កេត ទោះបីជាមិនមែនជាការស៊ើបអង្កេតផ្លូវច្បាប់ក៏ដោយ។ ដូច្នេះយើង តែការពិតយើងដឹងថា ស៊ី.ឌី.ខេម នោះធ្វើការស៊ើបអង្កេត។ អាស្រ័យហេតុដូច្នេះហើយ បានជាសំណួរខ្ញុំចង់បញ្ជាក់ថា ខ្ញុំសួរថាតើទោះបីជាការស៊ើបអង្កេតតុលាការ ឬក៏មិនតុលាការនោះ អ៊ីចឹងតើដែនកំណត់នៃការការងារស៊ើបអង្កេតរបស់ ស៊ី.ឌី.ខេម នោះវាយ៉ាងម៉េច?

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៧:៥៤]

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់សហព្រះរាជអាជ្ញាមានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយតបនឹងសំណួរដែលសួរដោយមេធាវីអម្បាញ់មិញនេះទេ។ មេធាវីអាចតាំងសំណួរផ្សេងទៀតបាន ប្រសិនបើមានសំណួរផ្សេង។

**លោក អាកទ្វរ វែកគែន៖**

គុលាការអាចប្រាប់មូលហេតុនៃការជំទាស់នេះបានដែរឬទេ? លោកសាក្សីដែលជាតំណាងអង្គការមួយ ដែលប្រមូលឯកសារទូទាំងពិភពលោក។ ខ្ញុំគិតថាជារឿងធម្មតាទេ ដែលក្នុងការសួរទៅប្រធានអង្គការនេះ ថាគាត់យល់ឃើញថាឯកសារចម្លងនោះ វាត្រូវតម្លៃជាភស្តុតាងជាងឯកសារច្បាប់ដើម ឬក៏យ៉ាងម៉េច? បើសិនជាឈប់ឲ្យខ្ញុំសួរសំណួរទៅសាក្សី ខ្ញុំឈប់ឥឡូវក៏បានដែរ។

[០៩:១៩:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ពន្យល់ដល់មេធាវីរូបនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ឥឡូវខ្ញុំសូមបំភ្លឺនៅក្រោមការត្រួតពិនិត្យរបស់សហការីរបស់ខ្ញុំ ព្រោះថាខ្ញុំមិនចង់ក្បត់ពីគំនិតរបស់អង្គជំនុំជម្រះទេ។ អ្វីដែលយើងចង់និយាយពីថ្ងៃនេះ គឺថាជាការពិភាក្សាផ្លូវច្បាប់។ ដូច្នេះអ្វីដែលយើងចាប់អារម្មណ៍នោះ គឺថាតម្លៃរបស់ឯកសាររបស់ ស៊ី.ឌី.ខេម នៅក្នុងក្របខ័ណ្ឌឯកសារតុលាការ។ ដូច្នេះការស្រាវជ្រាវរបស់ ស៊ី.ឌី.ខេម គួរឲ្យចាប់អារម្មណ៍នៅក្នុងក្រមខ័ណ្ឌការស្រាវជ្រាវរបស់ ស៊ី.ឌី.ខេម ជាការស្រាវជ្រាវបែបលក្ខណៈវិទ្យាសាស្ត្រ ប៉ុន្តែអ្វីដែលយើងចង់ដឹង គឺថាតម្លៃឯកសារទាំងអស់នេះនៅក្នុងការពិភាក្សាដេញដោលរបស់យើង។ អ៊ីចឹង ខ្ញុំគិតថា សំណួរដែលចោទសួរនោះ អម្បាញ់មិញនេះវាមិនអាចធ្វើឲ្យមានការដំណើរការទៅមុខបានល្អទេបាទ។

[០៩:២០:២១]

**សួរដោយលោក អាកទ្វរ វែកគែន៖**

លោកចៅក្រមខ្ញុំយល់ហើយ គឺថាការលំបាកនោះគឺថា ឯកសារដែលថា ភាគរយដ៏សម្បើមគឺថាចេញមកពីឯកសារ ឌី.ស៊ី.ខេម នោះ។ អ៊ីចឹងគឺថា ខ្ញុំគិតថា វាមានការពាក់ព័ន្ធគ្នា គឺថា អ៊ីចឹងការលំបាកវាស្ថិតនៅត្រង់នេះហើយ នៃការជំនះសេចក្តីយើងនេះ ព្រោះថា យើងមានអង្គការមួយ ខ្ញុំមិនប្រឆាំងអីនឹងអង្គការហ្នឹងទេ តែអង្គការហ្នឹងធ្វើការងាររបស់គាត់ ក៏ប៉ុន្តែខ្ញុំគិតថា គោលជំហររបស់ភាគីការពារក្តីនោះ គឺថាយើងចង់ឲ្យបញ្ចូលឯកសាររបស់មជ្ឈមណ្ឌល ឌី.ស៊ី.ខេម។ អ៊ីចឹងយើងប្រឆាំងនឹងគោលជំហរនេះ គឺថាមិនចង់ឲ្យបញ្ចូលឯកសារហ្នឹង ដោយគ្មានការផ្ទៀងផ្ទាត់នោះទេ។

**ស៖** ឥឡូវខ្ញុំសូមបន្តទៀត។ លោកសាក្សី តើឯកសារច្បាប់ដើមដែលចេញនៅសម័យខ្មែរក្រហមនោះ នៅឯណារបស់មជ្ឈមណ្ឌលរបស់លោកនោះ? ឥឡូវនេះឯកសារច្បាប់ដើមនៅឯណា?

**លោក ឆាំង យុ៖**

**ឆ៖** លោកមេធាវី បាទឯកសារនេះវាមានប្រាំប្រភេទ បើសិនជាលោកចាំកាលពីសប្តាហ៍មុន ហើយបើសិនជាលោកសួរទៅលើប្រភេទទីមួយ គឺឯកសារដើមនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបាទ។

[០៩:២២:០២]

**ស៖** លោកសាក្សី ខ្ញុំសូមបញ្ជាក់សំណួររបស់ខ្ញុំ។ ខ្ញុំសូមកាត់លោកបន្តិច ព្រោះថា ខ្ញុំមិនសូវមានពេលទេ។ ខ្ញុំមិនចង់-- ខ្ញុំចាប់ផ្តើមអម្បាញ់មិញនេះ ខ្ញុំបញ្ជាក់ថា ខ្ញុំនឹងនិយាយអំពីឯកសារដែលសន្មតថា កើតចេញធ្វើឡើងនៅសម័យកម្ពុជាប្រជាធិបតេយ្យ អ៊ីចឹងមិនបាច់និយាយពីប្រភេទឯកសារដែលថា ឌី.ស៊ី.ខេម មាននោះទេ។ អ៊ីចឹង អានេះមិនមែនជាកម្មវត្ថុរបស់ខ្ញុំទេ។ សំណួររបស់ខ្ញុំគឺថា ឯកសារច្បាប់ដើមនោះនៅឯណា? ដែលលោកយល់ឃើញថា ឯកសារទាំងអស់នោះធ្វើឡើងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ តើឯកសារទាំងអស់នោះនៅឯណា?

**ឆ៖** នៅកម្ពុជាបាទ។

**ស៖** នៅឯណា?

**ឆ៖** នៅកម្ពុជា។

[០៩:២៣:០៨]

**ស៖** នៅកន្លែងណា នៅប្រទេសខ្មែរហ្នឹង?

**លោក ឆាំង យុ៖**

លោកចៅក្រម តើខ្ញុំអាចប្រាប់ទីតាំងជាក់ស្តែង នៃឯកសារដើមបានដែរឬទេ ដោយសារថាបញ្ហាសន្តិសុខ ដែលយើងបានរក្សាអស់ជាង១៥ឆ្នាំមកហើយ។ អ៊ីចឹងបើសិនជាលោកចៅក្រមអនុញ្ញាត ខ្ញុំអាចជម្រាបជូនបាន។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៤:១៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន ខ្ញុំនិយាយដោយសង្ខេបទេ។ បញ្ហាចោទដែលធ្វើឡើងនេះ គឺវាទូលាយណាស់ សួរថាឯកសារដើមនៅឯណា? លោក ឆាំង យុ គាត់បានឡើងថា ឯកសារមានប្រហែលមួយលានឯកសារឯណោះ។ ដូច្នេះហើយការសួរនោះគឺសួរទូលាយពេក គួរតែសួរឲ្យជាក់លាក់ដើម្បីឲ្យសាក្សីអាចឆ្លើយបាន។ ចំណុចទីពីរ សក្ខីកម្មឆ្លើយពីម្សិលមិញ គឺនិយាយអំពីប្រភេទ នៃឯកសារដែលឯកសារដើមនោះគឺ បានរក្សាទុកនៅបណ្ណសារដ្ឋានជាតិជាដើម។ ដូច្នេះចម្លើយទាំងអស់នោះ បានផ្តល់ជូនរួចមកហើយ។ ក៏ប៉ុន្តែប្រសិនបើឲ្យសាក្សីឆ្លើយ នូវប្រភពឯកសារដើមទាំងអស់ ដែល ឌី.ស៊ី.ខេម រក្សាទុកនោះ គឺជាបញ្ហារសើប។ ដូច្នេះ យើងគួរតែធ្វើសវនាការជាអសាធារណៈទៅវិញ។ សូមអរគុណលោកប្រធាន។

[០៩:២៥:១២]

**ប្រធានអង្គជំនុំ៖**

បាទ ដោយសារ-- សូមអញ្ជើញមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

គឺខ្ញុំគាំទ្រទៅលើការស្នើឡើងដូច្នេះ គឺស្នើឲ្យមានការបើកសវនាការជាអសាធារណៈ ហើយដោយសារតែយើងនិយាយអំពីទីតាំងកន្លែងនៃឯកសារ។ ដូច្នេះហើយ វាសំខាន់ ហើយយើងប្រហែលជាអាចស្នើសុំឲ្យមានការផលិត និងបង្ហាញអំពីឯកសារដើម ដែលត្រូវពិភាក្សាគ្នាក្នុងតុលាការ។ ដូច្នេះហើយ ការដែលយើងបង្ហាញទៅលើចំណុចនេះ គឺវាអាចឲ្យយើងធ្វើទៅបាន ហើយអាចផលិតឯកសារទាំងអស់នោះបាន។ ដូច្នេះ ខ្ញុំសូមគាំទ្រនូវសំណើរបស់ខាងសហព្រះរាជអាជ្ញា យើងគួរតែធ្វើការបើកសវនាការជាអសាធារណៈ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

[០៩:២៦:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៨:០៣]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅសហព្រះរាជអាជ្ញា ពេលដែលភាគីដទៃទៀតលើក ហេតុអីបានជាលោកមិនលើក ហើយមកដល់ពេលចៅក្រមពិភាក្សារួចហើយ បានលោកមកចង់លើក ចង់លើកអីទៀត? មានបញ្ហាអីផ្សេងក្រៅពីបញ្ហាអំមិញទេ? បើបញ្ហាទាក់ទិននឹងបញ្ហាមិញ យើងមិនអនុញ្ញាតឲ្យធ្វើដូច្នេះទេ ហើយយើងមិនអនុញ្ញាតទេ។

សាក្សីចំពោះសំណួរអម្បាញ់មិញរបស់មេធាវី គឺសាក្សីមិនបាច់ឆ្លើយទេ ដោយសំខាន់នៅក្នុងការអនុវត្តគោលការណ៍នៃការរក្សាការសម្ងាត់សុវត្ថិភាពឯកសារ សំខាន់ថាតើវាពាក់ព័ន្ធនឹងបញ្ហាឯកសារដើម និងឯកសារដែលយកមកប្រើប្រាស់នៅទីនេះ។ ប្រសិនបើភាគីចង់ផ្ទៀងផ្ទាត់ជាមួយនឹងឯកសារដើម តើអាចធ្វើបានដែរឬទេ? នេះជាបញ្ហាសំខាន់ វាមិនមែនសំខាន់ថា ស្គាល់ទីកន្លែងរក្សាទុកដោយសុវត្ថិភាពនៃឯកសារនោះទេ។ ហើយបញ្ហាមួយទៀត គឺបញ្ហាដែលលើកឡើងដោយភាគី ក្នុងការស្នើសុំឲ្យមានសវនាការជាសម្ងាត់នោះ គឺអង្គជំនុំជម្រះយល់ថា មិនចាំបាច់ទេ។

[០៩:២៩:៥២]

សូមអញ្ជើញ ហើយសូមបញ្ជាក់ពីបញ្ហាឡើងវិញ វាមិនសំខាន់ទេ ថាចង់ដឹងទីកន្លែងរក្សាទុកឯកសារដោយ ស៊ី.ឌី.ខេម នូវឯកសារនោះ។ វាសំខាន់ថា ភាគីដែលពាក់ព័ន្ធនឹងរឿងក្តី ដែលឯកសារយកមកធ្វើជាឯកសារភស្តុតាងនៅក្នុងសំណុំរឿងក្តីនេះ ជាឯកសារចម្លង ឬក៏ស្កេនចូលនៅក្នុងសំណុំរឿង ប្រសិនបើភាគីមានបំណងយកទៅផ្ទៀងផ្ទាត់ចង់ផ្ទៀងផ្ទាត់នូវឯកសារនោះ ជាមួយនឹងឯកសារដើម តើខាង ស៊ី.ឌី.ខេម ហ្នឹងអាចធានាថា គឺអាចប្រព្រឹត្តទៅបាននៅក្នុងការធ្វើដូច្នេះ។ បានន័យថាផ្ទៀងផ្ទាត់គឺឯកសារដើមហ្នឹង គឺមានគ្រប់ពេលវេលាក្នុងអាចឲ្យប្រព្រឹត្តទៅបាន គ្រាន់តែកន្លែងរក្សាការសម្ងាត់នៃឯកសារ ដើម្បីរក្សាសុវត្ថិភាពឯកសារហ្នឹង គឺមិនអាចប្រាប់ឲ្យជាក់លាក់អំពីទីកន្លែងបានទេ។

[០៩:៣០:៥៥]

**លោក ឆាំង យុះ**

សូមគោរពលោកចៅក្រម បើសិនជាភាគីទាំងអស់ត្រូវការផ្ទៀងផ្ទាត់ឯកសារចម្លង នឹងឯកសារដើម គឺមជ្ឈមណ្ឌលឯកសារកម្ពុជាធានាគ្រប់ពេលវេលាចង់ផ្ទៀងផ្ទាត់ពេលណាក៏បានដែរ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។

**សួរដោយលោក អាកឡូរ វែកគែន៖**

រហូតដល់ថ្ងៃនេះ គឺថាមានភាគីមួយក្នុងចំណោមភាគីទាំងអស់នៅក្នុងតុលាការនេះ ទោះបីជាសហព្រះរាជអាជ្ញា ទោះបីជាសហចៅក្រមស៊ើបអង្កេត ពួកគេទាំងអស់សុំឱ្យលោកទៅរកឯកសារច្បាប់ដើមដែលនៅសម័យកម្ពុជាប្រជាធិបតេយ្យ គឺថាមិនប្រកាន់ទេ ថាកន្លែងនោះទុកនៅកន្លែងណាក៏ដោយ នេះមិនជាការសំខាន់ទេ។

**ស៖** តើការដែលថាសុំ អ្ហឺ! ថាសហព្រះរាជអាជ្ញា ឬក៏សហចៅក្រមស៊ើបអង្កេតហ្នឹងបានសុំឱ្យស៊ី.ឌី.ខេម ហ្នឹងមើល បង្ហាញច្បាប់ដើម ដែលលោកគិតថាឯកសារនោះធ្វើនៅសម័យខ្មែរក្រហមដែលលោក ដែលថាលោកនោះយល់ឃើញថាសុទ្ធតែឯកសារសម័យខ្មែរក្រហមទាំងអស់ ហើយមានតែមួយទេ ដែលលោកយល់ឃើញថាប្រហែលជាមិនមែននៅសម័យខ្មែរក្រហមនោះ?

[០៩:៣២:៣៧]

**លោក ឆាំង យុ៖**

**ឆ៖** លោកចៅក្រម ខ្ញុំមិនយល់សំណួរ ប៉ុន្តែខ្ញុំសុំធ្វើការសន្មត ហាក់បីដូចជាលោកមេធាវីចង់មានប្រសាសន៍ថា បើសិនជាភាគីទាំងអស់ចង់ផ្ទៀងផ្ទាត់ឯកសារដើម ខ្ញុំបាទអាចធ្វើជូនបាន ពេលណាក៏បានដែរ។ ហាក់ដូចជាសំណួរដដែល ហើយខ្ញុំឆ្លើយទៅដដែលវិញ ដរាបណាលោកចៅក្រមយល់ឃើញថា សំណួរនេះមានលក្ខណៈណាផ្សេង សូមមេត្តាផ្តល់ជា--

**ស៖** បាទ លោកសាក្សី ខ្ញុំសូមកាត់ផ្តាច់លោកខ្ញុំ បានសួរលោកថា--

**ប្រធានអង្គជំនុំ៖**

លោកមេធាវី រៀបចំនូវស្ថានភាពឱ្យល្អប្រសើរជាងនេះ នៅក្នុងការតាំងសំណួរចំពោះសាក្សី។ ទីមួយ គឺទុកចន្លោះពេលៗបន្តិចដើម្បីឱ្យអ្នកបកប្រែហ្នឹងអាចបកប្រែបានចប់ចុង ចប់ដើម។ បញ្ហាទីពីរ គឺមិនគប្បីកាត់នូវចម្លើយរបស់សាក្សីឡើយ។

សូមអញ្ជើញ!

[០៩:៣៣:៣៦]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** សំណួរខ្ញុំ គឺចង់ដឹងថា តើសព្វថ្ងៃនេះ សហព្រះរាជអាជ្ញា ហើយនិងសហចៅក្រមស៊ើបអង្កេតបានសុំលោក សុំមើលឯកសារច្បាប់ដើមដែលលោកយល់ឃើញថា ជាឯកសារសរសេរនៅសម័យកម្ពុជាប្រជាធិបតេយ្យនោះ តើមែនដែរឬទេ?

**ឆ៖** មកទល់សព្វថ្ងៃនេះ សហព្រះរាជអាជ្ញា ហើយនិងចៅក្រមស៊ើបអង្កេត ពុំដែលបានស្នើសុំមើលឯកសារផ្ទៀងផ្ទាត់ទេ ប៉ុន្តែបានស្នើសុំធ្វើការស្កេនដោយខ្លួនឯង ចេញពីឯកសារដើម។ បាទ គឺឯកសារដើមទាំងអស់នេះ គឺស្កេនឡើងដោយលោក ស្ទីវ ហេដឌ័រ ចេញមកពីការិយាល័យ អូ.ស៊ី.អាយ.ជេ។

**ស៖** តើលោកបានទទួលអាណត្តិជាផ្លូវការរបស់តុលាការនេះក្នុងការថែរក្សាឯកសារតុលាការដែលមានបិទស្លាកនោះទេ?

**ឆ៖** អត់ទេ បាទ។

[០៩:៣៥:០៨]

**ស៖** ម្សិលមិញលោកបានពន្យល់វគ្គមួយទាក់ទងទៅនឹង គម្រោងកិច្ចព្រមព្រៀងជាមួយតុលាការ លោកបានបញ្ជាក់ថា កិច្ចព្រមព្រៀងនេះមិនត្រូវបានចុះហត្ថលេខានោះទេ តើនេះជារឿងកិច្ចព្រមព្រៀងរវាងការទទួលស្គាល់ឯកសារតុលាការនេះឬក៏យ៉ាងណា?

**ឆ៖** ពីដំបូងឡើងគឺយើងមានការព្រួយបារម្ភក្នុងការស្នើសុំពីតុលាការ ចំពោះឯកសារដែលយើងមាន ហើយយើងបានគិតតាំងពីឆ្នាំ២០០៥ ខ្ញុំបានសរសេរលិខិតជូនទៅខាងរាជរដ្ឋាភិបាល បានទៅជួបនៅខាងអង្គការសហប្រជាជាតិ ដូចខ្ញុំជម្រាបពីម្សិលមិញអ៊ីចឹង ខ្ញុំបានជួបជាមួយលោកស្រីមីសែល លី, លោក ស៊ាន វិសុទ្ធ។ ហើយបានឲ្យធ្វើជាពង្រាង បាទធ្វើជាពង្រាង អ្វីដែលយើងធ្វើ ៗជាពង្រាងជូនជាយោបល់ថាតើដើម្បីទទួលបានឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជា ថាតើយើងគួរមានកិច្ចព្រមព្រៀងដែរឬក៏យ៉ាងណា? យើងបានព្យាយាមនៅក្នុងឆ្នាំ២០០៥, ២០០៦, ២០០៧, ២០០៨ រហូតយើងបានស្នើសុំម្តងទៀត នៅក្រោយការលាលែងរបស់លោក ស៊ាន វិសុទ្ធ ហើយនិងអ្នកស្រីមីសែល លី យើងបានផ្ញើសំណើជាថ្មីជូនលោក ឃ្នុត ហើយនិង តូនី ក្រាញ់ ដើម្បីពិចារណាឡើងវិញ។

[០៩:៣៦:២៨]

ប៉ុន្តែរហូតដល់ឆ្នាំ២០០៩ ហាក់ដូចជាគ្មានការឆ្លើយតប យើងក៏បោះបង់គំនិតនេះ ពីព្រោះថា

នៅក្នុងរយៈពេលឆ្នាំ២០០៦ រហូតទល់មក ២០០៩ គ្រប់អង្គភាពទាំងអស់បានធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរ ហើយយើងបានឆ្លើយតបគ្រប់សំណើទាំងអស់ទាំងក្រុមការពារក្តីជនចុងចោទ ទាំងការិយាល័យ អូ.ស៊ី.អាយ.ជេ និង អូ.ស៊ី.ភី ហើយនិងក្រុមដើមបណ្តឹងរដ្ឋប្បវេណី។ អ៊ីចឹង ក៏យើងអនុវត្តតាមគោលការណ៍ស្នើសុំរវាងតុលាការ ទៅនឹងស្ថាប័នយើង ដែលគេចាត់ទុកថាជាកន្លែងបណ្ណសារដ្ឋាន។ អ៊ីចឹងយើងគ្មានការព្រមព្រៀងអ្វីទាំងអស់ជាមួយតុលាការនេះជាផ្លូវការបាទ។

**ស៖** ក៏ប៉ុន្តែឥឡូវនេះ ដោយហេតុថាលោកបានជម្រាបថា ពុំមានភាគីណាដែលប្រាថ្នាចង់បានឯកសារច្បាប់ដើម ដែលលោកគិតថា ជាឯកសារនៅសម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារដែលលោកបានជូនដល់ភាគីដែលបានសុំលោកនោះ ឧទាហរណ៍ដូចជាសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាជាដើម តើឯកសារទាំងអស់នោះ ជាឯកសារថតចម្លង ឬស្កេន ឬក៏យ៉ាងម៉េច? តើត្រឹមត្រូវដែរ ឬទេ?

**ឆ៖** នៅក្នុងការបញ្ជូនឯកសារមកការិយាល័យសហព្រះរាជអាជ្ញាក្តី អូ.ស៊ី.អាយ.ជេ ក្តី និងក្រុមការពារជនចុងចោទក្តី គឺយើងមានធ្វើបញ្ជីមួយ បង្ហាញអំពីថាតើឯកសារនេះស្កេនចេញ ឬក៏ថតចម្លងចេញពីឯកសារដើម ហើយមានការស៊ីញ៉េ មានការទទួលជាក់លាក់អំពីភាគីដែលបានស្នើសុំ។ លើកលែងតែការិយាល័យ អូ.ស៊ី.អាយ.ជេ បានស្នើសុំធ្វើការស្កេនឯកសារចេញពីឯកសារដើមដោយផ្ទាល់ខ្លួនឯងតែម្តង។

[០៩:៣៨:៣៥]

**ស៖** អ៊ីចឹងទាក់ទងនឹងបញ្ហានេះ ម្សិលមិញនៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា លោកបានជម្រាបថា ដោយមាន-- ក្នុងបំណងមិនធ្វើឱ្យឯកសារខូចខាត ឲ្យរេចរិលដែលលោកគិតថាជាឯកសារនៅសម័យនោះៗ អ៊ីចឹងពេលនោះ តើលោកមិន-- កាលនោះលោកមិនសរសេរលើឯកសារនោះទេ ឯកសារដើមទេ តើពិតជាមែនដែរឬទេ?

**ឆ៖** ពិតហើយ។

**ស៖** លោកបានបំភ្លឺយ៉ាងដូច្នេះហើយ បន្ទាប់មកទៀតលោកបានជម្រាបថា លេខកូដ ស៊ី.ឌី.ខេម នោះគឺថាចារតែនៅលើឯកសារចម្លងទេ ដែលលោកចាត់ទុកថាជាឯកសារដូចឯកសារនៅសម័យនុំងដែរ។ តើពិតជាត្រឹមត្រូវដែរឬទេ?

[០៩:៣៩:៤២]

**ឆ៖** គ្រប់ឯកសារដែលយើងបានថតចម្លងចេញពីឯកសារដើម យើងចុះបញ្ជីមានលេខអក្សរ "D" ហើយនិងមានលេខអក្សរផ្សេងៗទៀត។ ហើយនៅក្នុងឯកសារនីមួយៗនេះ យើងមានធ្វើកំណត់ចំណាំផ្នែកតូចមួយនៅខាងក្រោមលេខ "D" នេះ ដើម្បីបញ្ជាក់ថា តើឯកសារនេះចេញពីប្រភពដើមកន្លែងមួយណា។ ដូចខ្ញុំប្រាប់ពីម្សិលមិញអ៊ីចឹង បើសិនជាចង់ លោកចង់ត្រូវការផ្ទៀងផ្ទាត់នឹងឯកសារដើម យើងអាចមើលកំណត់ចំណាំនៅក្រោមអក្សរតូចមួយ អាចទៅរកឯកសារដើមផ្ទៀងផ្ទាត់បានដោយមិនមានការលំបាក។

**ស៖** ដូច្នេះ អ៊ីចឹងបានន័យថា នៅក្នុងសំណុំរឿងនៃឯកសារនេះ គេបង្ហាញឯកសារដែលគេចាប់សន្មតថា ជាឯកសារនៅសម័យកម្ពុជាប្រជាធិបតេយ្យ ដែលមានកូដរបស់ ស៊ី.ឌី.ខេម អ៊ីចឹងគឺថាបានន័យថាឯកសារទាំងអស់នេះ គឺជាឯកសារចម្លង ពីព្រោះថាវាមានកំណត់ចំណាំរបស់ ស៊ី.ឌី.ខេម តើពិតជាត្រឹមត្រូវដែរឬទេ?

[០៩:៤០:៥៨]

**ឆ៖** បើសិនជាលោកនិយាយសំដៅទៅលើឯកសារថតចម្លង ដែលយើងបានបញ្ជូនមកតុលាការ គឺពិតជាមានលេខរបស់ ឌី.ស៊ី.ខេម ដើម្បីបញ្ជាក់ថាឯកសារនេះត្រូវបានថតចម្លង ឬក៏ស្កេនចេញពីឯកសារដើម។ ដោយឡែកនៅក្នុងការិយាល័យ អូ.ស៊ី.អាយ.ជេ គេបានយកតួលេខ លេខខាងក្រោមកំណត់សម្គាល់ខាងក្រោមនៃលេខឯកសារ "D" យកមកស្កេនផ្ទាល់តែម្តង។

អ៊ីចឹងដោយឡែកនៅក្នុងការិយាល័យ អូ.ស៊ី.អាយ.ជេ នេះ គេមានឯកសារដែលថតចេញផ្ទាល់ដោយអត់មានលេខ ឌី.ស៊ី.ខេម ទេ ប៉ុន្តែឯកសារនេះអាចទៅផ្ទៀងផ្ទាត់ទៅនឹងឯកសារហ្វូតូកូពី ដែលយើងបានផ្តល់ឲ្យគេកាលពីមុនមកក៏បានដែរ។

**ស៖** នៅក្នុងសំណុំរឿង យើងមាន*អ៊ីម៉ែល*មួយចំនួនដែលចេញមកពីខាងសហព្រះរាជអាជ្ញា ហើយជាមួយនឹង ដែលសហព្រះរាជអាជ្ញាសុំឲ្យៗលោកផ្តល់ឯកសារដែលលោកមាននៅមជ្ឈមណ្ឌលរបស់លោកនោះ។ អ៊ីចឹងខ្ញុំបង្ហាញអ៊ីម៉ែលមួយ ខ្ញុំគិតថាមិនមានបកប្រែអីទេ អ៊ីចឹងមានលេខ ERN គឺថា 00141959 ហើយលេខកូដផ្សេងទៀតហ្នឹងជាសុទ្ធតែជាអ៊ីម៉ែលដូចគ្នាអ៊ីចឹងដែរ។ អ៊ីចឹង ខ្ញុំគិតថាយើងអាចចាក់បញ្ចាំងអ៊ីមែលហ្នឹងទៅលើអេក្រង់។ អ៊ីចឹងយើងឃើញថា នៅក្នុងឯកសារឆ្លើយឆ្លងគ្នានេះ សហព្រះរាជអាជ្ញាសូមឲ្យលោកផ្តល់ឯកសារ ហើយនិងធ្វើការ សុំលិខិតបញ្ជាក់អំពីយថាភាពរបស់ឯកសារ។ តើលោកអាចៗពន្យល់យើងអំពីឯកសារ លិខិតបញ្ជាក់ហ្នឹងបានទេ?

[០៩:៤៣:៥៣]

**ឆៈ** បាទ នេះគឺជាទម្រង់ ការស្នើសុំមួយពីការិយាល័យសហព្រះរាជអាជ្ញា ហើយយើងមានច្រើនណាស់ មានរាប់រយសន្លឹក។ នេះមិនមែនតែមួយទេ មានមួយសៀវភៅ តាមដែលខ្ញុំចាំ។ ហើយខាងស្ដាំនេះ គឺជា *ទីសហ្វូល* របស់ខ្ញុំ ដែលបានបញ្ជាក់ថា នេះខ្ញុំបានទទួលសំណើ ហើយបានផ្ដល់ជូនឯកសារជូនគាត់។

[០៩:៤៤:២៥]

**សៈ** ចុះលិខិតបញ្ជាក់ពីយថាភាពនោះមានន័យយ៉ាងម៉េច ដែលការថាព្រះរាជអាជ្ញាបានសួរ សុំសួរទៅលោកនោះ ប្រហែលជាលោកបានចេញលិខិតបញ្ជាក់ហ្នឹងទៅឱ្យខាងសហព្រះរាជអាជ្ញាដែរ?

**ឆៈ** ខ្ញុំបានសរសេរលិខិតមួយ តាមដែលខ្ញុំចាំ ខ្ញុំសរសេរជូនលោក ពេទីត កាលណោះលោកពេទីត ជាសហព្រះរាជអាជ្ញាជាមួយអ្នកស្រី ជា លាង។ ប្រហែលជាប្រាំមួយប្រាំពីរទំព័រ បញ្ជាក់អំពីដំណើរការនៃការស្រាវជ្រាវ ហើយនិងយថាភាពរបស់ឯកសារ។ លិខិតនេះ ខ្ញុំគិតថាមាននៅក្នុងសំណុំរឿងដែរ ពីព្រោះខ្ញុំបានផ្ញើជូនអ្នកទាំងពីរ ប្រហែលជានៅក្នុងរវាងឆ្នាំ២០០៧ ឬ២០០៦ ខ្ញុំមិនច្បាស់ឆ្នាំប៉ុន្តែមាន ខ្ញុំបានសរសេរជូនជាលាយលក្ខណ៍អក្សរ។

[០៩:៤៥:២០]

**សៈ** តើចម្លើយរបស់លោកហ្នឹង គឺថាចង់និយាយថាតាំងពីឆ្នាំ២០០៧ មកលោកបានផ្ដល់លិខិតបញ្ជាក់ពីយថាភាពហ្នឹងតែមួយគត់សម្រាប់ឯកសារទាំងអស់ ឬក៏យ៉ាងម៉េច? ហើយក៏សម្រាប់ឯកសារដែលថាទាំងអម្បាលម៉ានដែលលោកនឹងផ្ដល់ជូននៅអនាគតកាលនោះ? ឬក៏ថា ឬក៏មានឯក-- កន្លងមកហ្នឹង គឺថាមានបញ្ជាក់ពីយថាភាពហ្នឹង រាល់សំណើសុំឯកសារទាំងអស់?

**ឆៈ** នៅក្នុងរាល់សំណើចេញពីការិយាល័យសហព្រះរាជអាជ្ញា គឺយើងបានមានបញ្ជាក់នៅក្នុងបញ្ជីៗដែលយើងផ្ដល់ឯកសារជូន អំពីប្រភេទឯកសារដើម ឬក៏ប្រភេទឯកសារថតចម្លង។ អ៊ីចឹងរៀងរាល់សំណើទាំងអស់ គឺមាននៅក្នុងខ្ទង់មួយដែលបានបញ្ជាក់ថា ឯកសារនេះគឺជាឯកសារដើម ឯកសារនេះឬក៏ជាឯកសារថតចម្លង។ ហើយនៅក្នុងលិខិតនេះ យើងបានសរសេរជាប្រភេទ ជារួមៈ នៅក្នុងប្រភេទ ឯកសារ K, ឯកសារ I, ឯកសារ D, ឯកសារ L គឺយើងសរសេរជារួមអំពីដំណើរ ឬក៏នីតិវិធីដែលយើងបានគ្រប់គ្រងឯកសារ បញ្ជាក់អំពីយថាភាពនៃឯកសារទាំងស្រុង។

[០៩:៤៦:៥៤]

**សៈ** កាលពីម្សិលមិញលោកបានរៀបរាប់ អំពីវិធីសាស្ត្រក្នុងការផ្ទៀតផ្ទាត់យថាភាពនៃឯកសារដែលលោកប្រើប្រាស់នៅកន្លែងរបស់លោក ហើយជាបឋមបានរៀបរាប់អំពីសារៈសំខាន់នៃពណ៌ ឬក៏ទិដ្ឋភាពនៃឯកសារនីមួយៗ។ តើលោកយល់ស្របទេថា ការងារបែបនេះគឺថាមិនអាចធ្វើបានទេ នៅពេលដែលយើងធ្វើទៅលើឯកសារថតចម្លងនោះ?

**ឆៈ** ជាការត្រឹមត្រូវ។ យើងមិនអាចធ្វើបានទៅលើឯកសារថតចម្លងទេ ប៉ុន្តែយើងអាចធ្វើបានដោយយើងអាចដឹងថា ឯកសារថតចម្លងគឺជាឯកសារថតចម្លងពីព្រោះវាមានពណ៌តែមួយ ទោះបីជាពណ៌ខ្មៅសក៏យើងដឹងថា វាជាពណ៌តែមួយ ហើយយើងអាចបញ្ជាក់ថាវាក៏ជាឯកសារហ្វូតូកូពីដែរ។ អ៊ីចឹងបើសិនជាមានឯកសារមួយទៀតដែលមានពណ៌ លោកអាចផ្ទៀងផ្ទាត់មើលថា តើមួយណាជាឯកសារថតចម្លង មួយណាជាឯកសារដើម។

**សៈ** លោកក៏បានបញ្ជាក់ផងដែរ ក្នុងចំណោមតម្រុយដែលទទួលបានការចាប់អារម្មណ៍របស់លោកពាក់ព័ន្ធទៅនឹងការពិនិត្យទៅលើឯកសារនីមួយៗនោះ គឺពាក់ព័ន្ធទៅនឹងបញ្ហានៃកាលបរិច្ឆេទដែលមាននៅលើឯកសារ។ តើលោកយល់ស្របទេថា គឺថាមានមនុស្សដែលមានចេតនាទុច្ចរិតណាមួយនោះអាចបង្កើតជាឯកសារ ហើយដែលវាមិនមែនជាៗ ឧទាហរណ៍ដូចថាមិនមែនឆ្នាំ២០១២ ទេ គាត់បែរទៅជាបង្កើតថ្ងៃប្រឌិតកាលបរិច្ឆេទណាមួយទៅជាចន្លោះឆ្នាំ៧៥ ទៅដល់ឆ្នាំ៧៩ ទៅវិញនោះ? អ៊ីចឹងតើលោកគិតយ៉ាងម៉េចដែរនៅពេលនោះ?

[០៩:៤៨:៥៧]

**ឆៈ** ខ្ញុំគិតថា ប្រសិនបើមានមនុស្សម្នាក់អាចបង្កើតឯកសារចំនួន ១លានទំព័រ ហើយមានសាច់រឿងខុសគ្នាៗមកពីទូទាំងប្រទេស ស្គាល់មនុស្សឈ្មោះរាប់សែននាក់ ខ្ញុំគិតថាមនុស្សនោះពិតជាអស្ចារ្យមែនទែន។ អ៊ីចឹងជារឿងមួយដែលកម្រនឹងអាចធ្វើទៅបានណាស់។ ទីពីរ ទៀតនៅក្នុងនេះ យើងមិនមែនមើលតែកាលបរិច្ឆេទទេ យើងមើលសាច់រឿង មើលពាក្យពេចន៍ មើលខ្លឹមសារ មើលពណ៌សម្បុរ ហើយឯកសារនីមួយមានទាក់ទងគ្នា មិនមែនដាច់ដោយឡែកតែឯងទេ។ ដូចជា ឧទាហរណ៍កាលពីម្សិលមិញអ៊ីចឹង គឺយើងមានឯកសារផ្ញើពីស្រុកមកឃុំមកទៅតំបន់ផ្សេងៗ។ អ៊ីចឹងយើងអាចធ្វើការស្រាក់គ្នាពីឯកសារមួយទៅឯកសារមួយហ្នឹង ដើម្បីបញ្ជាក់ថាឯកសារនេះ ពិតជារបបកម្ពុជាប្រជាធិបតេយ្យមែន។

[០៩:៤៩:៤៦]

**ស៖** លោកក៏បានបញ្ជាក់ជូនអង្គសវនាការដែរ នៅពេលដែលឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ហើយនិងខាងដើមបណ្តឹងរដ្ឋប្បវេណីគឺថា លោកយកចិត្តទុកដាក់ក្នុងការពិនិត្យទៅលើប្រភេទនៃវាក្យស័ព្ទដែលប្រើប្រាស់នៅក្នុងឯកសារ ដែលបានយកមកប្រគល់ជូនលោក ឬក៏លោកជាអ្នកប្រមូលដោយផ្ទាល់។ តើលោកឯកភាពទេ ថាអាចមានអ្នកដែលមានចេតនាទុច្ចរិតណាមួយព្យាយាមបង្កើតឯកសារក្លែងក្លាយនៅសម័យនោះ? ហើយគាត់អាចមិននិយាយអំពីអ៊ុនធីណែត ឬក៏និយាយអំពីទូរស័ព្ទដៃ ដែលមិនមាននៅចន្លោះឆ្នាំ៧៥ នោះ ដល់ឆ្នាំ៧៩នោះ។

**ឆ៖** ខ្ញុំសូមជម្រាបជូនលោក ខ្ញុំសូមលើកជាឧទាហរណ៍មួយ ឯកសារចម្លើយសារភាពរបស់អ្នកជាប់ទោស បុប្ផាណា ដែលមានកម្រាស់ទៅដល់មួយពាន់ទំព័រ។ បើសិនជាលោកមានពេលដើម្បីកែច្នៃពាក្យទាំងអស់នេះ គឺថាលោកមិនអាចធ្វើទៅបានទេ ពីព្រោះមានកម្រាស់ច្រើនណាស់ មិនមែនមួយសន្លឹកពីរសន្លឹកទេ។ ហើយបើសិនជាលោកធ្វើមួយសន្លឹកពីរសន្លឹក វាជាការងាយក្នុងការយើងចាប់បាន បើសិនជាមានជនទុច្ចរិតណាមួយមានចេតនាធ្វើបែបនេះ។ អ៊ីចឹងឯកសារនេះ ដូចខ្ញុំជម្រាបពីខាងដើមអ៊ីចឹង វាស្រាក់គ្នា វាមិនមែនជាឯកសារមើលតែមួយ ឃើញរឿងតែមួយទេ។ យើងអាចផ្ទៀងផ្ទាត់ព្រោះនៅក្នុងឯកសារខ្លះ មានទាំងអ្នកនិពន្ធ មានទាំងអ្នកសួរចម្លើយ មានទាំងហត្ថលេខា មានទាំងមនុស្សពីរបីនាក់នៅលើឯកសារនេះទៀត។ អ៊ីចឹងវាជាការមួយដែលកម្រ ហើយបើសិនជាមានមនុស្សម្នាក់អាចធ្វើឯកសារបានមួយលាន ឬក៏បង្កើតសាច់រឿងបានមួយលានរឿង ឬក៏អាចបង្កើតចម្លើយសារភាពបានប្រាំពាន់ ដែលក្នុងឯកសារចម្លើយសារភាពខ្លះមានរហូតទៅដល់មួយពាន់ទំព័រ មនុស្សនោះត្រូវការរយៈពេលច្រើនឆ្នាំណាស់បានធ្វើបាន។

[០៩:៥១:៥០]

**ស៖** គឺថាយើងមិនអាចនិយាយថា មានមនុស្សម្នាក់អាចផលិតឯកសាររាប់លានបានទេ។ ប៉ុន្តែលោកខ្លួនឯងផ្ទាល់នេះ លោកបានទទួលស្គាល់ថា យ៉ាងហោចណាស់ក៏មានឯកសារមួយដែរនៅក្នុងចំណោមឯកសារជិតមួយលាននោះ។ គឺអ៊ីចឹងគឺថា ចំពោះលោកនោះ ក៏លោកបានឃើញដែរ មានឯកសារមួយដែលប្រហែលជាឯកសារក្លែងក្លាយ ក្នុងចំណោមឯកសារជិតមួយលាននោះ។ តើពិតដែរឬទេ?

**ឆ៖** ជាការពិត ហើយឯកសារនេះ ដែលទាក់ទាញចាប់អារម្មណ៍របស់ខ្ញុំឱ្យសម្គាល់ថា ជាឯកសារមួយមិនមែនជារបបកម្ពុជាប្រជាធិបតេយ្យ គឺទីមួយ គឺកាលបរិច្ឆេទនេះឯង។ ធ្វើឡើងនៅក្នុង

៩១ ឆ្នាំ៩៥។ វាគឺជា១ចំណុចមួយដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍ដំបូង ពីព្រោះជា-- កាលបរិច្ឆេទនេះគឺបានបញ្ជាក់ច្បាស់ហើយ ថាមិនមែនជាកាលបរិច្ឆេទនៃរបបកម្ពុជាប្រជាធិបតេយ្យទេ។ អ៊ីចឹងយើងបានមើលទៅខ្លឹមសារ អ៊ីចឹងយើងបានមើលទៅលើអត្ថន័យបន្ថែមទៀត។ អ៊ីចឹងយើងបានសម្រេចថា ឯកសារនេះ គឺមិនមែនរបស់កម្ពុជាប្រជាធិបតេយ្យទេ។

[០៩:៥២:៥៣]

**ស៖** តើលោកអាចបញ្ជាក់ជូនតុលាការទេថា ឯកសារដែលលោកមានប្រសាសន៍អម្បាញ់មិញនេះមានការចុះកាលបរិច្ឆេទពេលណាដែរ?

**ឆ៖** តាមដែលខ្ញុំចាំ ប្រហែលជាក្នុងរវាងឆ្នាំ៩៥ ឬ៩៦ ខ្ញុំចាំមិនច្បាស់ ប៉ុន្តែនៅក្នុងរយៈកាលនៃការចាប់ខ្លួនជនបរទេសនៅក្នុងខេត្តកំពត។

**ស៖** ដូច្នេះលោកសន្និដ្ឋានថា វាជាឯកសារក្លែងក្លាយមួយដែលថាអ្នកដែលធ្វើនោះ គាត់មិនសូវមានទេពកោសល្យ តើមែនទេ?

**ឆ៖** ខ្ញុំមិនបានគិតថា ឯកសារនេះជាឯកសារក្លែងក្លាយទេ។ ខ្ញុំគិតថា ឯកសារនេះមិនមែនជាឯកសារចេញមកពីរបបកម្ពុជាប្រជាធិបតេយ្យ។

**ស៖** កាលពីម្សិលមិញជាច្រើនលើកច្រើនសា លោកបានពន្យល់អំពីប្រភពនៃការប្រមូលឯកសារផ្សេងៗដែលរក្សាដោយខាង ស៊ី.ឌី.ខេម ហើយលោកបាននិយាយអំពីអ្នកជំនាញការវៀតណាម តើលោកអាចបញ្ជាក់ជូនខាងយើងបានទេ ថាតើអ្នកណាខ្លះជាអ្នកជំនាញការវៀតណាមនេះ? តើលោកសំដៅដល់អ្នកណាខ្លះ ដែលនៅពេលលោកហៅថា អ្នកជំនាញការវៀតណាមនេះ?

[០៩:៥៤:៣៧]

**លោក ឆាំង យុ៖**

លោកចៅក្រម ម្សិលមិញ ខ្ញុំបានប្រើពាក្យថា អ្នកជំនាញការវៀតណាម? សូមអធ្យាស្រ័យពីព្រោះខ្ញុំគិតថា ខ្ញុំអត់បានប្រើពាក្យនេះ។ ប៉ុន្តែខ្ញុំក៏មិនអល់អែកក្នុងការឆ្លើយសំណួរនេះដែរ។ ប៉ុន្តែខ្ញុំមិនចង់ឲ្យមានការដាក់អ្វីដែលខ្ញុំមិនបាននិយាយកាលពីម្សិលមិញ។ ហើយបើសិនជាលោកចៅក្រមអនុញ្ញាត ខ្ញុំអាចឆ្លើយជូនក៏បាន។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី លោកអាចបង្ហាញពីប្រតិចារឹកពីម្សិលមិញ ពេលត្រង់ចំណុចណាមួយ នៃចម្លើយ

E1/38.1

របស់សាក្សីរូបនេះ ដែលបាននិយាយពាក់ព័ន្ធជាមួយនឹងពាក្យ ជំនាញការវៀតណាមបានដែរឬទេ? ដើម្បីឱ្យផ្ទុះបញ្ជាំងនៅលើសំណួររបស់លោក ដើម្បីឱ្យមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីឱ្យយើងនឹងសម្រេចអនុញ្ញាតឱ្យសាក្សីឆ្លើយតប ពីព្រោះសាក្សីបានគិតថា ខ្លួនមិនបាននិយាយពាក្យនេះនៅឡើយទេ។

[០៩:៥៦:១០]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកប្រធានប្រសិនបើដូច្នេះ ខ្ញុំអាចសួរសាក្សីថាតើគាត់អាចចងចាំថា គាត់បានឆ្លើយទៅនឹងសំណួររបស់ព្រះរាជអាជ្ញា អ៊ំ សូមទោស សហចៅក្រមស៊ើបអង្កេត ហើយគាត់និយាយអំពីឯកសារដែលប្រមូលបានដោយអ្នកជំនាញការវៀតណាម?

**លោក ឆាំង យុ៖**

លោកចៅក្រមខ្ញុំសូមឱ្យគាត់ឆ្លើយសំណួរមុនសិន ថាខ្ញុំបាននិយាយដែរឬក៏អត់កាលពីម្សិលមិញ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ គាត់ដូរសំណួរហើយ បានន័យថា សំណួរអំមិញលោកសាក្សីមិនបាច់ឆ្លើយទេ ពីព្រោះគាត់មានការភ័ន្តច្រឡំរវាងការផ្ទៀងផ្ទាត់ផ្គូផ្គង នូវឯកសារដែលខាងសហចៅក្រមស៊ើបអង្កេតហ្នឹងបានសួរលោកក្នុងអំឡុងពេលស៊ើបសួរ។ អ៊ីចឹងបញ្ហានេះ គឺគាត់ដូរសំណួរវិញ បានន័យថា សំណួរដែលគាត់ឆ្លើយថា និយាយថា អម្បាញ់មិញនេះគឺ មានន័យថា មានការភ័ន្តច្រឡំ គឺគាត់ដូរសំណួរវិញដោយសារផ្គូផ្គងពីរសំណួរដែលលោកបានសួរលើកមុន នេះជាការអនុញ្ញាតរបស់អង្គជំនុំជម្រះ ប្រសិនបើសំណួរដែលបានសួររួចហើយ ដើម្បីធ្វើការផ្គូផ្គងតទល់ជាមួយនឹងសាក្សី បានបានវត្តមាន។

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

អង្គជំនុំជម្រះ ខ្ញុំគិតថា មេធាវីការពារក្តីគួរតែសំអាងទៅលើចម្លើយណាមួយរបស់សាក្សី ឱ្យបានជាក់លាក់ ពីព្រោះវាមានកំណត់ហេតុស្តាប់ចម្លើយសាក្សីរូបនេះ ដល់ទៅ៦ ឯណោះ។ ដើម្បីឱ្យបង្ហាញឱ្យបានច្បាស់ ថាតើកំណត់ហេតុស្តាប់ចម្លើយណាមួយ ដែលមេធាវីការពារក្តីចង់សួរហ្នឹង?

[០៩:៥៨:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមមេធាវីបញ្ជាក់អំពីអត្តសញ្ញាណឯកសារឲ្យបានច្បាស់លាស់ ដែលលោកផ្អែកទៅលើកំណត់ហេតុដែលបានស្តាប់សក្ខីកម្មសាក្សីនេះ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។

**លោក អាកឡូវ វែកគែន៖**

លោកប្រធាន ខ្ញុំឯកភាពចំពោះបញ្ហានេះ។ ខ្ញុំនឹងធ្វើ ក៏ប៉ុន្តែនៅពេលនេះ ខ្ញុំគ្រាន់តែសួរទៅសាក្សីថា តើគាត់បានចងចាំទេថា គាត់បាននិយាយអំពីអ្នកជំនាញការវៀតណាម ទៅកាន់សហចៅក្រមស៊ើបអង្កេត? គឺថា សំណួរខ្ញុំគឺថា សង្កត់ធ្ងន់ទៅលើចំណុចនេះតែម្តង ខ្ញុំគ្រាន់តែចង់ដឹងថា តើគាត់ចងចាំដែរឬទេ? គឺថា អ៊ីចឹងហើយ ខ្ញុំមិនទាន់រៀបរាប់អំពីឯកសារទេ ប្រសិនបើគាត់និយាយថា គាត់មិនចាំទេ ខ្ញុំនឹងលើកឯកសារនោះឲ្យគាត់មើល។ ខ្ញុំធ្វើដូច្នេះ គឺថាដើម្បីកុំឲ្យខាតពេលវេលារបស់តុលាការ ពីព្រោះថា ពេលវេលាកាន់តែឈានទៅមុខហើយ ហើយខ្ញុំមិនចង់និយាយទៅលើថា ខ្ញុំមិនចង់ខាតពេលរបស់ភាគីខាងខ្ញុំទេ។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយនឹងសំណួរនេះ!

**លោក ឆាំង យុ៖**

លោកចៅក្រម ខ្ញុំរីករាយនឹងឆ្លើយសំណួរនេះ ប៉ុន្តែខ្ញុំសោកស្តាយ ដោយសារថាមេធាវីរូបនេះមិនបានទទួលស្គាល់ថា លោកមានចេតនាសួរសំណួរដែលមិនបានឲ្យឯកសារ ដែលខ្ញុំបាននិយាយកាលពីម្សិលមិញឲ្យបានជាក់លាក់ នេះគឺជាចំណុចសំខាន់មួយ ដែលយើងគួរកតសម្គាល់ដែរ ដែលយើងបង្ខាតពេលវេលាដែលសួរសំណួរដែលគ្មានមូលដ្ឋានជាក់លាក់។

**ឆ៖** ខ្ញុំបានប្រាប់ទៅចៅក្រមស៊ើបអង្កេតថា នៅក្នុងគ្រប់-- អ្នកគ្រប់គ្រងឯកសារនៅក្រសួងការ-- ក្រសួងប៉ូលិស បាទនៅក្នុងក្រសួងមហាផ្ទៃនេះ គឺមានជំនាញការមួយធ្វើការជាមួយក្រុមឯកសារនេះ។ ខ្ញុំបានឆ្លើយពិតជាអ៊ីចឹងមែន ហើយខ្ញុំបានរហូតតាមរកគាត់ទៀតផង ហើយគាត់បានស្លាប់បាត់បង់ជីវិតទៅហើយ។ ហើយព័ត៌មាននេះ ខ្ញុំបានទទួលមកពីក្រុមរៀបចំឯកសារនៅក្រសួងមហាផ្ទៃ។

[១០:០០:០៩]

**ស៖** គឺលោក ក៏លោកមិនឆ្លើយទៅសំណួររបស់ខ្ញុំដែរ លោកសាក្សី។ ដូច្នេះ វាជាការសន្ទនាគ្នាយើងនេះ ដូចជារៀងពិបាកបន្តិចហើយ។ ខ្ញុំក៏មិនបានឆ្លើយទៅសំណួររបស់លោកដែរ ហើយខាង

តុលាការសុំឲ្យលោកឆ្លើយមកកាន់ខ្ញុំ គឺខ្ញុំជាអ្នកសួរសំណួរ មិនមែលលោកជាសួរទេ។

**ប្រធានអង្គជំនុំ៖**

បាទ លោកមេធាវីភ័ន្តច្រឡំខ្លួនឯងទេ សាក្សីបានឆ្លើយជាក់ច្បាស់ហើយ។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ៗស្តាប់ភាសាខ្មែរបានផ្ទាល់ ហើយលោកប្រធានយល់ថាចម្លើយច្បាស់ ក៏ប៉ុន្តែចំពោះស្តាប់ភាសាបារាំង ដូចជាមិនសូវច្បាស់។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោក ឆាំង យុ តើលោកអាចបញ្ជាក់បានទេ ថាអ្នកជំនាញការដែលលោកនិយាយអំមិញនោះ គាត់ឈ្មោះអី? គាត់មានមុខងារអ្វី? ហើយតើគាត់បំពេញមុខងារនោះ ក្នុងអំឡុងឆ្នាំណា?

**លោក ឆាំង យុ៖**

**ឆ៖** ខ្ញុំមិនចាំឈ្មោះគាត់ ប៉ុន្តែបើសិនជាលោកមើលទៅក្នុងឯកសាររបស់ អូ.ស៊ី.អាយ.ជេ មានឈ្មោះ។ ពីព្រោះខ្ញុំបានសួរច្បាស់ណាស់ អំពីក្រុមរៀបចំឯកសារនៅក្រសួងមហាផ្ទៃ។ គាត់មានតួនាទីជាអ្នជំនាញការនាពេលនោះ របស់ក្រសួងមហាផ្ទៃ។ ឈ្មោះខ្ញុំមិនចាំច្បាស់ ប៉ុន្តែបើសិនលោកបើកឯកសារច្បាស់ជាមាន ពីព្រោះខ្ញុំបានធ្វើការជូនឯកសារនេះទាំងស្រុងទៅការិយាល័យសហចៅក្រមស៊ើបអង្កេត។

[១០:០២:១០]

**ស៖** ហើយនៅថ្ងៃនេះ លោកបាននិយាយថា លោកបានផ្តល់ជូនទៅខាងសហចៅក្រមស៊ើប-- លោកផ្តល់ឈ្មោះដល់សហចៅក្រមស៊ើបអង្កេត តើអ៊ីចឹងមែនទេ?

**ឆ៖** ពិតមែន។

**ស៖** តើលោកអាចបញ្ជាក់ជូនយើងបានទេ ថាតើមានចំនួនប៉ុន្មានដែរ ដែលលោកទទួលបានពីអ្នកជំនាញការវៀតណាមនេះ?

**ឆ៖** សូមទោសទទួលអីបាទ?

**ស៖** តើចំនួនឯកសារប៉ុន្មានដែលលោកបានទទួលពីអ្នកជំនាញការវៀតណាមនេះ?

**ឆ៖** ខ្ញុំមិនដែលទទួលបានឯកសារពីអ្នកជំនាញការនៅក្រសួងមហាផ្ទៃទេ។ ខ្ញុំយកឯកសារពីក្រសួងមហាផ្ទៃ។ នៅក្រសួងមហាផ្ទៃមានក្រុមរៀបចំឯកសារ ដែលមានជំនាញការម្នាក់ ធ្វើការជា

មួយក្រុមរៀបចំឯកសាររបស់ក្រសួងមហាផ្ទៃ។ ខ្ញុំមិនដែលបានទទួលឯកសារអំពីជំនាញការនៃក្រសួងមហាផ្ទៃទេ។ លោកអាចស្តាប់ច្បាស់ហើយ ពិសេសក្នុងការបកប្រែនៅក្នុងភាសាបារាំង។

[១០:០៣:៥២]

**ស៖** តើ ស៊ី.ឌី.ខេម បានដាក់លេខយោងយ៉ាងម៉េច ចំពោះឯកសារដែលលោក ហ៊ុន សែន ផ្តល់ជូនទៅមជ្ឈមណ្ឌល ស៊ី.ឌី.ខេម នោះ?

**ឆ៖** នៅក្នុងឯកសារនេះ យើងដាក់អក្សរ អេក.អេស (HS) ដើម្បីបញ្ជាក់ថាជាឯកសារ ដែលសម្តេចតេជោបានប្រគល់ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារនេះ គឺខ្ញុំបានរកឃើញនៅក្នុងសំណេររបស់សម្តេចតេជោ សៀវភៅពីរដែលគាត់បានសរសេរ ហើយខ្ញុំបានស្នើសុំទៅការិយាល័យរបស់លោក។ អ៊ីចឹង នៅក្នុងឯកសារនេះ កាលណាលោកឃើញអក្សរ អេក.អេស គឺមានន័យថា ហ៊ុន សែន។ អ៊ីចឹង គឺគាត់ជាអ្នកផ្តល់ឯកសារនេះ មកឲ្យខ្ញុំ ហើយសូមជម្រាបលោកថានៅគ្រប់ឯកសារទាំងអស់ ភាគីណាក៏អាចសុំបានដែរ មិនមែនជាឯកសារយកមកហើយលាក់ទុកនៅក្នុងកន្លែងណាមួយទេ។ ហើយសូមចាំថា សូម្បីតែនៅក្នុងគណបក្សប្រឆាំង ខ្ញុំក៏បានជូនឯកសារចំនួនមួយពាន់ទំព័រដែរ នៅក្នុងចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជាបាទ។

**ស៖** តើលោកដឹងទេ ថានៅឆ្នាំណា ដែលលោក ហ៊ុន សែន បានរកឃើញឯកសារទាំងអស់នោះ?

[១០:០៥:០០]

**ឆ៖** ខ្ញុំមិនដឹងថាលោក សម្តេចតេជោ រកឃើញឯកសារនៅក្នុងឆ្នាំណាទេ ប៉ុន្តែខ្ញុំបានចាំថា ឯកសារនេះ ខ្ញុំបានទទួលនៅក្នុងឆ្នាំប្រហែលជាក្នុងឆ្នាំ៩៥ ឆ្នាំ៩៦ នៅពេលដែលខ្ញុំអាន ចាប់ផ្តើមអានស្រាវជ្រាវឯកសារសំណេររបស់លោកនៅក្នុងបណ្ណាល័យជាតិ ហើយខ្ញុំឃើញលោកបានយោងឯកសារទាំងអស់នេះ។ អ៊ីចឹងខ្ញុំក៏បានស្នើទៅការិយាល័យរបស់លោកសំណើសុំឯកសារនេះ ដើម្បីតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយយើងយល់ឃើញថាឯកសារនេះ គឺជាឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យ ហើយការិយាល័យរបស់លោកក៏បានផ្តល់មកឲ្យយើង។

**ស៖** តើ ឌី.ស៊ី.ខេម ត្រូវការពេលវេលាប៉ុន្មានដែរ ដើម្បីប្រមូលឯកសារច្បាប់ដើមទាំងអស់ដែលលោកគិតថាជាឯកសារដែលកើតឡើងនៅសម័យកម្ពុជាប្រជាធិបតេយ្យ ហើយនិងនាំយកមកកាន់ទីនេះនៅសាលសវនាការនៅចំពោះមុខតុលាការនេះ?

**ឆ៖** សូមជម្រាបថា ការប្រមូលឯកសារនៅតែបន្ត និងបន្តទៅទៀត ពីព្រោះឃ្លាដែលយើងនិយាយអំពីពាក្យថា ឯកសារ យើងមិនមែនសំដៅទៅលើក្រដាស យើងមិនមែនសំដៅទៅវត្ថុតាង យើងមិនមែនសំដៅទៅត្រឹមតែរូបថត ឬក៏ខ្សែភាពយន្តទេ។ មនុស្សក៏ជាឯកសារដែរ លោកត្រូវដឹងថា អ្នកដែលរស់រានមានជីវិតពីសម័យខ្មែរក្រហមនៅរស់រានមានជីវិតរាប់លាននាក់ ដែលយើងត្រូវការបន្តសាកសួរគាត់ ដើម្បីឲ្យរឿងរ៉ាវរបស់គាត់នេះត្រូវបានទុកសម្រាប់កូនខ្មែរជំនាន់ក្រោយបានដឹង។ អ៊ីចឹងបើសិនជាលោកសួរថា តើត្រូវការរយៈពេលប៉ុន្មានទៀត គឺជាអចិន្ត្រៃយ៍ ដើម្បីទប់ស្កាត់អំពើនេះ គឺត្រូវមានកន្លែងមួយជាអចិន្ត្រៃយ៍ ហើយបន្តសាកសួរអ្នកដែលរស់រានមានជីវិតទាំងអស់។ ព្រោះរឿងនេះជារឿងរ៉ាវប្រវត្តិសាស្ត្រ ហើយមនុស្សទាំងអស់គឺជាឯកសាររស់។ មិនមែនតែក្រដាសទេ ដែលជាឯកសារ មនុស្សក៏ជាឯកសារដែរ។

[១០:០៦:៥៧]

អ៊ីចឹងនៅក្នុងស្រុកខ្មែរយើងនេះ ទោះបីជាមានយុវជន យុវនារីកើតក្រោយរបប៧៩ មានរហូតដល់ទៅ៦៥ភាគរយយ៉ាងណាក៏ដោយ ៣៥ភាគរយទៀត គឺជាមនុស្សដែលធ្លាប់បានឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ។ ហើយចាំបាច់ណាស់ រឿងរ៉ាវរបស់គាត់ត្រូវបានកត់ត្រាទុក ដើម្បីឲ្យយើងបានរៀនសូត្រទាំងអស់គ្នា ការពាររបបនេះ កុំឲ្យកើតឡើងម្តងទៀត។

[១០:០៧:២៦]

**ស៖** បាទ ចម្លើយរបស់លោកនេះល្អណាស់។ គឺហើយ វាជាសកម្មភាពដ៏ប្រសើរថ្លៃថ្លារបស់លោក-- នៃមជ្ឈមណ្ឌលរបស់លោក ប៉ុន្តែយើងស្ថិតនៅក្នុងបរិវេណតុលាការ ហើយយើងវិធានផ្តុយពីអ្វីដែលលោកអនុវត្តនៅកន្លែងរបស់លោក ខ្ញុំចង់ឲ្យលោកឆ្លើយទៅនឹងសំណួររបស់ខ្ញុំម្តងទៀត។ ខ្ញុំសួរម្តងទៀត តើខាងលោកត្រូវការពេលវេលាប៉ុន្មានដើម្បីទៅប្រមូលឯកសារច្បាប់ដើមដែលលោកគិតថាវាធ្វើឡើងនៅសម័យកម្ពុជាប្រជាធិបតេយ្យ? ពីព្រោះលោកបាននិយាយថា ត្រូវបានរក្សាទុកនៅកន្លែងសម្ងាត់នៅក្នុងប្រទេសកម្ពុជា។ ហេតុដូច្នេះ នៅពេលដែល ទៅពេលដែលលោកទៅយកឯកសារនោះ ហើយនិងនាំចូលឯកសារមកនៅតុលាការនេះ។ ខ្ញុំនិយាយតែអំពីឯកសារក្រដាសទេ ខ្ញុំមិននិយាយពីមនុស្សទេ។ គឺខ្ញុំនិយាយសំដៅទៅដល់ឯកសារដែលលោកគិតថា វាត្រូវបានធ្វើឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ?

[១០:០៨:២៨]

**ឆ៖** ចំពោះឯកសារក្រដាសនេះ យើងកំពុងធ្វើការជាមួយនឹងសាកលវិទ្យាល័យ មីឈីហ្គេន នៅក្នុងមហាវិទ្យាល័យគោលនយោបាយជាតិប្រធានាធិបតី ចឺរ៉ាហ្វត គឺយើងកំពុងតែស្កេន *ឌីជីថាហ្មៀរ* វាគ្រប់ឯកសារទាំងអស់ ដើម្បីដាក់នៅលើ បង្ហោះនៅក្នុងគេហទំព័រ ដែលពិភពលោកទាំងអស់ មនុស្សម្នាក់ៗអាចមានឯកសារទាំងស្រុងចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ មូលហេតុដែលយើងការពារសុវត្ថិភាពឯកសារដើម ពីព្រោះយើងមិនទាន់មានកន្លែងទីតាំងពិតប្រាកដ ហើយទីមួយទៀតយើងមិនត្រូវឲ្យឯកសារដើមចេញពីប្រទេសកម្ពុជាទេ។ វាគឺជាសម្បត្តិរបស់ប្រទេសកម្ពុជា។ អ៊ីចឹងបើសិនជាលោករង់ចាំពីរបីឆ្នាំទៀត ឯកសារទាំងឡាយដែលខ្ញុំបានប្រមូលមកជាឯកសារដើម លោកអាចឃើញៗនៅក្នុងគេហទំព័រ លោកនៅទីណាក៏អាចទទួលបានដែរ។ តាមពិតទៅ យើងចង់ធ្វើបញ្ហានេះយូរមកហើយ ប៉ុន្តែដោយសារមានការខ្វះធនធាន និងពេលវេលា យើងធ្វើមិនទាន់។ អ៊ីចឹងសព្វថ្ងៃនេះ យើងកំពុងតែបន្ត *ឌីជីថាយ* ស្កេន ឯកសារទាំងអស់នេះដាក់នៅលើគេហទំព័រទាំងអស់ ទាំងស្រុងតែម្តង។ អ៊ីចឹងគ្រប់គ្នានៅក្នុងពិភពលោក អាចឃើញការពិត យកឯកសារទាំងអស់នេះទៅពិចារណាទាំងអស់គ្នា។ តើហេតុដូចម្តេចបានជារបបនេះ ធ្វើឲ្យមនុស្សពីរលាននាក់ស្លាប់បាត់បង់ជីវិត។

[១០:០៩:៣៨]

**ប្រធានអង្គជំនុំ៖**

លោកសាក្សី សូមសម្រួលអារម្មណ៍ ហើយចាំស្តាប់នូវសំណួរឲ្យបានច្បាស់លាស់អំពីអ្នកសួរ ហើយក្នុងករណីលោកសួរ ស្តាប់សំណួរមិនយល់ លោកអាចរំឭកសុំឲ្យគាត់សួរម្តងទៀត ឬក៏សុំយើងដើម្បីឲ្យយើងប្រាប់គាត់ ដើម្បីឲ្យសួរ តាំងសំណួរនោះជាថ្មីម្តងទៀត ដើម្បីឲ្យច្បាស់។ ហើយកាលណាយើង លោកយល់អំពីខ្លឹមសារនៃសំណួរហើយ គឺលោកអាចឆ្លើយតបនៅក្នុងកម្រិតនៃសំណួរដែលសួរបានហើយ ចៀសវាងអត្ថាធិប្បាយវែងហួសចេញផុតពីសំណួរដែលគោលបំណងនៃការសួរតាំងសំណួរនោះ។ បើច្រឡំ-- មិនច្រឡំទេ សំណួរអម្បាញ់មិញនេះ គឺលោកឆ្លើយអំមិញនេះគឺមិនឆ្លើយតបទៅនឹងសំណួរដែលមេធាវីសួរទេ។ លោកមេធាវីអាចសួរសំណួរអំមិញម្តងទៀត ដើម្បីឲ្យគាត់ឆ្លើយច្បាស់ពីព្រោះគិតមិនស្តាប់សំណួរប្រហែលជាមានការភ័ន្តច្រឡំអំពីសំណួរ។

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** ព្រឹកនេះលោកបានបញ្ជាក់ជូនខ្ញុំ និងតុលាការថាឯកសារច្បាប់ដើម ដែលធ្វើឡើងនៅសម័យកម្ពុជាប្រជាធិបតេយ្យ ហើយដែលខាង ឌី.ស៊ី.ខេម រក្សាទុក គឺថាត្រូវបានរក្សាទុកនៅកន្លែង

សម្ងាត់នៅប្រទេសកម្ពុជា។ សំណួររបស់ខ្ញុំគឺដូចតទៅនេះ៖

តើលោកអាចនាំយកឯកសារច្បាប់ដើមទាំងមកទីនេះបានដែរឬទេ? ហើយថាតើលោកត្រូវការពេលវេលាប៉ុន្មានសម្រាប់នាំឯកសារច្បាប់ដើមទាំងអស់នោះមកកាន់តុលាការ?

[១០:១១:៣៧]

**លោក ឆាំង យុ៖**

លោកចៅក្រមតាមដែលខ្ញុំយល់គាត់ចង់ឲ្យខ្ញុំយកឯកសារដើមមកតុលាការ តើជាការត្រឹមត្រូវ? បើសិនជាមានការសំណូមពរពីតុលាការ ខ្ញុំយកជូនបាន ពេលណាក៏បាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា។ សំណួរនេះគឺថាដូចជាមិនពាក់ព័ន្ធទេ។ សំណួរនេះ ជាសំណួរបច្ចេកទេស ហើយសំណួរនេះគឺត្រូវតែសួរដោយអង្គជំនុំជម្រះ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា ឌី.ស៊ី.ខេម ត្រូវតែនាំឯកសារមួយ ឬក៏ដប់ ឬក៏ ១លាននៃច្បាប់ដើមមកកាន់ទីនេះ។ ដូច្នេះសំណួរនេះ គឺសំណួរបច្ចេកទេស ហើយជាសំណួរដែលត្រូវចោទសួរដោយអង្គជំនុំជម្រះ នេះជាគោលជំហររបស់ខាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណ។

[១០:១២:៣៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្តី នួន ជា!

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន។ សូមឆ្លើយតបទៅនឹងមេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណី សំណួររបស់លោកមេធាវីរបស់លោក ខៀវ សំផន ខ្ញុំបានស្នើទៅព្រះរាជអាជ្ញាតាំងពីមុនដំបូង។ ជាពិសេសចំពោះទង់បដិវត្តដែលលោក នួន ជា ផ្ទាល់ខ្លួនគាត់កំពុងអង្គុយកន្លែងនេះ ហើយគាត់សុំឲ្យបង្ហាញឯកសារដើម រហូតដល់សួរហើយសួរទៀតនៅលើទង់បដិវត្ត ហុចមកហើយគាត់មើលឯកសារហ្នឹងគាត់គ្រវាត់ចោលទៅទៀតថា ឯកសារដើមមកបញ្ជាក់ផ្ទៀងផ្ទាត់ដើម្បីគាត់ទទួលស្គាល់។ ម្ល៉ោះហើយខ្ញុំមិនទាន់បាននិយាយ មិនមែនតួនាទីរបស់ខ្ញុំ ប៉ុន្តែថ្ងៃនេះខ្ញុំគ្រាន់តែសុំបញ្ជាក់ថា បានសុំរួចទៅហើយ

ឯកសារទង់បដិវត្ត។ សូមអរគុណ។

[១០:១៣:៥៦]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅសហព្រះរាជអាជ្ញា? លោកចង់និយាយអ្វីទៅឥឡូវនេះ? លោកអាចរៀបចំនូវស្ថានភាព ឬក៏លំដាប់លំដោយនៃការជំទាស់តវ៉ាបានដែរឬទេ រវាងភាគីទាំងសងខាង លោកគួរតែត្រូវបានប្រព្រឹត្តឡើងព្រមគ្នា ឬក៏លំដាប់ជាមួយគ្នា ជាមួយនឹងក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលជាភាគីម្ខាងជាមួយនឹងសហព្រះរាជអាជ្ញា។ ហើយចំណែកឯភាគីម្ខាងទៀតគឺមេធាវីការពារក្ដី ប្រសិនបើលោកម្ដងម្នាក់ៗដូច្នេះ អាចមួយព្រឹកនេះ គ្រាន់តែងើបឡើងហើយអង្គុយចុះហ្នឹងប្រហែលជាអាចអស់ម៉ោងហើយ។ លោកអាចរៀបរយនូវបញ្ហានេះសាជាថ្មីឡើងវិញ ដើម្បីឲ្យការជំទាស់ ឬក៏ការលើកឡើងនូវបញ្ហានានាហ្នឹងឲ្យមានស្ថានភាពមួយ គឺតែម្ដងទេ។ ដើម្បីប្រើប្រាស់ពេលវេលានៅក្នុងគោលការណ៍នៃការប្រព្រឹត្តទៅជំនុំជម្រះដោយឆាប់រហ័ស និងយុត្តិធម៌។

សូមអញ្ជើញ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១០:១៥:៣៥]

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ គឺខ្ញុំស្ទាក់ស្ទើរក្នុងការឆ្លើយតប ក៏ប៉ុន្តែខ្ញុំគិតថា គួរតែឆ្លើយតបដោយសារតែមេធាវី នួន ជា លើកឡើងបញ្ហាដែលអង្គជំនុំជម្រះបានបង្គាប់ចេញសេចក្ដីសម្រេចរួចមកហើយ ដែលអង្គជំនុំជម្រះលើកឡើងថា ឯកសារដើមនោះគឺមិនទាមទារយកមកបង្ហាញនៅក្នុងនេះ--នៅក្នុងទីនេះនោះទេ។ ដូច្នេះហើយគ្រាន់តែខ្ញុំចង់ឲ្យអង្គជំនុំជម្រះរំឭកទៅដល់ខាងមេធាវីការពារក្ដីលោក នួន ជា វិញ។ សូមអរគុណ។

[១០:១៦:០៩]

**ប្រធានអង្គជំនុំ៖**

យើងបានកាន់រួចហើយនូវសេចក្ដីសម្រេចនេះ។ អ៊ីចឹងសូមឲ្យភាគីមើលសេចក្ដីសម្រេចផ្ទាល់មាត់ ស្ដីពីបញ្ហាឯកសារដែលអង្គជំនុំជម្រះបានប្រកាសនៅរសៀលថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ វេលាម៉ោងដប់មួយព្រឹក។ មើលប្រតិចារឹកឡើងវិញអំពីបញ្ហានេះ ហើយមិនអនុញ្ញាតឲ្យលើកបញ្ហានេះដដែលៗទេ ដោយបញ្ហាបានដោះស្រាយមួយជំហានហើយលើបញ្ហានេះ។ សូមអញ្ជើញ!

**លោក អាកទ្វរ វែកកែន៖**

លោកប្រធាន ខ្ញុំបានសុំឱ្យសាក្សី ថាតើជាលក្ខណៈបច្ចេកទេស វាមានការលំបាកយ៉ាងណាចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយថាគាត់ត្រូវការពេលវេលាប៉ុន្មាន ដើម្បីឱ្យគាត់នាំយកឯកសារដែលគាត់យល់ឃើញថាជាឯកសារនៅសម័យកម្ពុជាប្រជាធិបតេយ្យ ដើម្បីនាំមកតុលាការនេះ។ ដូច្នេះខ្ញុំគិតថា ខ្ញុំមិនបានច្រឡំគ្នាចំពោះសេចក្ដីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះនោះទេ។

**លោក ឆាំង យុ៖**

សូមគោរពលោកចៅក្រម ចំពោះបច្ចេកទេសដឹកជញ្ជូន ប្រសិនជាមានការស្នើសុំពីអង្គជំនុំជម្រះនេះ យើងអាចថាត្រូវការរយៈពេលយ៉ាងហោចណាស់ក៏មួយខែ ដោយសារថាឯកសារនេះ វាមានភាព--ខ្ញុំនេះជាការប៉ាន់ប្រមាណ យើងនឹងពិនិត្យទៅលើបញ្ហានេះទៀត ពីព្រោះជាទូទៅយើងមិនដែលបានធ្លាប់ដឹកចេញឯកសារដើមនេះទៅកាន់ទីណាមួយនៅឡើយទេ នៅពេលក្រោយពេលដែលយើងបានទទួលឯកសារនេះ។ ប៉ុន្តែបើសិនជាមានការស្នើសុំពីអង្គជំនុំជម្រះ ខ្ញុំបាទរីករាយនឹងពិភាក្សាជាមួយនឹងក្រុមបច្ចេកទេសរបស់តុលាការ ដើម្បីធ្វើយ៉ាងណាធានាបាននូវសុវត្ថិភាព។ ដឹកគ្រប់ឯកសារទាំងអស់បញ្ជូនឱ្យតុលាការតាមសំណើគ្រប់ពេលវេលា។

[១០:១៨:៣០]

បើសិនជាលោកចៅក្រមអនុញ្ញាត ហើយខ្ញុំចង់បញ្ជាក់ថាបើសិនជា អ៊ំ នួន គាត់ចង់បានទង់បដិវត្តនោះ ឯកសារដើម ខ្ញុំសូមប្រគល់គាត់ ផ្ញើគាត់ជូនជាឯកជន បើសិនជាគាត់ចង់បាន ដើម្បីឱ្យគាត់ឱ្យអស់ចិត្ត។ បើសិនជាគាត់ចង់បាន ព្រោះខ្ញុំមានច្រើនណាស់ ឯកសារនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកសាក្សី។ សូមអញ្ជើញតាំងសំណួរផ្សេងទៀត!

**លោក អាកទ្វរ វែកកែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីជាតិការពារក្ដីឱ្យលោក ខៀវ សំផន ទំនងមានសំណួរច្រើនទេ?

**លោក គង់ សំអុន៖**

ខ្ញុំបាទមានសំណួរ ប៉ុន្តែដោយសារពេលវេលាអាចដល់ពេលសម្រាក តើសុំអាចសម្រាកសិនបាន

ទេ លោកប្រធាន?

[១០:១៩:៣០]

**ប្រធានអង្គជំនុំ៖**

បាទ យើងសួរលោកហ្នឹង គឺដើម្បីគណនាពេលវេលា ប៉ាន់ស្មានពេលវេលាហ្នឹងឯង។ បើសិនជាលោកមានចំនួនច្រើន អាចចំណាយពេលវេលាច្រើន នោះនឹងយើងនឹងប្រកាសសម្រាក។ ឥឡូវនេះដោយសារមេធាវីក៏មិនបង្ហាញលក្ខណៈច្បាស់លាស់ដែរ ហើយពេលវេលាសមល្មមនឹងសម្រាកផងអង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះ។ ហើយចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការជួយសម្របសម្រួល ផ្តល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់ចម្លើយនៅក្នុងបន្ទប់សវនាការនេះឲ្យបានមុនម៉ោង មុនពេលដែលអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សូមអញ្ជើញ លោកមេធាវី!

[១០:២០:២៣]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមអរគុណ។ ដោយសារបញ្ហាសុខភាព និងជាពិសេសបញ្ហាឈឺចង្កេះឆ្អឹងខ្នង លោក អៀង សារី មិនអាចទ្រាំអង្គុយនៅទីនេះយូរបានទៀត លោកស្នើសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការផ្ទាល់នៅថ្ងៃនេះ។ ប៉ុន្តែ សូមចូលរួមសវនាការនេះដោយប្រយោលនៅបន្ទប់រង់ចាំខាងក្រោមសម្រាប់រយៈពេលពេញមួយថ្ងៃនេះ។ អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់លោកជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិមិនចូលរួមកិច្ច-- តាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយសុំដកខ្លួនថយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោម តាមរយៈមធ្យោបាយឧបករណ៍សោតទស្សន៍។ អង្គជំនុំជម្រះយល់ព្រមអនុញ្ញាតតាមសំណើនេះ ហើយដោយតម្រូវឲ្យក្រុមមេធាវីការពារក្តី ផ្តល់នូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមរបស់ជនជាប់ចោទរូបនេះ ដោយមានចុះ

ហត្ថលេខា ឬស្នាមផ្តិតម្រាមដៃយ៉ាងច្បាស់លាស់ពីជនជាប់ចោទ។ ហើយនិងបង្គាប់ឲ្យខាងផ្នែកសោតទស្សន៍តភ្ជាប់ប្រព័ន្ធរូបភាព និងសំឡេងទៅបន្ទប់ខាងក្រោមសម្រាប់ជនជាប់ចោទរូបនេះ ដើម្បីបន្តការតាមដានកិច្ចដំណើរការសវនាការនៅក្នុងអំឡុងពេលសវនាការដេញដោលសម្រាប់ថ្ងៃនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនគាត់ទៅកាន់បន្ទប់ខាងក្រោមចុះ!

អង្គជំនុំជម្រះសម្រាកត្រឹមនេះ ហើយអញ្ជើញសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:២២នាទី ដល់ម៉ោង ១០:៤៤នាទី)*

[១០:៤៤:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ជាបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅមេធាវីជាតិការពារក្តីឲ្យលោក ខៀវ សំផន ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរចំពោះសាក្សី ផាំង យុ។ សូមអញ្ជើញមេធាវី!

**សួរដោយលោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការ។

**ស៖** សូមជម្រាបសួរលោក ផាំង យុ។ ខ្ញុំបាទជាមេធាវីរបស់លោក ខៀវ សំផន ឈ្មោះ គង់ សំអុន ហើយខ្ញុំបាទនឹងតាំងសំណួរមួយចំនួនចំពោះលោក។ ខ្ញុំសង្ឃឹមថា លោកនឹងឆ្លើយតបមកខ្ញុំវិញដោយស្មោះសរបាទ។ ជាបឋម ខ្ញុំសូមសួរបញ្ជាក់ពីលោកថា តាមការស្តាប់ពីម្សិលមិញ លោកមិនបានសិក្សាអំពីជំនាញ ទាក់ទងទៅនឹងការឆ្លើយថាភាពទេមែនទេ?

**ឆ៖** អត់ទេបាទ។

**ស៖** បាទ សូមអរគុណ។ ហើយនៅក្នុងក្រុម នៃអង្គការ ឌី.ស៊ី.ខេម របស់លោកនោះ ក៏មិនមានអ្នកជំនាញ ដែលធ្វើកិច្ចការទៅលើការផ្តល់យថាភាពនោះដែរ។ អ៊ីចឹងមែនទេ?

[១០:៤៦:១៧]

**ឆ៖** យើងធ្វើសហការជាមួយនឹងបណ្ណសារដ្ឋានជាតិ ដែលមានជំនាញក្នុងការបញ្ជាក់អំពីយថាភាពនៃឯកសារ។

**សៈ** បាទ ប៉ុន្តែក្នុងក្រុមរបស់លោក នៅក្នុងអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា មិនមានក្រុមជំនាញទាក់ទងទៅនឹងការធ្វើយថាភាពនេះទេ។ លោកទទួលស្គាល់អ៊ីចឹងទេ?

**ឆៈ** ក្រុមជំនាញ?

**សៈ** បាទ ជាអ្នកជំនាញ ជា*ប្រូចិច* ឬក៏ជា*ធីម* ណាមួយដែលលោកគិតថា ធ្វើតែទៅលើកិច្ចការផ្តល់នូវយថាភាពនេះ?

**ឆៈ** មិនមានទេ ដោយសារថានៅក្នុងក្រុមឯកសាររបស់យើងនេះ យើងបានធ្វើរួមតែម្តង *(ឮមិនច្បាស់)* ។

**សៈ** បាទ អរគុណ។ សូមអរគុណលោក។ អ៊ីចឹងបានន័យថា ខ្ញុំសូមបញ្ជាក់ឡើងវិញថា លោកអត់មានអ្នកជំនាញក្នុងការធ្វើយថាភាពនេះទេ?

**ឆៈ** អត់ទេបាទ។

[១០:៤៧:០៦]

**សៈ** បាទ សូមអរគុណ។ ហើយនៅក្នុងអង្គការរបស់លោកនោះ ក៏មិនមានជាគោលការណ៍លាយលក្ខណ៍អក្សរ អំពីការធ្វើយថាភាពនេះដែរ។ តើអ៊ីចឹងមែនទេ?

**ឆៈ** យើងមានបាទ។ យើងមានភាសាអង់គ្លេសហៅថា *ឆេន អូហ្វ ខស្តូឌី* យើងមានជាបួនចំណុច នៅក្នុងពេលដែលយើងបានទទួលឯកសារមួយៗ យើងត្រូវសួរ។ បាទ ជាទូទៅអ្នកផ្តល់ឯកសារខ្លះ គាត់មិនចង់រវីរវល់ទេពីរឿងតុលាការ គាត់ថាយកឯកសារទៅជាប្រវត្តិសាស្ត្រ យកទៅប្រើយ៉ាងម៉េចប្រើចុះ។ អ៊ីចឹង ជាទូទៅ យើងបានមានជាកម្រងសំណួរបួន បាទ បួនចំណុច ដែលនិយាយអំពីថាយកឯកសារមកត្រូវសួរថា អ្នកណាឈ្មោះអី? នៅកន្លែងណា? យកមកពីកន្លែងណា? អ្នកណាខ្លះបានទទួលឯកសារនោះពីមុនមក? ដូចជម្រាបលោកពីលើកមុនអ៊ីចឹង យើងមិនបានធ្វើជាលាយលក្ខណ៍អក្សរទេ ប៉ុន្តែយើងបានដាក់បញ្ចូលទៅក្នុងផ្នែកមួយនៅក្នុង*វ៉ើកស៊ីត* របស់យើងអំពីប្រភពឯកសារ ហើយយើងអាចឆ្លើយជូនបាន បើសិនជាលោកត្រូវការព័ត៌មានបន្ថែម។ អ៊ីចឹង យើងមានៗជាលាយលក្ខណ៍អក្សរជាគោលការណ៍។

[១០:៤៨:១១]

**សៈ** បាទ អំមិញលោកមានប្រសាសន៍ថាមានជាលាយលក្ខណ៍អក្សរអ៊ីចឹងណ៎ា គោលការណ៍ទាក់ទងទៅនឹងគេហៅថាការ--

**ឆ៖** សួរសំណួរ។

**ស៖** --ចង្វាក់នៃការសួរសំណួរ។

**ឆ៖** បាទៗ។

**ស៖** ប៉ុន្តែមិនមានគោលការណ៍ ទាក់ទងទៅនឹងការឆ្លើយថាភាពទេ?

**ឆ៖** ខ្ញុំពិបាកយល់សំណួរហ្នឹងបន្តិចបាទ?

**ស៖** យថាភាព--

[១០:៤៨:៣០]

**ប្រធានអង្គជំនុំ៖**

ទាំងសហមេធាវីជាតិការពារក្តីលោក ខៀវ សំផន ទាំងសាក្សី សូមបង្អង់បង្អាក់បន្តិចមុននឹងឆ្លើយដោយសារការបកប្រែទៅជាភាសាបរទេសហ្នឹង គឺវាដាច់បកអត់ទាន់ទេ អ៊ីចឹងវាកិច្ចសន្ទនាហ្នឹងគឺភាគីពាក់ព័ន្ធផ្សេងទៀត ទាំងអង្គជំនុំជម្រះផងដែលប្រើប្រាស់ភាសាអង់គ្លេស និងបារាំងហ្នឹងគឺ ទទួលព័ត៌មានអត់បានល្អទេ។

**សួរដោយលោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**ឆ៖** ខ្ញុំឆ្លើយតប?

**ស៖** បាទ សូមអញ្ជើញ។

**ឆ៖** ខ្ញុំចង់និយាយថា នៅពេលឯកសារចូលមក គឺយើងមានកម្រងសំណួរ បាទ របៀបជាគោលការណ៍ ជាការណែនាំថាតើបើសិនជាឯកសារយកមក យើងត្រូវសួរគាត់ គាត់ឈ្មោះអី? ទីលំនៅនៅកន្លែងណា? ទូរស័ព្ទលេខប៉ុន្មាន? អ្នកណាឲ្យគាត់? គាត់រកឃើញនៅកន្លែងណា? យើងមានឯកសារទាំងអស់នេះបាទ។

[១០:៤៩:២៥]

**ស៖** សូមអរគុណ។ អ៊ីចឹងសួរថា គោលការណ៍ដែលលោកនិយាយថា មានជាលាយលក្ខណ៍អក្សរនេះ វាជាគោលការណ៍ចំពោះការតាំងសំណួរ ឬក៏ជាគោលការណ៍ដែលបញ្ជាក់អំពី ឧទាហរណ៍ទៅលើដែលលោកមានប្រសាសន៍ទៅលើពណ៌ នៃឯកសារជាក្រដាសសៀវភៅ ឬក៏ជាអីអ៊ីចឹង ឬមួយក៏ជាប្រភេទជាសំណួរ?

**ឆ៖** ជាសំណួរណែនាំដើម្បីឲ្យបុគ្គលម្នាក់ យល់រូបភាពធំថាតើគួរសួរអ្វីខ្លះ ដោយមូលហេតុថា អ្នកផ្តល់ឯកសារខ្លះ មិនមានចេតនា ឬក៏មិនចង់ត្រូវបានសួរដោយ គាត់យល់ឃើញថា នេះជាឯកសារប្រវត្តិសាស្ត្រ គាត់ប្រគល់មកឲ្យយើង។ អ៊ីចឹង នៅក្នុងកម្រងសំណួរទាំងបួនចំណុចនេះ យើងអាចសួរពីរ ឬក៏បី ឬក៏បួន ប៉ុន្តែយើងមានជារូបភាពធំ ថាដើម្បីលម្អិតមួយសម្រាប់ឲ្យដំណើរការនេះវាជាក់លាក់មួយ ជនម្នាក់ដែលចង់ឲ្យត្រូវបានសួរជាលម្អិត គឺយើងមានកម្រងសំណួរ មានបួនចំណុចទាំងអស់។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង នៅពេលដែលលោកសួរសំណួរទៅចំពោះអ្នកដែលផ្តល់ឯកសារមកឲ្យលោកនោះ គឺលោកសួរជាលក្ខណៈរួម អ៊ីចឹងមែនទេ? មិនមែនសួរទៅលើឯកសារនីមួយៗទេ។

**ឆ៖** ខ្ញុំជូនឧទាហរណ៍មួយ ដើម្បីឲ្យស្រួលស្តាប់។ មានលោកម្នាក់ឈ្មោះ ខៀវ កូឡា គាត់មិនមែន ខៀវ កូឡា ធ្វើការនៅ ស៊ី.ធី.អ៊ិន ទេ គាត់ជាមន្ត្រីចូលនិវត្តន៍ ហើយគាត់បានឃើញការផ្សព្វផ្សាយនៅក្នុងទូរទស្សន៍នៅកន្លែងផ្សេងៗ គាត់ក៏ទូរស័ព្ទមកខ្ញុំ។ គាត់ថា គាត់មានរូបថតខ្មែរក្រហម គាត់ចង់យកមកឲ្យខ្ញុំ។ អ៊ីចឹង គាត់ក៏យកមកឲ្យខ្ញុំ ហើយរូបថតនេះ ខ្ញុំបានបោះផ្សាយនៅក្នុងសៀវភៅមួយដែលមានចំណងជើងថា *"អន ត្រាល"* ជារូបថតរបស់គាត់។ អ៊ីចឹង នៅពេលដែលខ្ញុំជួបគាត់ គាត់ថា យកឯកសារទៅប្រើចុះ គឺគាត់ចង់ចូលរួមចំណែកក្នុងការប្រមូលឯកសារប្រវត្តិសាស្ត្រ។

អ៊ីចឹង ជាទូទៅ នៅក្នុងគាត់ហ្នឹង គាត់ចង់ឆ្លើយតែប៉ុណ្ណឹង។ ប៉ុន្តែខ្ញុំមានអាសយដ្ឋានគាត់ ទូរស័ព្ទគាត់ ហើយជាទូទៅនៅក្នុងករណីណាដែលអ្នកផ្តល់ឯកសាររបៀបនេះ មិនចង់និយាយច្រើន ខ្ញុំតែងតែផ្តល់រូបថតនេះ ទៅឲ្យសារព័ត៌មាន ដើម្បីបង្ហាញ ដើម្បីយកជាចំណុចមួយ យកជាព័ត៌មានមួយដើម្បីបញ្ជាក់ថាព័ត៌មាននេះ ឯកសារនេះត្រូវបានផ្តល់មកមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបើកចំហជូនជាសាធារណៈ។

[១០:៥១:៤៥]

ឧទាហរណ៍ទីពីរ គឺរូបថត ខ្ញុំបានមកពីប្រទេសជប៉ុន។ មានមន្ត្រីបុគ្គលិកស្ថានទូតខ្មែរយើងម្នាក់ធ្វើការនៅប្រទេសជប៉ុនហ្នឹង បានរកឃើញរូបថតឯកសារសេសសល់នៅក្នុងឃ្លាំង ហើយគាត់-- ខ្ញុំចាំបានថា ពេលនោះ ពេលបុណ្យអុំទូក។ គាត់ក៏បានអ៊ីម៉ែលប្រាប់ខ្ញុំថា គាត់មានរូបថតជាច្រើន ដែលគាត់រកឃើញនៅក្នុងអតីតស្ថានទូតខ្មែរនៅប្រទេសជប៉ុន តើលោក-- ខ្ញុំត្រូវការដែរឬក៏អត់? ខ្ញុំថា យកមក។ ពេលដែលគាត់យកមក គាត់ថាខ្ញុំជា មិនចង់បានអីទេ គ្រាន់តែថាចូលរួមចំណែកក្នុងការកសាងជាតិនេះ ខ្ញុំជូនឯកសារទៅលោក។ អ៊ីចឹង ខ្ញុំក៏បានផ្តល់ព័ត៌មាននេះ ឲ្យកាសែតឌេលី ជាឧទាហរណ៍ ដាកក្លាស

ហ្គៀលសិន ដែលជាទូទៅប្រើប្រាស់រូបថតនេះផ្សព្វផ្សាយ ហើយខ្ញុំយកព័ត៌មាននេះជាសំអាងមួយ ថាឈ្មោះនេះ ជាទូទៅអ្នកកាសែតសម្គាសអ្នកដែលបានផ្ដល់ឯកសារ។ អ៊ីចឹង ខ្ញុំប្រើវិធីផ្សេងៗដើម្បីបញ្ជាក់ឲ្យដឹងថា ឯកសារទាំងអស់នេះមកពីកន្លែងណា។ នៅក្នុងពេលជាមួយគ្នាហ្នឹងដែរ ខ្ញុំមានជាគោលកម្រងសំណួរជារួម ដែលយើងសួរនៅក្នុង ទៅតាមកាលៈទេសៈ និងមនុស្ស ដែលយើងបានទទួលឯកសារពេលហ្នឹង។

[១០:៥៣:០៣]

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញនេះ លោកមានប្រសាសន៍ថា លោកលើកឧទាហរណ៍ពីរ ទាក់ទងទៅនឹងរូបថតដែលបានពីស្ថានទូត ហើយនិងបានពីឈ្មោះ កូឡា ណ៎ា ខៀវ កូឡា បាទ។ តើលោកបានសួរសំណួរថា ថាតើលោក ខៀវ កូឡា និងស្ថានទូតខ្មែរនៅប្រទេសជប៉ុនហ្នឹង បានទទួលឯកសារហ្នឹងដោយរបៀបណាពីមុនមក លោកមានបានសួរបញ្ជាក់បន្ថែមអ៊ីចឹងទេ?

**ឆ៖** សូមបញ្ជាក់បន្តិច យើងមិនមែនបានទទួលរូបថតមកស្ថានទូតខ្មែរ នៅប្រទេសជប៉ុនទេ បានមកពីបុគ្គលិក ធ្វើការនៅស្ថានទូតខ្មែរ។ ហើយរូបថតនេះ នៅពេលដែលគាត់សម្អាតការិយាល័យ គាត់ត្រូវបានរកឃើញនៅក្នុងឃ្លាំង ហើយគាត់យកមកឲ្យខ្ញុំ។ ខ្ញុំបានសួរគាត់ បាទ លោក ខៀវ កូឡា ខ្ញុំសួរថា បានរូបថតមកពីណា? ហេតុអីបានមានរូបថតនេះ? ហើយរូបថតនេះ ជាកូល័រទៀត ជាពណ៌ បាទ។ ខ្ញុំចាប់អារម្មណ៍ ព្រោះជាទូទៅរូបថតខ្មែរក្រហមពណ៌ខ្មៅស ប៉ុន្តែរូបថតនេះ ជាពណ៌។ គាត់ថា អង្គាល់ចូលគាត់មកទីក្រុងភ្នំពេញដំបូង ជាទីក្រុងរហោស្ថានគ្មានមនុស្សនៅ ដោយគាត់ដើរចូលពីផ្ទះមួយទៅផ្ទះមួយ រកអាហារ រកអីអ៊ីចឹង។ គាត់ក៏ប្រទះឃើញរូបថតនេះ នៅក្នុង-- តាមដែលខ្ញុំចាំ នៅសព្វថ្ងៃនេះ ជាៗស្ថានទូតសូវៀត។ គាត់បានចូលទៅតំបន់កន្លែងនេះ ហើយឃើញរូបថតនេះ ក៏ទុកមករហូតទល់សព្វថ្ងៃ ហើយក្រោយមក គាត់ក៏យកមកឲ្យខ្ញុំ។

[១០:៥៤:៣៤]

**ស៖** បាទ សូមអរគុណ។ ប៉ុន្តែលោកមានបានសួរជាឧទាហរណ៍នេះ ខ្ញុំគ្រាន់តែ ខ្ញុំអត់វិភាគទៅលើរូបថតអម្បាញ់មិញនេះទេណ៎ា។ ខ្ញុំគ្រាន់តែលើកយកអ្វីដែលជាឧទាហរណ៍របស់លោក ដើម្បីឲ្យលោកជម្រាបជូនក្រុមប្រឹក្សាជំនុំជម្រះណ៎ា ថា-- ឧទាហរណ៍ថាលោក កូឡា គាត់បានទទួលពី-- បានរកឃើញនៅស្ថានទូតសហភាពសូវៀត បាទបច្ចុប្បន្ននេះ។ អ៊ីចឹងលោក កូឡា ហ្នឹងក៏មិនបានដឹងដែរ ថាតើរូបថតដែលៗ ចូលមកក្នុងស្ថានទូតសហភាពសូវៀតហ្នឹងដោយវិធីណា គឺលោកអត់បានដឹងទេ?

អ៊ីចឹងមែនទេ?

**ឆៈ** ត្រឹមត្រូវ បាទ គាត់មិនដឹងទេ។

**សៈ** បាទ សូមអរគុណ។ អ៊ីចឹងបានន័យថាព័ត៌មានដែលលោកទទួលបានពីឯកសារទាំងនោះ វាដាច់នូវចង្វាក់នោះមួយចំនួន បានន័យថាលោកមិនបានព័ត៌មានពេញលេញចាប់ពីឯកសារដែលត្រូវបានផលិត ឬកើតឡើងរហូតបានមកដល់ បានមកដៃលោកនោះថា ខ្សែចង្វាក់នៃការថែរក្សា ឬក៏ទុកដាក់ឯកសារនោះ លោកមិនបានដឹងពេញលេញទេ។ អ៊ីចឹងមែនទេ?

[១១:៥៥:៤២]

**ឆៈ** វាអាស្រ័យទៅលើតាមឯកសារដែរ បើឯកសារខ្លះវាមានច្រើន ឯកសារខ្លះវាមានតិច។ ហើយខ្ញុំបានព្យាយាមតាមរកទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ចំពោះលោក ខៀវ កូឡា មិនដឹងទៅសួរអ្នកណាទៀត ព្រោះគាត់គឺមនុស្សទីមួយដែលបានឃើញរកឯកសារនេះ ហើយបច្ចុប្បន្ននេះ កន្លែងនេះគឺជាអតីត គឺជាកន្លែងស្ពានទូតស្វៀត។ អ៊ីចឹងយើងអស់ជម្រើសត្រឹមលោក ខៀវ កូឡា។ ប៉ុន្តែឯកសារផ្សេងទៀត យើងបានព្យាយាមលើសពីលោក ខៀវ កូឡា ទៅទៀត ដើម្បីធ្វើយ៉ាងណាឲ្យដល់ចំណុចមួយដែលយើងអស់លទ្ធភាព ដើម្បីបញ្ជាក់ថា តើអ្នកណាទៅជាមនុស្សទីមួយនោះ? អ៊ីចឹងវាអាស្រ័យទៅលើឯកសារ ដែលលោកសួរដែរ។ តែឧទាហរណ៍អម្បាញ់មិញនេះ គឺត្រឹមលោក ខៀវ កូឡា។

**សៈ** បាទ សូមអរគុណ។ អំមិញនេះលោក ខ្ញុំសួរលោកអំពីអាមុនៗនេះបន្តិច ខ្ញុំសួរលោកអំពីគោលការណ៍ជាលាយលក្ខណ៍អក្សរចំពោះការឆ្លើយថាភាពទៅលើឯកសារ។ ហើយលោកបានឆ្លើយថាមាន បាទ។ អ៊ីចឹងខ្ញុំសូមឲ្យលោកជួយជម្រាបទៅក្រុមប្រឹក្សាជំនុំជម្រះថា តើគោលការណ៍អ្វីខ្លះដែលលោកថាមានជាលាយលក្ខណ៍អក្សរនោះ បាទ?

[១០:៥៦:៥៤]

**ឆៈ** ខ្ញុំអាចឲ្យការិយាល័យផ្ញើមកឲ្យមួយសន្លឹកក៏បាន បើសិនជាលោកចាំបាច់ ព្រោះវាច្រើនសំណួរ យើងព្យាយាមលម្អិតដែលអាចធ្វើទៅបាន។ បើសិនជាលោកចៅក្រមអនុញ្ញាត ប៉ុន្តែគ្រាន់ខ្ញុំចាំគោលការណ៍ថា ទីមួយ សួរអំពីថា ឯកសារបានមកពីណា? អ្នកដែលឲ្យយើងឈ្មោះអី? អាសយដ្ឋាននៅកន្លែងណា? បើយើងចង់ទាក់ទងទៅអាចបានដែរក៏អត់? រកឃើញរូបថតពីពេលណា? ឬក៏គាត់បានមកពីអ្នកណា? មានចំនួនប៉ុន្មាន? យើងរាប់ចំនួនប៉ុន្មាន យើងយក-- បន្ទាប់ពីរាប់ចំនួនហើយ តើ

គាត់-- យើងមានឯកសារអីផ្សេងៗទៀត ដើម្បីគាំទ្របញ្ជាក់ថាគាត់ជាអ្នកយកមកឱ្យយើងដែរឬក៏អត់? បាទ មានច្រើនសំណួរនៅក្នុងចំណុចនីមួយៗ តាមដែលខ្ញុំចាំ មានរហូតទៅដល់ប្រាំពីរ ឬក៏ប្រាំបីសំណួរ។ ហើយសំណួរនេះ គឺត្រូវបានធ្វើឡើងដោយសាស្ត្រាចារ្យច្បាប់ អេលីហ្សាបេ៊ត វ៉ាន់ស្កាក់។ គាត់សព្វថ្ងៃជាសាស្ត្រាចារ្យបង្រៀននៅសាលាច្បាប់ នៅរដ្ឋកាលីហ្វ័រញ៉ា ឈ្មោះសាលាសាន់តាក្លារ៉ា ហើយគាត់បច្ចុប្បន្ននេះ ត្រូវបានៗជ្រើសរើសឱ្យធ្វើទៅជាអនុ ភារធារីគោចរនៃ *អំបាសាឌ័រ វរក្រោម អ៊ែត ឡូ*--

[១០:៥៨:០៩]

**ស៖** បាទ ខ្ញុំសុំកាត់លោក ហើយសូមអរគុណ។ ខ្ញុំជឿថាក្រុមប្រឹក្សាជំនុំជម្រះប្រហែលជាមិនចង់ដឹងថាលោក ដែលលោកមានប្រសាសន៍អម្បាញ់មិញនេះ ពាក់ព័ន្ធយ៉ាងម៉េចទេ។ ដូច្នេះសូមលោកបាទ សូមអរគុណតែប៉ុណ្ណឹងចុះ។

**ឆ៖** បាទ នេះជាខ្សែចង្វាក់ លោកត្រូវដឹងមនុស្សហ្នឹងឱ្យច្បាស់ ថាជាអ្នកណា អ៊ីចឹងខ្ញុំជម្រាបជូនឱ្យជាក់លាក់។

**ស៖** បាទ អ្ហឺ! បញ្ហាសំខាន់ សំណួររបស់ខ្ញុំ គឺខ្ញុំចង់ដឹងអំពីការងាររបស់អង្គការរបស់លោក ជាជាងបុគ្គលដោយឡែកណាមួយ។

**ឆ៖** បុគ្គលនោះ គឺជាទីប្រឹក្សារបស់ខ្ញុំ បាទ។

[១០:៥៨:៤៥]

**ស៖** ខ្ញុំសូមតសំណួរទាក់ទងទៅនឹងបេសកកម្មរបស់អង្គការរបស់លោក ដែលលោកមានប្រសាសន៍ថា ក្នុងគោលបំណងមួយ ដើម្បីប្រមូលឯកសារ និងផ្សះផ្សាជាតិ។ នេះជាបេសកកម្មដែលលោកបានមានប្រសាសន៍កាលពីម្សិលមិញ ហើយខ្ញុំក៏បានឮលោកមានប្រសាសន៍ម្តងទៀតដែរ ព្រឹកនេះ។ អ៊ីចឹងមែនទេ?

**ឆ៖** លោកចៅក្រម! នេះដូចពីកាលម្សិលមិញដែរ ខ្ញុំអាចនិយាយរឿងរ៉ាវនេះមួយម៉ោង។ សូមលោកអនុញ្ញាត--

**ស៖** បាទ សូមទោស! ខ្ញុំអត់ លោកសាក្សី លោក ឆាំង យុ ខ្ញុំអត់សួរលោកឱ្យលោករៀបរាប់ទេ ខ្ញុំគ្រាន់តែចង់ឱ្យលោកបញ្ជាក់ថា តើវាពិតទេអ្វីដែលខ្ញុំលើកនេះ ក្រែងលោលោកមានការផ្លាស់ប្តូរជំហររបស់លោក?

**ឆ៖** មិនមានទេ បាទ។

[១០:៥៩:៤៥]

**ស៖** បាទ សូមអរគុណ។ ក្នុងទស្សនៈរបស់លោក ពីព្រោះវាជាបេសកកម្មរបស់អង្គការរបស់លោក ខ្ញុំជឿថាការផ្សះផ្សាជាតិ ដែលលោកមានប្រសាសន៍នេះ វាស្ថិតនៅក្នុងជាទស្សនៈវិស័យរបស់អង្គការរបស់លោកក៏ថាបាន។ អ៊ីចឹងខ្ញុំសូមឲ្យលោកជម្រាបទៅក្រុមប្រឹក្សាជំនុំជម្រះថា ៗតើកម្ពុជាបច្ចុប្បន្ននេះមានបញ្ហាដែលត្រូវឲ្យមានការផ្សះផ្សាជាតិយ៉ាងម៉េចដែរ? អាចលោកអាចផ្តល់អំពីទស្សនៈរបស់អង្គការបានទេ? ខ្ញុំអាចសួរសំណួរពីរមុននឹងលោកឆ្លើយសំណួរនេះ។ សំណួរទីមួយ លោកអាចសួរថា-- ខ្ញុំអាចសួរថា តើបេសកកម្មរបស់លោកនៅក្នុងអង្គការ ឌី.ស៊ី.ខេម នេះមានការផ្លាស់ប្តូរដែរទេពីពេលចាប់ផ្តើម និងរហូតមកដល់បច្ចុប្បន្ននេះ? ហើយខ្ញុំនឹងសួរសំណួរអម្បាញ់មិញទៀត។

**លោក ឆាំង យុ៖**

លោកចៅក្រម ខ្ញុំអាចឆ្លើយបានបើសិនជាអនុញ្ញាត។ ពីព្រោះសំណួរនេះលោក វ៉ាន់ថាន់ ពៅដារ៉ា ឆ្លើយម្តងហើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០១:២៩]

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះ សាក្សីមិនបាច់ឆ្លើយទេ ព្រោះជាសំណួរច្រំដែលជាមួយនឹងសាក្សីមុន ដែលក្នុងនាមជាតំណាងឲ្យបុគ្គល-- នីតិបុគ្គលមជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយទីពីរ សូមសួរឲ្យចំនូវបញ្ហាដែលជាកម្មវត្ថុនៃការដែលអង្គជំនុំជម្រះកំណត់ឲ្យសួរដេញដោលចំពោះសាក្សីរូបនេះ ក្នុងនាមគាត់ជាប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ពាក់ព័ន្ធទៅនឹងកិច្ចដំណើរការប្រព្រឹត្តទៅនៃការប្រមូល ការគ្រប់គ្រង ការចងក្រងឯកសារនៅក្នុងមជ្ឈមណ្ឌលកម្ពុជា។ ដូចជាយើងបានរំឭកច្រើនលើកច្រើនសាហើយ។

[១១:០២:១៧]

ចំពោះគោលនយោបាយ ខ្លឹមសារនៃគោលនយោបាយយ៉ាងណានោះ គឺមិនពាក់ព័ន្ធជាមួយនឹងគោលបំណងនៃការស្តាប់សក្ខីកម្មសាក្សីរូបនេះទេ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់មួយថា នៅពេលដែល ឌី.ស៊ី.ខេម ត្រូវបានបង្កើត នៅពេលនោះគឺមាន នៅឆ្នាំ១៩៩៥នោះ វាមានចលនាខ្មែរក្រហមដែលមិនទាន់ចូលនៅក្នុង

រាជរដ្ឋាភិបាលកម្ពុជាទេ។ ប៉ុន្តែបច្ចុប្បន្ននេះវាអត់មាន រឿងវាផ្លាស់ប្តូរ។ ដូច្នេះហើយបានខ្ញុំចង់ដឹងពីចំណុចចាប់ផ្តើម ដែលជាបេសកកម្មរបស់អង្គការ ឌី.ស៊ី.ខេម នេះ ជាមួយនឹងពេលបច្ចុប្បន្ននេះ ថាតើវាមានភាពខុសគ្នាយ៉ាងម៉េច? ឬមួយក៏បេសកកម្មដែលបានកំណត់តាំង-- ដែលមានបច្ចុប្បន្ននេះគឺបានកំណត់តាំងពីការចាប់ផ្តើមដំបូងនោះបាទ?

[១១:០៣:២១]

ហើយម្យ៉ាងទៀតខ្ញុំបាទ យល់ឃើញថា សំណួររបស់ខ្ញុំបាទនេះ គឺមិនមានជាន់គ្នាដោយលើកអំពីការផ្លាស់ប្តូរ ថាតើបេសកកម្មរបស់អង្គការ ឌី.ស៊ី.ខេម នេះមានការផ្លាស់ប្តូរដែរឬទេ ពីចំណុចចាប់ផ្តើមហើយនិងរហូតដល់ពេលបច្ចុប្បន្ននេះ?

ហើយខ្ញុំបាទសូមលោកចៅក្រមមេត្តាអនុញ្ញាតឲ្យសាក្សីឆ្លើយសំណួរនេះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយទេ អង្គជំនុំជម្រះបានសម្រេចរួចហើយ!

[១១:០៤:១២]

**សួរដោយលោក គង់ សំអុន៖**

សូមអរគុណ។ ឥឡូវខ្ញុំសូម តាំងសំណួរថ្មីចំពោះលោក យុ ឆាំង។

**ស៖** កាលពីសប្តាហ៍មុនលោក វ៉ាន់ថាន់ ពៅដារ៉ា គាត់មកឆ្លើយទីនេះ។ ខ្ញុំចង់សួរលោកថា តើលោកបានតាមដានការផ្តល់សក្ខីកម្មនៅក្នុងតុលាការនេះដែរទេ?

**លោក ឆាំង យុ៖**

**ឆ៖** បាន ប៉ុន្តែមិនបានគ្រប់ជ្រុងជ្រោយទេបាទ ព្រោះខ្ញុំនៅក្នុងការធ្វើដំណើរដែរ។

**ស៖** បាទ សូមអរគុណ។ លោកបានស្តាប់ឮនូវចំណុចសំខាន់ៗ ឬក៏បានពិភាក្សាជាមួយនឹងលោក វ៉ាន់ថាន់ ពៅដារ៉ា ទេ បន្ទាប់ពីលោក វ៉ាន់ថាន់ ពៅដារ៉ា បានផ្តល់សក្ខីកម្មរួចហើយ?

**ឆ៖** ពេលមុនខ្ញុំធ្វើដំណើរទៅស្រុកថៃ ខ្ញុំបានជួបគាត់ ហើយបន្ទាប់មកខ្ញុំបានទូរស័ព្ទ។ ខ្ញុំបានប្រាប់លោក វ៉ាន់ថាន់ ពៅដារ៉ា ថាកុំឲ្យមានការព្រួយបារម្ភជាទូទៅគឺយើងគាំទ្រជំហរអ្នកការពារជនចុងចោទ ព្រោះវាមានសារៈសំខាន់ណាស់សម្រាប់ប្រទេសរបស់យើង ហើយខ្ញុំប្រាប់ថាជាទូទៅនៅក្នុងគោលការណ៍របស់ជាមេធាវីជនចុងចោទ បើសិនជាខ្ញុំជាមេធាវីជនចុងចោទវិញ យើងខ្ញុំប្រហែលជាមានចេតនាថាធ្វើឲ្យជនរងគ្រោះឲ្យទៅជាអ្នកឃាតក ហើយធ្វើឃាតកឲ្យទៅជាមនុស្សគ្មានទោស។

អ៊ីចឹងខ្ញុំប្រាប់គាត់ថា កុំឲ្យខ្លាច កុំឲ្យព្រួយ មានការព្រួយបារម្ភ ឆ្លើយទៅតាមសំណួរដែលអាចធ្វើទៅបាន។

[១១:០៦:០៨]

**ស៖** លោក យុ ឆាំង ខ្ញុំអត់យល់នឹងបទអត្ថាធិប្បាយរបស់លោកចុងក្រោយអំមិញថា បើលោកជាមេធាវីការពារជនចុងចោទ បានន័យថា ជនជាប់ចោទ លោកនឹងធ្វើឲ្យជនរងគ្រោះក្លាយទៅជាឃាតក អ៊ីចឹងឬមួយយ៉ាងម៉េច?

**ឆ៖** ជាដំបូន្មាន ប្រហែលជាលោកមិនសូវយល់ ភាសាដែលខ្ញុំនិយាយជាមួយបុគ្គលិកបាទ។ បុគ្គលិកដែលយល់ចិត្តខ្ញុំគាត់យល់អំពីអ្វីដែលខ្ញុំនិយាយ។ ខ្ញុំចង់និយាយថា ដើម្បីឲ្យមានតុលាការមួយមានភាពយុត្តិធម៌សុក្រឹតគឺថា យើងត្រូវគោរពគោលការណ៍ជនចុងចោទ។ គឺត្រូវមានមេធាវីការពារឲ្យកាន់តែខ្លាំង ឲ្យកាន់តែល្អ ដូចជាលោក កាណាវាស អ៊ីចឹងគាត់ពូកែណាស់។ បាទ អ៊ីចឹងគឺថាកាលណាមានមេធាវីកាន់តែល្អ តុលាការនេះយុត្តិធម៌កាន់តែល្អ។ អ៊ីចឹងហើយជាទូទៅយើងមានវិធីសាស្ត្រផ្សេងៗ បាទ ជាទូទៅដូចជាជនរងគ្រោះខ្លះ គ្នាពិតជាជនរងគ្រោះមែន ប៉ុន្តែសំណួរមកហាក់ដូចជាធ្វើឲ្យគ្នាមានអារម្មណ៍ថា គ្នាជាឃាតកទៅវិញ ហើយជាទូទៅនៅពេលមនុស្សដែលត្រូវបានចាប់មកដល់ហើយ បែរទៅជានិយាយថាគ្មានទោសទៅវិញ។ អ៊ីចឹងនេះគ្រាន់តែជា *ខន់សិប* ជាគំនិតដែលខ្ញុំឲ្យដំបូន្មានកុំឲ្យគាត់មានការខឹងសម្បា ឬក៏ប្រតិកម្ម បើសិនជាមេធាវីជនចុងចោទមានសំណួរណាមួយ ដែលមានលក្ខណៈព្រៃផ្សៃ ឬក៏គ្មានការគួរសម សូមលោកហ្នឹងតាំងស្មារតីឲ្យនឹងនរ ដើម្បីឆ្លើយសំណួរទៅតុលាការ។

[១១:០៧:៣៧]

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមឲ្យលោកបញ្ជាក់អំពីការធ្វើចំណាត់ថ្នាក់ នៃឯកសាររបស់លោកបាទ។ ចំណុចមួយបានបញ្ជាក់ថា ឯកសាររបស់លោកមានពីរថ្នាក់ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** សូមលោកបញ្ជាក់ទាំងពីរថ្នាក់ហ្នឹងមើល ខ្ញុំមិនបានស្តាប់ច្បាស់សោះពីពេលកន្លងមក ពីព្រោះហាក់ដូចជាឮតែមួយថ្នាក់?

**ឆ៖** បាទ, ជាទូទៅបើសិនជាលោកឆ្លងកាត់ការសិក្សារៀនសូត្រ នៅក្នុងសាកលវិទ្យាល័យមហាវិទ្យាល័យនេះ គឺជារឿងសាមញ្ញគឺថា ដើម្បីធ្វើការសិក្សាស្រាវជ្រាវមួយ គឺយើងត្រូវមានឯកសារ

ពីរលំដាប់ ហើយខ្ញុំគិតលោកបានបញ្ចប់ការសិក្សាហើយ ហើយក្លាយជាមេធាវីដែលមានមុខតួនាទីនៅទីនេះទៀត។ ឯកសារលំដាប់ពីរថ្នាក់នេះ បើយើងនិយាយជាភាសាអង់គ្លេសស្រួលស្តាប់គឺ *ប្រៃម៉ារី សស* (primary source) និង*ស៊ីខិនដេរី សស* (secondary source) បាននិយាយថាប្រភេទឯកសារដើម និងប្រភេទឯកសារ បន្ទាប់បន្សំ។

[១១:០៨:៣៤]

អ៊ីចឹងនៅក្នុងប្រភេទឯកសារទាំងប្រាំ យើងបានចែកចេញជាពីរលំដាប់ទៀត អាលំដាប់ទីមួយនេះ បើសិនជាប្រើភាសាអង់គ្លេស ប្រហែលជាលោកងាយស្តាប់ជាង គឺយើងប្រើពាក្យថា *ប្រៃម៉ារី សស* គឺជាឯកសារផ្ទាល់ ឯកសារដើម ឯកសារដែលយើងបានពីមនុស្សដែលយើងសម្ភាសដំបូង។ ឯកសារលំដាប់ទីពីរ យើងអាចប្រើវាថា *ស៊ីខិនដេរី សស* ឯកសារដែលយើងបានយកតពីកន្លែងផ្សេងទៀត យកមកប្រើប្រាស់។ អ៊ីចឹងនៅក្នុងប្រភេទទាំងប្រាំ ហើយខ្ញុំសង្ឃឹមថា លោកចាំប្រភេទទាំងប្រាំជាស្ថិរខ្លះប្រភេទទាំងប្រាំនុ៎ងចែកចេញជាពីរលំដាប់ទៀត ហើយពីរលំដាប់នេះ គឺជាប្រព័ន្ធសិក្សារៀនសូត្រនៅគ្រប់មហាវិទ្យាល័យទាំងអស់នៅស្រុកយើងក្តី នៅស្រុកអាមេរិកក្តី នៅស្រុកបារាំងក្តី គឺជារឿងសាមញ្ញសម្រាប់អ្នកណាដែលបានរៀនសូត្រ គឺត្រូវតែស្គាល់អំពីលំដាប់ទាំងពីរនេះ។

សូមទោសលោកយល់ខ្ញុំឆ្លើយទៅទេ?

[១១:០៩:៣១]

**ស៖** ខ្ញុំយល់ ប៉ុន្តែអ្វីខ្ញុំទុកពេលសម្រាប់ការបកប្រែ អ៊ីចឹងបានខ្ញុំសុខចិត្តនៅស្ងៀម។

**ធ៖** អរគុណបាទ។

**ស៖** បាទ សូមអរគុណ ហើយខ្ញុំប្រហែលជាត្រូវសុំទៅលោកប្រធានដើម្បីជម្រាបទៅសាក្សីថា ការលើកឧទាហរណ៍ចំពោះរូបខ្ញុំ ទាក់ទងទៅនឹងការអត្ថាធិប្បាយអម្បាញ់មិញ ដូចថាតើខ្ញុំរៀនចប់មហាវិទ្យាល័យបានយល់អំពីចំណុចនេះ ឬចំណុចនោះ ខ្ញុំគិតថា អានេះគឺជារឿងផ្ទាល់ខ្លួនរបស់ខ្ញុំ ហើយខ្ញុំយល់ថា សាក្សីមិនគួរធ្វើការប្រៀបធៀបបែបនេះទេ។ ខ្ញុំសូមឲ្យលោកប្រធានមេត្តាពន្យល់សាក្សីពីចំណុចនេះ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ទាំងពីរ ទីមួយ មេធាវីសូមរៀបចំនូវសំណួរក្នុងការសួរឲ្យបានជាក់ច្បាស់ ដើម្បីមានមូលដ្ឋាននៅក្នុងការឆ្លើយតបដែរ បើសិនជាសំណួរមិនច្បាស់នាំឲ្យការឆ្លើយតបនោះ វាមានការបញ្ហាដែរ។

បញ្ហាទីពីរ យើងបានរំឭករួចហើយសាក្សី គឺសូមឲ្យស្តាប់នូវសំណួរឲ្យបានច្បាស់ ហើយប្រសិនបើមិនច្បាស់គឺកុំអាលឆ្លើយ សូមឲ្យសួរម្តងទៀត អាចសុំសួរប្រាប់គាត់ផ្ទាល់ក៏បាន ឬក៏ប្រាប់មកយើងដើម្បីឲ្យយើងណែនាំទៅអ្នកដែលសួរហ្នឹង ឲ្យតាំងសំណួរសាជាថ្មីម្តងទៀត ដើម្បីឲ្យបានជាក់ច្បាស់។ បញ្ហាទីពីរ សូមឆ្លើយតបទៅនឹងសំណួរបានហើយ ចៀសវាងការអត្ថាធិប្បាយផុតពីតម្រូវការចាំបាច់ នៃការឆ្លើយតបទៅនឹងសំណួរ ហើយចំពោះបញ្ហាផ្សេងទៀត ដែលពាក់ព័ន្ធនឹងបុគ្គលភាពនេះ គឺសូមឲ្យចៀសវាង គឺចៀសវាងការប៉ះពាល់ទៅលើបុគ្គលភាព នៃបុគ្គលទាំងឡាយដែលចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនេះ។ យើងព្យាយាមផ្តល់នូវសេចក្តីថ្លៃថ្នូរសម្រាប់គ្នាទៅវិញទៅមក។ សូមអញ្ជើញ!

[១១:១១:៥១]

**សួរដោយលោក គង់ សំអុន៖**

បាទ សូមអរគុណ។

**ស៖** លោក ឆាំង យុ កាលពីមុន មុនពេលដែលតុលាការនេះចាប់ផ្តើមដំណើរការ ថាតើមជ្ឈមណ្ឌលឯកសាររបស់លោកបានបង្ហោះឯកសារ ដែលជាលោកអាចថា ជាឯកសារដែលបានពីរបបកម្ពុជាប្រជាធិបតេយ្យនោះនៅលើវេបសាយរបស់លោកដែរឬទេ?

**ឆ៖** យើងបានបង្ហោះព័ត៌មាននៅក្នុង*ដេតាបេស* ដែលមានបួន មានជារូបថត មានជាទីតាំងរណ្តៅសាកសព មានជាឯកសារប្រវត្តិរូប និងមានជាឯកសាររួម។ ហើយនិងមានឯកសារខ្លះយើងបានស្កេន ហើយភ្ជាប់ទៅក្នុងទិន្នន័យនីមួយៗ ប៉ុន្តែមិនបានមួយរយភាគរយទេ។

[១១:១២:៤៣]

**ស៖** ចុះដូចជាចម្លើយសារភាព តើមានបង្ហោះទេនៅក្នុងវេបសាយរបស់លោក?

**ឆ៖** បើសិនលោកនិយាយសំដៅទៅលើចម្លើយសារភាព ដែលខ្ញុំយក-- មានចំនួនប្រហែលមួយពាន់ ដែលខ្ញុំបានទទួលមកពីក្រសួងមហាផ្ទៃ។ ខ្ញុំចាំថា យើងបានស្កេន ហើយបានព្យាយាមបង្ហោះខ្លះដោយសារថា នៅពេលនោះប្រព័ន្ធអ៊ីនធឺណែត នៅស្រុកយើងវាមិនអំណោយផល កាលណាយើងលោកដាក់ច្រើនវាធ្វើឲ្យ*ភ្លាស* វាធ្វើឲ្យគេហទំព័រនេះវាមិនប្រក្រតី។ អ៊ីចឹង យើងបានធ្វើមួយចំនួន ប៉ុន្តែមិនបានមួយរយភាគរយទេ។ យើងមិនដែលបានបង្ហោះចម្លើយសារភាពមកពីសារមន្ទីរទួលស្លែងទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងឯកសារទាំងអស់ ដែលមជ្ឈមណ្ឌល ឌី.ស៊ី.ខេម បានទទួល ខ្ញុំសួរថា តើមជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខេម បានធ្វើការវាយតម្លៃទៅលើឯកសារទាំងនោះដែរ

ឬទេ?

**ឆ៖** រឿងនេះ ខ្ញុំគិតថា អនុប្រធានរបស់ខ្ញុំ លោក វ៉ាន់ថាន់ ពៅដារ៉ា បានជជែកម្ដងហើយ វាយតម្លៃសង្កេត ពិនិត្យអីអ៊ីចឹង តែខ្ញុំសូមជម្រាបលោកថា គ្រប់ឯកសារទាំងអស់ ដែលចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជាខ្ញុំអាន មិនអាចគេចផុតពីតុរបស់ខ្ញុំទេ។ នៅពេលដែលខ្ញុំអានឯកសារហើយ ខ្ញុំចំណាត់ថ្នាក់ទៅតាម*ដេតាបេស* របស់យើង បានន័យថា បើជាប្រវត្តិរូបយើងដាក់មួយដុំ បើសិនជាឯកសារទូទៅយើងដាក់មួយដុំ បើសិនជា រូបថត យើងដាក់មួយដុំ បើសិនជា ព័ត៌មានអំពីទីតាំងរណ្ដៅសាកសព យើងដាក់មួយដុំ។ បន្ទាប់មក ការ-- បើសិនជាលោកចាត់ទុកថា ជាវាយតម្លៃ នេះហើយគឺជាការវាយតម្លៃ ហើយខ្ញុំបានប្រគល់ទៅឲ្យលោក វ៉ាន់ថាន់ ពៅដារ៉ា រៀបចំទុកដាក់ស្កេន ហ្វូតូកូពី បញ្ចូលទៅក្នុងកុំព្យូទ័រ។

[១១:១៤:៤៧]

**ស៖** តើលោក-- ក្នុងអង្គការរបស់លោកមានការវាយតម្លៃឯកសារ ដោយអ្នកជំនាញដែរឬទេ?

**ឆ៖** មានគឺលោក ប៉ែន យៀរនិន បាទ លោកប្រវត្តិវិទូ ប៉ែន យៀរនិន ក៏លោកបានធ្វើការវាយតម្លៃទៅលើសំណុំរឿងឯកសារដែលខ្ញុំនិយាយពីម្សិលមិញហ្នឹង គឺសន្តិបាល។ ហើយដូចខ្ញុំជម្រាបលោកអ៊ីចឹង ការវាយតម្លៃនេះ មិនពិបាកទេ បើសិនជាលោកចេះអានភាសាខ្មែរ គឺពាក្យសន្តិបាល វានៅលើក្រដាសហ្នឹងតែម្ដង។ ហើយលោក ប៉ែន យៀរនិន បានសរសេរៗជាសេចក្ដីសង្ខេបមួយអំពីថាតើប្រភេទឯកសារនេះ វាយ៉ាងដូចម្ដេច? លោកប្រហែលជាអាចរកឃើញព័ត៌មាននេះ ទៅក្នុងគេហទំព័រសាកលវិទ្យាល័យយ៉ែល គឺលោក ប៉ែន យៀរនិន បានធ្វើការវាយតម្លៃឯកសារមួយនេះ ហើយលោកក៏បានធ្វើការវាយតម្លៃទៅលើប្រភេទប្រវត្តិរូប ដែលប្រើប្រាស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ប៉ុន្តែអត្ថបទមួយនេះ តាមដែលខ្ញុំចាំមិនត្រូវបានបង្ហោះនៅក្នុងគេហទំព័រទេ ហើយប្រសិនបើជាលោកត្រូវ ខ្ញុំអាចយកជូនបាន។

**ស៖** ខ្ញុំសូមសួរបន្តថា តើការវាយតម្លៃដែលលោកមានប្រសាសន៍អម្បាញ់មិញនេះ វាជាការវាយតម្លៃផ្លូវការ ឬក៏មួយជាវាយតម្លៃជាលក្ខណៈបុគ្គល?

**ឆ៖** ជាការវាយតម្លៃរបស់ប្រវត្តិវិទូ ប៉ែន យៀរនិន។

[១១:១៦:១៩]

**ស៖** បានន័យថាជាលក្ខណៈបុគ្គល អ៊ីចឹងមែនទេ?

**ឆ៖** បាទ គាត់ជាបុគ្គល។

**ស៖** ចំពោះឯកសារដែលលោកទទួលបានមកពីបណ្ណសារដ្ឋានជាតិ សួរថាតើឯកសារទាំងអស់នោះ មានធ្វើការវាយតម្លៃជាផ្លូវការដែរឬទេ?

**ឆ៖** ឯកសារនេះ ខ្ញុំបានដឹង ដោយខ្ញុំបានអានសរសេរសៀវភៅមួយដោយលោកសាស្ត្រាចារ្យ ប៉ែន ឃៀរនិន ដែលគាត់បានយោងឯកសារចេញមកពីបណ្ណសារដ្ឋានជាតិពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹង លោកអាចចាត់ទុកថាប្រហែលនៅក្នុងសំណេរសៀវភៅរបស់គាត់នេះ អាចជាការវាយតម្លៃក៏បាន ពីព្រោះបានប្រើរួចទៅហើយ។ ហើយមូលហេតុដែលខ្ញុំដឹងថាមានដែលខ្ញុំបានអានសៀវភៅរបស់គាត់។ អ៊ីចឹង យើងប្រហែលជាអាចយកសំណេររបស់គាត់នេះ យកមកប្រើប្រាស់ ហើយចាត់ទុកថាជាវាយតម្លៃរបស់បុគ្គលប្រវត្តិវិទូ ប៉ែន ឃៀរនិន ក៏អាចថាបាន។

**ស៖** សំណួររបស់ខ្ញុំ ខ្ញុំចង់ដឹងថាតើឯកសារដែលបានមកពីបណ្ណសារដ្ឋានជាតិ មានការវាយតម្លៃជាផ្លូវការដែរទេ?

**ឆ៖** ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា?

**ស៖** គឺដោយបណ្ណសារដ្ឋានជាតិ?

[១១:១៧:៥៦]

**ឆ៖** បណ្ណសារដ្ឋានជាតិ ដូចជាលោកអនុប្រធានដែលខ្ញុំបានជម្រាបលោកអ៊ីចឹង គឺស្ថាប័នជាតិមានអនុក្រឹត្យដែលហៅ-- កំពុងតែមានដំណើរការនៅក្នុងប្រទេសរបស់យើង ហើយជាទូទៅយើងបានសួរទៅគាត់ បាទ គឺអ្នកស្រី លឹម គី។ អ្នកស្រី លឹម គី គាត់ជាអ្នកទទួលបន្ទុកឯកសារនេះ ហើយបានសួរទៅគាត់ថា ឯកសារនេះមកពីណា? អ្នកណាឲ្យគាត់? ហើយខ្ញុំបាននិយាយពីម្សិលមិញហើយ ថាឯកសារនេះ តាមដែលខ្ញុំចាំ បាទ គឺមកពីក្រសួងព័ត៌មាន និងវប្បធម៌ នៅក្នុងទសវត្សរ៍៨0 ដែលកាលនោះ មានលោក កែវ ចិន្តា ជារដ្ឋមន្ត្រី ហើយជាអ្នក ជាប្រធានតុលាការកំពូលនៃការកាត់ក្តីឆ្នាំ៧៩។ អ៊ីចឹង ឯកសារនោះ គឺនៅទីនោះ ហើយដោយសារថាបណ្ណសារដ្ឋានជាតិមានក្រឹត្យ មានគោលការណ៍ក្នុងការថែរក្សារបស់ជាតិ ក៏ត្រូវបាននាំយកមកទុកនៅបណ្ណសារដ្ឋានជាតិ។ ត្រង់ថាអ្នកស្រី លឹម គី គាត់វិភាគ សរសេរយ៉ាងម៉េច ខ្ញុំគិតថាប្រហែលជាមិនមានជាការបោះពុម្ពវិភាគនេះទេ។ ប៉ុន្តែខ្ញុំគិតថាអាចសួរគាត់បាន បើសិនជាចាំបាច់។

**ស៖** អ៊ីចឹង ខ្ញុំសូមសរុបនូវសេចក្តីដែលលោកបានធ្វើអត្ថាធិប្បាយអម្បាញ់មិញនេះថា លោក

មិនបានដឹងថា បណ្ណសារដ្ឋានជាតិបានធ្វើការវាយតម្លៃជាផ្លូវការទេ អ៊ីចឹងមែនទេ? ត្រឹមត្រូវទេ?

**ឆ៖** ពិតប្រាកដ បាទ។

**ស៖** ខ្ញុំសូមសួរលោកមួយសំណួរថា តើលោកបានដឹងថា នៅព្រះរាជាណាចក្រកម្ពុជាយើងមានច្បាប់ស្តីពីបណ្ណសារទេ?

[១១:១៩:៥៨]

**ឆ៖** មាន បាទ មាន។ ហើយខ្ញុំបានដឹងថាច្បាប់នេះ គឺជាព្រាងឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី ហើយបើសិនជាខ្ញុំចាំមិនច្បាស់ទេ គឺច្បាប់នេះបានដាក់ជូនសភាអនុម័ត ខ្ញុំមិនច្បាស់ថាតើព្រះករុណាបានឡាយព្រះហស្តលេខានៅឡើយ ឬក៏អត់ទេ។ ប៉ុន្តែខ្ញុំដឹងថាមានច្បាប់នេះ ពីព្រោះថាយើងក៏បានពិនិត្យទៅលើច្បាប់នេះដែរ នៅពេលដែលច្បាប់នេះបានព្រាងឡើង ហើយយើងបានផ្តល់ជាយោបល់ផ្សេងៗទៅលើសេចក្តីព្រាងច្បាប់នេះដែរ។

**ស៖** ខ្ញុំសូមសួរលោកទាក់ទងទៅនឹងការអនុវត្តនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជារបស់លោក ថាតើលោកបានយកគោលការណ៍ដែលមានចែងនៅក្នុងច្បាប់ នៅក្នុងច្បាប់ស្តីពីបណ្ណសារនេះយកមកអនុវត្តនៅក្នុងអង្គការរបស់លោកដែរឬទេ?

**ឆ៖** សូមជម្រាបលោកថា ច្បាប់នេះទើបតែធ្វើនៅពេលថ្មីៗ ហើយដូចខ្ញុំជម្រាបលោកអំមិញអ៊ីចឹង គឺថាមិនទាន់ច្បាស់ថា ច្បាប់នេះត្រូវបានឡាយព្រះហស្តលេខានៅឡើយទេ។ អ៊ីចឹងបានន័យថានៅពេលដែលយើងចាប់កកើត កសាងប្រមូលឯកសារតាំងពីឆ្នាំ៩៥មកនេះ គឺច្បាប់បណ្ណសារដ្ឋានជាតិនេះមិនទាន់មានអាយុជីវិតនៅឡើយទេ។ ខ្ញុំមិនចាំឆ្នាំ ប៉ុន្តែខ្ញុំគិតថា ក្នុងរវាងឆ្នាំប្រហែលជា កាលពីពីរបីឆ្នាំមុន ច្បាប់នេះគឺត្រូវបានព្រាងឡើង ដោយបុគ្គលិកជំនាញរបស់បណ្ណសារដ្ឋានជាតិ ជាមួយនឹងទីស្តីការគណៈរដ្ឋមន្ត្រី។ ដោយសារថាបណ្ណសារដ្ឋានជាតិនេះ គឺនៅក្រោមឱវាទរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

[១១:២២:០២]

**ស៖** ដើម្បីប្រតិចារឹក ខ្ញុំបាទសូមជម្រាបថា ច្បាប់ស្តីពីបណ្ណសារនេះបានអនុម័ត និងឡាយព្រះហស្តលេខាតាំងពីឆ្នាំ២០០៥។ ដូច្នេះច្បាប់នេះ មានអាយុជិតប្រាំពីរឆ្នាំហើយ ប្រាំមួយឆ្នាំជាង។ ខ្ញុំសូមសួរបញ្ជាក់ទាក់ទងទៅនឹងការគ្រប់គ្រងឯកសារនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជារបស់លោក ថាតើឯកសារដែលចូលមកក្នុងមជ្ឈមណ្ឌលឯកសាររបស់លោកនោះ មានបុគ្គលិកដែលមានជំនាញពិតប្រាកដដែលអាចធ្វើយថាភាពជាលក្ខណៈប្រចាំអង្គការដែរឬទេ បើមិនមានជាលក្ខណៈជាក្រុម?

**ឆៈ** លោកចៅក្រម ពាក្យថាជំនាញនេះ វាមិនដឹងថាយើងវាស់ស្ទង់យ៉ាងដូចម្ដេច។ អ៊ីចឹង ពិបាកឆ្លើយបន្តិច ខ្ញុំគ្រាន់តែជម្រាបជូន។ សូមលោកចៅក្រមមេត្តា ជម្រាបទៅលោកមេធាវី ពាក្យជំនាញ ពាក្យអីទាំងអស់នេះគឺថាវាទូលំទូលាយពេក។ អ៊ីចឹងវាពិបាកឆ្លើយ។ ដូចខ្ញុំបានប្រាប់ពីលើកមុនអ៊ីចឹង ថាកាលណាយើងមានការមន្ទិលសង្ស័យ មានការមិនច្បាស់លាស់ គឺយើងបានពិភាក្សាជាមួយបណ្ណសារដ្ឋានជាតិ ដែលជាដៃគូរបស់យើង ដែលយើងកន្លែងដែលផ្ទុកឯកសារជាកន្លែងរបស់ជាតិ។ យើងបានធ្វើការជាមួយស្ថាប័នផ្សេងៗទៀត។ ប៉ុន្តែបើសិននិយាយអំពីជំនាញ មិនដឹងជាសំដៅទៅលើអ្នកហ្នឹងមានសញ្ញាបត្រ ឬក៏អ្នកហ្នឹងអត់សញ្ញាបត្រ ឬក៏រយៈពេលនៃធ្វើការងារ។ បុគ្គលិកខ្ញុំទាំងអស់រួមទាំងលោក វ៉ាន់ថាន់ ពៅដារ៉ា ធ្វើការ១៧ឆ្នាំ ហើយបើសិនជា១៧ឆ្នាំ លោកចាត់ទុកថា មនុស្សនេះគ្មានជំនាញ គ្មានការយល់ដឹង ត្រូវតែរៀនថែមទៀតយកថ្នាក់បណ្ឌិត ឬអនុបណ្ឌិត ខ្ញុំពិបាកឆ្លើយបន្តិចកន្លែងនេះ។ សូមលោកចៅក្រម មេត្តាជម្រាបទៅខាងមេធាវី ដើម្បីសម្រួលពាក្យពេចន៍ ព្រោះថាពាក្យខ្មែរយើង វាមានន័យទូលំទូលាយ វាសម្បូរបែប។ ហើយកាលណាយើងដៅទៅលើតែពាក្យមួយអ៊ីចឹង វាទូលំទូលាយពេក ហើយខ្ញុំអាចឆ្លើយទៅចាកប្រធានរបស់មេធាវីក៏អាចថាបាន។

**សៈ** បាទ សូមអរគុណលោក យុ ឆាំង។ ហើយខ្ញុំសូមបញ្ជាក់ជូនលោកថា ពាក្យថាជំនាញនេះ ខ្ញុំសួរក្នុងន័យអ្នកដែលមានការហ្វឹកហ្វឺនពិសេស បានន័យថាគាត់មានការហ្វឹកហ្វឺន ហើយដែលគេអាចចាត់ទុកថា ជាអ្នកមានបទពិសោធន៍ទៅលើឯកទេសនៃការផ្ដល់យថាភាព ទៅលើឯកសារនេះ។

[១១:២៥:០០]

**ឆៈ** ខ្ញុំព្យាយាមឆ្លើយ ដូចលោក វ៉ាន់ថាន់ ពៅដារ៉ា បានជម្រាបជូនអ៊ីចឹង គឺថាបុគ្គលយើងត្រូវបានទៅរៀនសូត្រនៅសាកលវិទ្យាល័យញូវសៅវែល ដែលនៅទីនោះគឺមានអ្នកស្រី ហេនឡែន ចារីសកាលនោះ គាត់គឺជាបណ្ណារក្ស ជាអ្នកទទួលបន្ទុកក្នុងការបណ្ដុះបណ្ដាល ក្នុងការចងក្រងឯកសារ។ ហើយមានអ្នក នៀរីដា ក្រោស ដែលជាជំនួយការរបស់គាត់ បង្រៀនបុគ្គលិករបស់យើងដែលធ្វើដំណើរទៅកាន់ប្រទេសអូស្ត្រាលី ហើយគាត់ទាំងពីរក៏ធ្លាប់បានធ្វើដំណើរមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាបង្រៀនបុគ្គលិកផ្សេងៗទៀត។ ហើយនៅក្នុងកន្លែងរបស់យើងមានការចែករំលែកកិច្ចការនេះអស់រយៈពេល១៧ឆ្នាំ។

[១១:២៥:៥៦]

**សៈ** ខ្ញុំសូមសួរបញ្ជាក់ទៅលើជំនាញនៃការធ្វើយថាភាពនេះថា តើការពិនិត្យទៅលើក្រដាស

ដែលលោកមានប្រសាសន៍ពីព្រឹកថា ទាក់ទងនឹងពណ៌ណ៎ា។ តើលោកសម្គាល់ក្រដាសនោះប្រភេទយ៉ាងម៉េច ដែលលោកកំណត់ថា ជាក្រដាសដែលចេញដោយ ដែលធ្វើឡើងក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ទីមួយ សូមបញ្ជាក់ប្រាប់លោកខាងដើមបន្តិច ដើម្បីកុំឲ្យមានការមន្ទិលសង្ស័យ គឺថា យើងគ្មានលក្ខណៈវិទ្យាសាស្ត្រធ្វើ *ហ្វ័រវិនស៊ីក* ក្រដាសទេ។ បាទ អត់មានទេ យើងមិនដែលធ្វើទាល់តែសោះ។ ចំពោះការមើលពណ៌ យើងប្រើភ្នែកៗ លោកអាចដឹង លោកអាចមើលក្រដាសនេះមួយ លោកដឹងថាក្រដាសនេះមិនមែនមក-- មិនអាចជាឯកសារដើមទេ ជាក្រដាសថ្មី ឧទាហរណ៍។

[១១:២៦:៥៤]

ប៉ុន្តែនៅក្នុងនោះពណ៌ហ្នឹង គឺបង្ហាញអំពីភាពចំណាស់ ជួនកាលឯកសារខ្លះមានភាពពុកផុយ។ ហើយមួយទៀត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ គេបានយកក្រដាសដែលសេសសល់អំពីសម័យ លន់ នល់ យកមកប្រើប្រាស់ក៏មានដែរ។ អ៊ីចឹងនៅក្នុងនោះដូចជា សៀវភៅ *អាហ្សង់ដា* បាទ របបកម្ពុជាប្រជាធិបតេយ្យបានយកឯកសារក្រដាស ដែលសេសសល់ពីសម័យ លន់ នល់ មកសរសេរខ្លួនឯងក៏មានដែរ។ ហើយមួយទៀតចំណាស់នៃក្រដាសនេះ បើសិនជាអាចលោកគិតថា បើសិនជាលោកហិតក្លិនៗ ក៏លោកអាចដឹងដែរ ថាវាផ្អួរ វាអីអ៊ីចឹង។ ហើយមួយទៀតយើងមិនមែនសម្រេចម្នាក់ឯង មានមនុស្សច្រើនបានមើលឯកសារនេះ។ អ៊ីចឹងជាការទម្លាប់ភ្នែក បើសិនជាលោកទម្លាប់ភ្នែកអស់រយៈ ១៧ឆ្នាំ លោកអាចដឹងហើយ ថាក្រដាសនេះចាស់ ឬមិនចាស់។

[១១:២៧:៣៨]

ហើយមួយទៀត នៅពេលដែលយើងមើលពណ៌នេះ បាទ អ៊ីចឹងពេលដែលយើងមើលពណ៌នេះ យើងមិនមែនមើលតែពណ៌ ហើយកំណត់ថាឯកសារនេះជាឯកសារដើមទេ។ យើងមើលកាលបរិច្ឆេទ យើងមើលអ្នកដែលសរសេរឯកសារនេះ យើងមើលខ្លឹមសារ យើងមើលឯកសារផ្សេងៗទៀតដែលជាប់ពាក់ព័ន្ធនឹងឯកសារ ដែលយើងកំពុងតែសម្លឹងមើលជាដំបូងដូចពណ៌ដែរ។ មូលហេតុដែលខ្ញុំនិយាយអំពីពណ៌ ពីព្រោះពណ៌វាទាក់ទងនឹងមនុស្សយើង។ មនុស្សយើងសព្វថ្ងៃ គឺកាលណាមើលអ្វីមួយ គឺពណ៌ គឺចំណុចទីមួយ ដែលយើងចាប់អារម្មណ៍។ ដូចខ្ញុំមើលទៅលោកអ៊ីចឹង ខ្ញុំឃើញស ខ្ញុំអត់ទាន់ឃើញពណ៌ខ្មៅនៅឡើយទេ។

[១១:២៨:០៧]

អ៊ីចឹង ពណ៌នេះគឺសំខាន់ណាស់ ប៉ុន្តែបើយើងហ្វឹកហ្វឺនភ្នែកយើង១៧ឆ្នាំ ហើយមានអ្នកផ្សេងទៀតជួយឱ្យយោបល់ ហើយប្រើព័ត៌មានផ្សេងទៀត ខ្ញុំគិតថា វាគ្រប់គ្រាន់នៅក្នុងកម្រិតមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូចខ្ញុំជម្រាបលោកពីខាងដើមអ៊ីចឹង យើងគ្មានវិទ្យាសាស្ត្រដើម្បីយកមកធ្វើ*តេស្ដិ៍*ក្រដាសហ្នឹងថាអាយុប៉ុន្មានទេ យើងអត់មានទេបាទ។

**ស៖** លោក យុ ឆាំង តើលោកអាចបង្ហាញទៅក្រុមប្រឹក្សាជំនុំជម្រះបានទេថា ការទុកដាក់ក្រដាសនៅទីកន្លែងខុសគ្នា វាអាចឱ្យគុណភាពក្រដាសនេះខុសគ្នាដែរ?

**ឆ៖** លោកចង់និយាយថា បើក្រដាសនៅអត់មានកន្លែងម៉ាស៊ីនត្រជាក់ ឬក៏មានម៉ាស៊ីនត្រជាក់?

[១១:២៩:១៦]

**ស៖** អាចថាក្រដាសពីរដូចគ្នា ឧទាហរណ៍ថា មួយនៅក្នុងបន្ទប់ មួយនៅហាលវាល ថាតើក្រដាសដែលមានអាយុកាលដំណាលគ្នានេះ វាអាចប្រែពណ៌ខុសគ្នាទេ?

**ឆ៖** ខ្ញុំមិនមែនជំនាញផ្នែកពណ៌។ ប៉ុន្តែជាទូទៅឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ ជាទូទៅរកឃើញនៅក្នុងបន្ទប់។ សូម្បីតែឯកសារដែលសេសសល់រាយប៉ាយនៅក្នុងសារមន្ទីរទួលស្លែងហ្នឹងក៏នៅក្នុងបន្ទប់ដែរ។ ខ្ញុំកម្រឃើញឯកសារកម្ពុជាប្រជាធិបតេយ្យនៅផ្សារថ្មី ឬក៏នៅកន្លែងណាផ្សេង ខ្ញុំកម្រឃើញ។ អ៊ីចឹងវាហាក់ដូចជាថា មានរឿងតែមួយ ខ្ញុំគិតថា បើសិនជាមានអ្នកជំនាញអាចប្រាប់ខ្ញុំក៏ចាប់អារម្មណ៍ដែរបាទ។

[១១:៣០:១៥]

**ស៖** ទាក់ទងទៅនឹងអាការរក្សាទុកឯកសារនៅដំណាក់កាលមុនចូលមកដល់មជ្ឈមណ្ឌលឯកសាររបស់លោក។ តើលោកគិត-- តើលោកមានបានបញ្ជាក់ជាសំណួរ ឬក៏ឱ្យអ្នកដែលផ្តល់ឯកសារពីប្រភពឯកសារហ្នឹងបង្ហាញអំពីទីតាំង ដែលគាត់រកឃើញឯកសារនោះបានទេ ដែរទេ?

**លោក ឆាំង យុ៖**

លោកចៅក្រម នេះខ្ញុំត្រូវការលើកឧទាហរណ៍មួយទៀតហើយ។ លោកចៅក្រមអនុញ្ញាតដែរឬក៏អត់បាទ?

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត! សូមអញ្ជើញ!

[១១:៣១:០០]

**លោក ឆាំង យុះ**

**ឆ:** ឧទាហរណ៍ដូចជាឯកសាររបស់ក្រសួងមហាផ្ទៃអ៊ីចឹង ខ្ញុំប្រាប់ពីម្សិលមិញ ថាឯកសារនេះនៅពេលដែលខ្ញុំតាមដេញរកមនុស្សទីមួយដែលប៉ះឯកសារនេះ គឺគាត់បានឆ្លើយថា ឯកសារនេះនៅម្តុំផ្សារស៊ីឡិប នៅជិតផ្លូវដែលចាក់ទៅរកផ្ទះលោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក។ គាត់ប្រាប់អ៊ីចឹង ប៉ុន្តែឥឡូវបើយើងទៅដល់ កន្លែងនោះវាទៅជាវីឡា វាទៅជាហាងខារ៉ាអូខេ អស់បាត់ទៅហើយ។ អ៊ីចឹងយើងរកឃើញបាន។ ចំពោះឯកសារនៅសារមន្ទីរទួលស្លែង វានៅកន្លែងហ្នឹងតែម្តង។ អ៊ីចឹងគាត់អាចប្រាប់ថានៅបន្ទប់នេះ ឬក៏បន្ទប់នោះ ហើយចំពោះនៅបណ្ណសារដ្ឋានជាតិ គាត់អាចប្រាប់ថាពីមុន នៅក្នុងការិយាល័យរបស់លោក កែវ ចិន្តា ដែលឥឡូវនេះ ការិយាល័យនេះគឺទៅជាកន្លែងអីផ្សេងទៀតហើយ។ ឬមួយក៏លោកអាចសួរទៅលោក ហ្គុនណា បឺយស្រ្តម ឬលោកសាស្ត្រាចារ្យ ឡូវ៉ា សាំម៉ី ថាពីលើកមុន ឯកសារនេះនៅក្នុងគណៈកម្មាធិការស៊ុយអែត កម្ពុជា វៀតណាម ឡាវ ឥឡូវនេះ គឺត្រូវបានផ្ទេរមកទៅដល់កន្លែងបណ្ណាល័យរបស់សាកលវិទ្យាល័យ លូនដ៍។ អ៊ីចឹងការទីតាំងនេះ យើងអាចរកបាន ប៉ុន្តែវាមិនប្រាកដថាជាទីតាំងដែលនៅរក្សាភាពដដែល តាំងពីឆ្នាំ៧៩ មកនោះទេ។ វាមានការផ្លាស់ប្តូរទៅលើទីតាំងនីមួយៗ ដែលឯកសារនេះ ត្រូវបានរកឃើញពីដំបូង។

[១១:៣២:២៦]

**សួរដោយលោក គង់ សំអុន៖**

**ស:** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា បើគិតជាចំនួនប្រភេទឯកសារដែលលោករកឃើញ និងឯកសារដែលគេយកមកឲ្យ មានអ្នកយកមកឲ្យហ្នឹង តើមានចំនួនប៉ុន្មានភាគរយដែរ?

**ឆ:** លោកចៅក្រម បញ្ហារឿងសួរភាគរយ តួលេខនេះគឺពិបាកឆ្លើយ ហើយមិនមែនជារឿងមួយដែលពិបាកនឹងរកឃើញ បើសិនជាយើងបើកទៅក្នុងប្រព័ន្ធទិន្នន័យ ឬក៏អនុញ្ញាតឲ្យខ្ញុំបាទផ្តល់ព័ត៌មាននេះតាមរយៈអ៊ីម៉ែលមកលោកមេធាវី ខ្ញុំអាចធ្វើជូនបាន។ ក្នុងការកំណត់ភាគរយជាការលំបាកណាស់ ពីព្រោះសព្វថ្ងៃនេះ យើងនៅតែបន្តទទួលឯកសារអ៊ីចឹង។ អ៊ីចឹងវាកើនឡើងជារៀងរាល់ថ្ងៃ។

[១១:៣៣:០៧]

**ស:** បាទ សូមអរគុណ។ អ្វីដែលខ្ញុំចង់ដឹងថា ពីពេលកន្លងមករហូតមកដល់ពេលនេះ រឿងអនាគតទៀត អាហ្នឹងចាំគិតនៅពេលក្រោយទៀត។ តើលោកអាចវាយតម្លៃជាតម្លៃប្រហាក់ប្រហែល

ថា ឯកសារដែលលោករកឃើញចំនួនប៉ុន្មានភាគរយ? ហើយឯកសារដែលលោកទទួលបានពីបុគ្គលចំនួនប៉ុន្មានភាគរយ បានដែរទេ?

**ឆៈ** ខ្ញុំសូមកន្លែងនេះដែរ គឺថានិយាយទៅវាអាចជាចំណាប់ខ្មាំង បាទបើសិនជាខ្ញុំនិយាយពាក្យថាលេខណាមួយ។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់ឲ្យហើយ នេះជាការប៉ាន់ប្រមាណទេ មិនមែនជាការពិតទេ។ ខ្ញុំគិតថាប្រហែលជា ៦០ ឬក៏ ៧០ភាគរយបានមកពីស្ថាប័ន ហើយប្រហែលជា ៤០ភាគរយទៀតបានមកពីបុគ្គល។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ឲ្យហើយ នេះគ្រាន់តែជាការប៉ាន់ប្រមាណទេ។

**សៈ** បាទ ខ្ញុំសួរបញ្ជាក់ទៅលោកសាជាថ្មី ខ្ញុំបានស្តាប់រួចហើយ ប៉ុន្តែខ្ញុំចង់បញ្ជាក់វិញថា ឯកសារទាំងអស់ដែលលោកបានទទួលនោះ ខ្ញុំឮពាក្យមានពីរ។ ទីមួយថាឯកសារចំនួនប្រហែល ១លានមួយទៀតថាប្រហែល ១លានទំព័រ។ តើមួយណាពិតប្រាកដ?

[១១:៣៤:៥១]

**ឆៈ** នេះវាចូលទៅក្នុងន័យបច្ចេកទេស បើសិនជាលោកមើលនៅក្នុងក្បួនខ្នាតនៃការរៀបចំឯកសារ មួយសន្លឹកគេរាប់ថាមួយឯកសារ។ ហើយមួយសន្លឹកនេះ បើសិនជាយើងមើល និយាយជាភាសាខ្មែរ មានជាសន្លឹក ឬទំព័រ ខុសគ្នាទៀត។ អ៊ីចឹងវាមានការប្រើប្រាស់ពាក្យ បើសិនជាលោកប្រើទំព័រ គឺលោកមើលតែផ្នែកមួយទេ។ បើសិនជាលោករាប់សន្លឹក យើងមើលទាំងពីរ ហើយដូចជាប្រវត្តិវិទូ ប៉ែន ឃៀរនិន គាត់រាប់ថាមួយសន្លឹកនេះគឺជាឯកសារមួយ។ អ្នកខ្លះទៀត រាប់ឯកសារនេះមួយដុំមួយដុំ មួយសំណុំនេះ មានរាប់ពាន់សន្លឹក រាប់ថាជាមួយឯកសារដែរ។ អ៊ីចឹងការរាប់ឯកសារនេះ វាមានការខុសៗគ្នា។ ចំពោះយើង យើងរាប់ឯកសារមួយ គឺមួយឯកសារ ដែលយើងរាប់ឯកសារនេះមួយសន្លឹក គឺជាមួយឯកសារ ហើយយើងរាប់វារហូតតៗទៅ ជាការរាប់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ប៉ុន្តែ ស្ថាប័នផ្សេង អាចរាប់ផ្សេងពីហ្នឹង ក៏អាចថាបាន។

[១១:៣៥:៥១]

**សៈ** សូមអរគុណ។ អ៊ីចឹងបានន័យថា ក្នុងចំណោមឯកសារទាំងអស់មួយលានឯកសារសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺមានន័យថាអាចមួយលានសន្លឹក។ អ៊ីចឹងមែនទេ?

**ឆៈ** បាទ អាចថាមួយលានសន្លឹក អាចថាមួយលាន-- ផ្នែកមួយនៃផ្នែកទាំងប្រាំ នៃប្រភេទឯកសារនៅមជ្ឈមណ្ឌលឯកសារ។

**សៈ** ក្នុងចំណោមឯកសារទាំងប្រហែល១លាននេះ តាមការអះអាងរបស់លោកគឺថា គ្មាន

ឯកសារណាមួយក្លែងក្លាយទេ។ អ៊ីចឹងមែនទេ?

**ឆ៖** មានឯកសារមួយដែលមិនមានភាពប្រក្រតី ដែលខ្ញុំលើកឡើងទាក់ទងទៅនឹងការចាប់ជនបរទេសនៅខេត្តកំពត។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ឡើងវិញថា ឯកសារទាំងចំនួនប្រហែលមួយលានឯកសារនេះ នៅមជ្ឈមណ្ឌលឯកសារនោះ គឺពុំមានឯកសារមួយក្លែងក្លាយទេ។ លោកទទួលអ៊ីចឹងទេ។

**ឆ៖** សូមលោកសួរម្តងទៀត លោកចង់និយាយថា មានអ្នក ឯកសារដែលមិនមែនរបបកម្ពុជាប្រជាធិបតេយ្យ?

**ស៖** បាទ។

**ឆ៖** បាទពិតមែន គឺនៅក្នុងឯកសារមួយលាននេះ សុទ្ធសឹងតែឯកសារមកពីរយៈកាល ១៩៧៥ និង១៩៧៩។

[១១:៣៧:២៦]

**ស៖** ហើយឯកសារទាំងអស់នោះ គ្មានឯកសារណាមួយក្លែងក្លាយទេ លោកអាចបញ្ជាក់អ៊ីចឹងបានទេ? ឬមួយក៏លោកផ្លាស់ប្តូរជំហររបស់លោក?

**ឆ៖** ខ្ញុំមិនបានផ្លាស់ប្តូរទេបាទ។ ខ្ញុំឆ្លើយរួចហើយ។

**ស៖** បាទ អ៊ីចឹងអត់មានក្លែងក្លាយទេ ឯកសារទាំងអស់នោះ។

**ឆ៖** លោកសំដៅទៅលើយ៉ាងម៉េច ក្លែងក្លាយហ្នឹង?

**ឆ៖** ក្លែងក្លាយ បានន័យថាមិនមែនជាឯកសារពិតប្រាកដ។

**ឆ៖** មានមួយ គឺឯកសារទាក់ទងទៅហ្នឹង ដែលយើងយល់ថាមិនប្រក្រតី គឺឯកសារនិយាយអំពីការចាប់ចំណាប់ខ្មាំងនៅខេត្តកំពត។ ឯកសារផ្សេងៗទៀតគឺសុទ្ធសឹងជាឯកសារមកពីរបបកម្ពុជាប្រជាធិបតេយ្យ។

**ស៖** ឯកសារដែលលោកមានប្រសាសន៍ថា មិនប្រក្រតីនេះ គឺមិនជាប់ពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យទេ។ មិនអ៊ីចឹងមែនទេ?

**ឆ៖** មិនទាក់ទងទៅនឹងរយៈកាល ពី៧៥ ដល់៧៩ ព្រោះវាកើតឡើងក្នុងឆ្នាំ៨៤-៨៥។

**ស៖** បាទ។ ខ្ញុំសូមបន្តសំណួរ។ ទាក់ទងទៅនឹងឯកសារដែលលោកមាននៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា តើឯកសារទាំងអស់នោះ ជាឯកសារដែលមានកំណត់រយៈពេលរបបកម្ពុជាប្រជាធិប

តេយ្យ បានន័យថាពីថ្ងៃទី១៧ មេសា ១៩៧៥ រហូតដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩។ ទាំងអស់មែនទេ?

**ឆ៖** អានេះមករឿងដដែលវិញ អំពីការប្រើពាក្យនិងការយល់ដឹង ពាក្យឯកសារវាទូលំទូលាយ។ វាមានឯកសារផ្សេងៗទៀត។ ឯកសារដែលយើងបញ្ចូលទៅក្នុងទិន្នន័យ គឺមានរយៈកាលនោះមែន។ ប៉ុន្តែយើងមានឯកសារផ្សេងៗទៀត ដូចជារូបថត ដូចជាការធ្វើបទសម្ភាសមនុស្ស ក៏យើងចាត់ទុកជាឯកសារ ប៉ុន្តែយើងទើបតែសម្ភាសគាត់ប៉ុន្មានឆ្នាំ ប៉ុន្មានខែមុននេះ ឧទាហរណ៍។

[១១:៤០:០០]

អ៊ីចឹងឯកសារដែលយើងបញ្ចូលទៅក្នុងទិន្នន័យរបស់យើង ដែលជាឯកសារក្រដាសៗហ្នឹង គឺសុទ្ធសឹងតែជាឯកសារមកពីរយៈកាលនៃកម្ពុជប្រជាធិបតេយ្យ។ ខ្ញុំចាំថា នៅមានឯកសារមួយទៀតហៅថា “ឯកសាររណសិរ្ស”។ ឯកសាររណសិរ្សនេះ គឺជាឯកសារដែលកកើតឡើងនៅក្នុងឆ្នាំ១៩៨២ ឬ៨៣ គឺជាប្រភេទឯកសារយើងហៅថា “ញត្តិ”។ ឯកសារញត្តិនេះ គឺយើងបានរកឃើញនៅកន្លែងបច្ចុប្បន្ននេះគឺជាក្រសួងរៀបចំបុណ្យជាតិ អន្តរជាតិ។ ឯកសារញត្តិនេះ គឺជាឯកសារធ្វើក្រោយឆ្នាំ៧៩ទេ ប៉ុន្តែយើងបានប្រើប្រាស់វាជាមូលដ្ឋានក្នុងការស្វែងរករណ្ដៅសាកសព និងមនុស្សផ្សេងៗទៀត ដោយសារថានៅក្នុងឯកសារនេះមាននិយាយអំពី។ ហើយតាមដែលខ្ញុំចាំមានឯកសារនេះប្រហែលជាមួយចំនួនតូចត្រូវបានបញ្ចូលដែរ ដោយយើងឃើញថាមានឯកសារខ្លះហ្នឹងវាមានលក្ខណៈសំខាន់ ហើយក្រោយមកយើងបានគិតថាវាជាការមួយមិនត្រឹមត្រូវ។ អ៊ីចឹងចំពោះឯកសារមួយនេះ គឺយើងបានពិចារណាម្ដងហើយម្ដងទៀត ហើយឯកសារនេះគឺវាមិនមានគ្រប់ចំនួនទេ។ យើងឲ្យឈ្មោះវាថា “ឯកសាររណសិរ្ស”។

[១១:៤១:២២]

**ស៖** សូមអរគុណ។ លោកអាចបង្ហាញពីចំនួន មិន-- អាចថាជាការវាយតម្លៃទៅលើប្រភព-- ប្រភេទនៃឯកសារដែលលោកទទួលបាននេះថា ឯកសារដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលផលិតនៅក្នុងសម័យនោះ ហើយនិងឯកសារដែលធ្វើបន្ថែម ឧទាហរណ៍ ការធ្វើវិភាគ ឬក៏ការយកចម្លើយសាក្សី ឬក៏អ្នកដែលលោកធ្វើសម្ភាសនោះ មានខុសគ្នាយ៉ាងម៉េចដែរ? មានចំនួនខុសគ្នាយ៉ាងម៉េចដែរ?

**ឆ៖** រឿងចំនួននេះគឺជាសំណួរមួយដែលខ្ញុំយ៉ាប់នឹងឆ្លើយតែម្ដង សូមទោស។ បើខ្ញុំគិតថា អាចរកឃើញនៅក្នុងទិន្នន័យ មិនជាការពិបាកទេ បើសិនជាលោកចង់ដឹងចំនួននេះប៉ុន្មានៗអ៊ីចឹង។ ឲ្យខ្ញុំឆ្លើយ

ចាំពីខួរក្បាលរបស់ខ្ញុំនេះ ខ្ញុំមិនអាចចាំបាន ពីព្រោះថាចំនួននេះវាកើនរាល់ថ្ងៃ។ អ៊ីចឹងបើលោកមេត្តាអធ្យាស្រ័យ បើសិនជាលោកចង់បានព័ត៌មាននេះ មិនជាការលំបាកទេ។ លោកអ៊ីម៉ែលមកខ្ញុំក៏បាន ឬក៏លោកអាចព្យាយាមឆែកនៅក្នុងអ៊ីនធឺណែតក៏បាន ឬសួរព័ត៌មានបន្ថែមក៏បាន។ បើឆ្លើយសំណួរទៅវាទៅជាមានការពាំត្រណោត និយាយវាមិនពិត។ អ៊ីចឹងខ្ញុំមិនចង់និយាយចំនួន ដោយសារថាវាខ្ញុំមិនដឹងពិតប្រាកដ។ ជាចំនួនប៉ាន់ប្រមាណ។

[១១:៤២:៤៩]

**ស៖** សំណួរចុងក្រោយ ខ្ញុំសូមសួរថា តើលោកបានដឹងពីអតីតបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមកធ្វើការនៅតុលាការនេះប៉ុន្មាននាក់ដែរ? លោកមានដឹងទេ?

**ឆ៖** មានច្រើនបាទ។ មានគ្រប់អង្គភាពទាំងអស់ ខ្ញុំស្គាល់ទាំងអស់បាទ។

**ស៖** ប្រហែលប៉ុន្មាននាក់លោកអាច?

**ឆ៖** ចំនួនគឺខ្ញុំអត់បានរាប់ តែខ្ញុំស្គាល់មុខ។ ម្សិលមិញខ្ញុំឃើញសុជា, សុខឃីម ធ្វើការនៅកន្លែងកិច្ចការសាធារណៈជាមួយ កល្យាណ, សុផល ធ្វើការនៅកន្លែងផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ, មករា ធ្វើជាអ្នកកាន់ខាងឯកសារ, ណារឿន, សុរិយ៉ា ធ្វើការជាមួយ អូ.ស៊ី.អាយ.ជេ។ ខ្ញុំស្គាល់ច្រើន ទាំងបរទេសទាំងខ្មែរ មានច្រើន។ ប៉ុន្តែខ្ញុំមិនទម្លាប់រាប់ចំនួន។ ប៉ុន្តែបើលោកចង់ឲ្យឈ្មោះ ខ្ញុំរៀបរាប់ជូនបានទាំងអស់។ ហើយមិនមែនជាការអ្វីលាក់បាំង ពីព្រោះបុគ្គលិកទាំងអស់គេបានដាក់ពាក្យសុំចូលធ្វើការ ហើយតុលាការនេះបានទទួលគេយកមកធ្វើការ។ ហើយចាំបាច់អ្នកទាំងអស់នោះត្រូវធ្វើការលាលែងចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជាមុនមកធ្វើការនៅទីនេះ។

[១១:៤៣:៥៨]

**ស៖** សូមអរគុណ។

**ឆ៖** សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវី អរគុណសាក្សី។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយលោក ឆាំង យុ ដោយការផ្តល់សក្ខីកម្មរបស់លោក គឺនៅត្រូវបន្តទៀត ដូច្នេះអង្គជំនុំជម្រះអញ្ជើញនៅ

រសៀលនេះ សូមអញ្ជើញមកបន្តការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ចាប់ផ្តើមពីម៉ោងមួយនិងសាមសិបនាទី។ ហើយសូមមន្ត្រីរដ្ឋបាលតុលាការជួយសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាក រហូតដល់ពេលយើងចាប់ផ្តើមកិច្ចដំណើរការសវនាការ។

[១១:៤៥:៥៩]

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទ នួន ជា និង--

សូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធានខ្ញុំសូមស្នើថា កូនក្តីរបស់ខ្ញុំសូមស្នាក់នៅបន្ទប់ខាងក្រោម នៅក្នុងពេលដំណើរការនីតិវិធីបន្តទៅទៀតហ្នឹង ហើយខ្ញុំបានដាក់លិខិតបោះបង់សិទ្ធិនេះ ជូនជាលាយលក្ខណ៍អក្សរហើយ។

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា តាមរយៈមេធាវីរបស់គាត់សុំលះបង់សិទ្ធិក្នុងការចូលរួមតាមដានកិច្ចដំណើរការសវនាការផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយសុំដកខ្លួនថយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅបន្ទប់ខាងក្រោមតាមរយៈប្រព័ន្ធសោតទស្សន៍ អង្គជំនុំជម្រះយល់ព្រមអនុញ្ញាតតាមការស្នើសុំ សម្រាប់កិច្ចដំណើរការសវនាការនៅរសៀលនេះ ហើយអម្បាញ់មិញនេះគឺច្បាស់លាស់ហើយថា មេធាវីបានបំពេញកាតព្វកិច្ចរួចហើយក្នុងការផ្តល់មកឲ្យអង្គជំនុំជម្រះ នូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ ក្នុងកិច្ចដំណើរការសវនាការរបស់ជនជាប់ចោទ សម្រាប់រសៀលនេះ។ ហើយបង្គាប់ឲ្យមន្ត្រីសោតទស្សន៍ភ្ជាប់នូវប្រព័ន្ធសោតទស្សន៍រូបភាព និងសំឡេងទៅបន្ទប់ខាងក្រោមសម្រាប់ជនជាប់ចោទ នួន ជា បន្តកិច្ចដំណើរការ-- តាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់កិច្ចដំណើរការសវនាការនៅរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោម ហើយនិងរសៀលនេះបង្គាប់ឲ្យនាំខ្លួន លោក ខៀវ សំផន ឡើងមកកាន់បន្ទប់សវនាការនេះឲ្យបានមុនម៉ោងមួយនិងសាមសិននាទី។ សូមអញ្ជើញសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៤៨នាទី ដល់ម៉ោង១៣:៣១នាទី)*

[១៣:៣១:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្ដល់វេទិកាទៅក្រុមមេធាវីការពារក្ដី នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ លោក លោកស្រីចៅក្រម អស់លោក លោកស្រី នៅក្នុងបន្ទប់សវនាការ និងក្រៅសវនាការ។

សូមគោរព សួស្ដីលោក ឆាំង យុ នៅពេលនេះ គឺសូមចាប់ផ្ដើមដោយថ្លែងអំណរគុណទៅដល់លោក ឆាំង យុ ដូចដែលយើងបានពិភាក្សាក្នុងរយៈពេលពីរបីថ្ងៃចុងក្រោយនេះ គឺលោកមានប្រយោជន៍ណាស់ ដែលលោកផ្ដល់ព័ត៌មានជូនមកយើង។ ខ្ញុំយល់ថា លោកគឺបានលើកឡើង-- ក៏បានជម្រាបជូន អ៊ីនូហ្ស៊ី ផងដែរ ដូច្នេះហើយ ទោះយ៉ាងណាក៏ដោយ គឺក្នុងនាមជាក្រុមមេធាវីលោក នួន ជា គឺខ្ញុំសូមថ្លែងអំណរគុណជូនលោក។

**ស៖** នេះមិនមែនជាសំណួរទេ ក៏ប៉ុន្តែខ្ញុំបន្តសំណួររបស់ខ្ញុំទីមួយទាក់ទងទៅនឹងបញ្ហាទូទៅដែលសំណួរនេះ ទីមួយគឺមានការពិភាក្សាក្នុងពេលពីរថ្ងៃចុងក្រោយនេះ។ ដូច្នេះហើយ ខ្ញុំចង់តែបញ្ជាក់ឱ្យបានច្បាស់ថា ប្រសិនបើ ឌី.ស៊ី.ខេម យោងទៅលើឯកសារណាមួយ ថាជាឯកសារដើម ឯកសារនោះ ប្រហែលជាឯកសារ-- នៅពេលដែលឌី.ស៊ី.ខេម យោងឯកសារមួយ ថាមិនមែនជាឯកសារដើម បានន័យថា ឯកសារនោះ មិនមែនជាឯកសារបង្កើតនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ មែនដែរឬទេ?

**លោក ឆាំង យុ៖**

**ឆ៖** មិនច្បាស់ទេ បាទ ឯកសារហ្វូតូកូពីក៏អាចជាដើមដែរ គឺជាឯកសារដែលយើងថតចម្លងមកពីប្រទេសខាងក្រៅ។

**ស៖** គឺខ្ញុំគិតថា នេះជាការឆ្លើយមួយ ប៉ុន្តែមិនចំតែប៉ុណ្ណោះទេ។ គឺលោកនៅ ឌី.ស៊ី.ខេម គឺបានន័យថា នៅពេលដែលហៅឯកសារមួយជាឯកសារដើមនោះ គឺឯកសារដែលបានបង្កើតឡើងនៅក្នុង

ចន្លោះឆ្នាំ៧៥ ដល់៧៩ តើមែនដែរឬទេ?

**ឆ៖** ត្រឹមត្រូវ បាទ។

**ស៖** សូមអរគុណ។ លោកបាននិយាយបញ្ហាហ្នឹង កាលពីម្សិលមិញ ក៏ប៉ុន្តែខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ នៅពេលដែលលោកឃើញឯកសារមួយដែលចុះកាលបរិច្ឆេទឆ្នាំ៧៥ ទៅដល់៧៩ ថានៅពេលដែលឃើញអ៊ីចឹង គឺលោកនឹងប្រមូល និងរក្សាវាទុកដែរឬទេ មិនខ្វល់ថាខ្លឹមសារនៅក្នុងឯកសារនោះយ៉ាងម៉េចនោះឡើយ?

**ឆ៖** ជាការត្រឹមត្រូវ បាទ។

**ស៖** ឌី.ស៊ី.ខេម ក៏ប្រមូលឯកសារដែលមិនបានបង្កើតឡើងក្នុងចន្លោះ៧៥ ដល់៧៩ ផងដែរ។ ឯកសារនោះឃើញមាននៅក្នុងសំណុំរឿងផងដែរ។ តើលោកមានលក្ខណៈវិនិច្ឆ័យយ៉ាងម៉េចក្នុងការប្រមូលឯកសារទាំងឡាយដែលមិនបង្កើតឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ រួមទាំងឯកសារទាំងឡាយណាដែលមិនស្ថិតនៅក្នុងរបបនោះ តើលោកមានលក្ខណៈវិនិច្ឆ័យយ៉ាងម៉េចដែរ?

[១៣:៣៥:៥៥]

**ឆ៖** ជាទូទៅ ឯកសារទាំងនេះត្រូវផ្តល់មកយើងជាសំណុំធំមួយ បាទ ហើយមានការលាយឡំគ្នា ដូចជាឧទាហរណ៍ ឯកសារមកពីប្រទេសស៊ុយអែត អ៊ីចឹង មានរយៈកាលកម្ពុជាប្រជាធិបតេយ្យ ហើយមានឯកសារមួយចំនួនដែលធ្វើឡើងដោយកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីរបបនេះបានដួលរលំទៅ។ អ៊ីចឹងមានឯកសារមួយចំនួនទៀតនៅខាងក្រោយ ហើយវាត្រូវបានផ្តល់មកយើងទាំងស្រុង។ អ៊ីចឹងយើងមិនបានបំបែកវាទេ ព្រោះយើងចង់ទុកថែរក្សាភាពដើមរបស់វា។ អ៊ីចឹងបានន័យថា ឯកសារនេះត្រូវផ្តល់មកឲ្យយើង យើងមិនបានទៅរកឯកសារផ្សេងទៀតនៅក្នុងចន្លោះពេលនេះទេ។

**ស៖** ខ្ញុំនឹងសុំសួរឲ្យជាក់លាក់ជាងនេះ។ ប្រសិនបើលោកស្នើសុំឲ្យអ្នកស្រាវជ្រាវរបស់លោកណាមួយចេញទៅតាមខេត្ត ទៅរកឯកសារដែលវាបង្កើតឡើងក្នុងឆ្នាំ១៩៨២ ហើយឯកសារឆ្នាំ៨២នេះគឺមិនជាប់ពាក់ព័ន្ធទៅនឹងឆ្នាំ៧៥, ៧៩នោះឡើយ។ តើលោកមានលក្ខណៈវិនិច្ឆ័យយ៉ាងម៉េចនៅពេលដែលឃើញឯកសារហ្នឹង គួរតែប្រមូល ឬក៏មិនគួរ? តើមានលក្ខណៈវិនិច្ឆ័យយ៉ាងម៉េចដែរ?

**ឆ៖** ជាទូទៅ បើសិនជាឯកសារនេះមិនមែនធ្វើឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមានការពាក់ព័ន្ធនិយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ ឧទាហរណ៍ដូចនិយាយអំពីទីតាំងរណ្តៅសាកសព អ្ហ៊ឺ!ទីកន្លែងផ្សេងៗ យើងបានប្រមូលវាយកមកដែរ។

[១៣:៣៧:២៧]

**ស៖** លោកនិយាយថា ឯកសារដែលពាក់ព័ន្ធនឹងសម័យកម្ពុជាប្រជាធិបតេយ្យ តែខ្ញុំចង់សួរជាក់លាក់ថា តើលោកមានលក្ខណៈវិនិច្ឆ័យយ៉ាងម៉េចទៅនឹងការប្រមូលឯកសារដែលវាពាក់ព័ន្ធនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ខ្ញុំមិនសូវច្បាស់សំណួរ លោកចង់សួរថា តើខ្ញុំវិនិច្ឆ័យយ៉ាងដូចម្ដេចដែលបញ្ជាក់ថាឯកសារនេះ គឺជាឯកសារកម្ពុជាប្រជាធិបតេយ្យ ហើយប្រមូលយកមក វាខុសគ្នានឹងការវិនិច្ឆ័យរបស់ខ្ញុំយ៉ាងដូចម្ដេចចំពោះឯកសារដែលធ្វើក្រោយសម័យរបបកម្ពុជាប្រជាធិបតេយ្យ?

**ស៖** ខ្ញុំនឹងសួរដោយងាយៗវិញ អាចលើកជាឧទាហរណ៍ជាក់លាក់។ ឧទាហរណ៍ថាលោកបានឃើញឯកសារមួយដែលឯកសារនោះ គឺធ្វើឡើងក្នុងឆ្នាំ៨៣, ៨៤ ហើយនិយាយអំពីកូនក្ដីរបស់ខ្ញុំ គឺលោក នួន ជា។ តើលោកនឹងប្រមូលឯកសារនោះដែរឬទេ ទោះបីជាឯកសារនោះ វាពាក់ព័ន្ធទៅនឹងអំពើប្រព្រឹត្តរបស់កូនក្ដីរបស់ខ្ញុំ ក្រោយឆ្នាំ៧៩?

**ឆ៖** ជាទូទៅ យើងមិនចុះទៅមូលដ្ឋានដើម្បីរកឯកសារនេះទេ ប៉ុន្តែឯកសារនេះត្រូវបានផ្ដល់មកឱ្យយើងទៅតាមបុគ្គលមួយចំនួនដែលមានឯកសារទាំងអស់នេះ ហើយយើងបានយកមកទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១៣:៣៩:០០]

**ស៖** ខ្ញុំមិនចង់សួរពាក់ព័ន្ធទៅនឹងចំណុចនោះទៀតទេ ប៉ុន្តែចម្លើយមិនឆ្លើយទៅនឹងសំណួររបស់ខ្ញុំនោះទេ ប៉ុន្តែខ្ញុំសូមសួរបន្តទៀត។ លោកបានលើកឡើងនៅមុខចៅក្រមស៊ើបអង្កេតថា អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់មួយចំនួន បានសរសេរចំណារនៅលើឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យ តើលោកអាចផ្ដល់ឈ្មោះអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ហ្នឹងដែរឬទេ ដែលគាត់សរសេរចំណារនៅក្នុងឯកសារដើមនៃសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** តាមដែលខ្ញុំចាំ មានបីរូប គឺលោកសាស្ត្រាចារ្យ ប៉ែន ឃៀរនិន, ដេវីដ ឆេនដ៍ល័រ ហើយនិង លោក ហ្វូលីយ៉ូ ហៀលជ្រេស។

**ស៖** សូមអភ័យទោស សូមឱ្យលោកអ្នកទីបីហ្នឹងឈ្មោះអីគេដែរ សូមលោកថាឡើងវិញ?

**ឆ៖** ហ្វូលីយ៉ូ ហៀលជ្រេស សរសេរនឹងអក្សរ J ដោយសារថាគាត់មានកំណើតមកពីប្រទេសឈីលី អ៊ីចឹងយើង*ប្រូណោន* ហ្វូលីយ៉ូ បាទ *អ៊ុស* "J-U-I-L-O J-E-L-E-S"។

**ស៖** នៅមុខចៅក្រមស៊ើបអង្កេត លោកបានលើកឡើងពិភាក្សាអំពីឯកសារមួយ ហើយលោកស្គាល់ជាចំណាររបស់លោក ស៊្វីរ វិន ហេដឌ័រ។ តើលោកចាំថា លោកបានលើកឡើងថា ស្គាល់ចំណាររបស់លោក ស៊្វីរ ហេដឌ័រ នៅចំពោះមុខចៅក្រមស៊ើបអង្កេតដែរឬទេ?

[១៣:៤០:៤៧]

**ឆ៖** បើសិនជាលោកបង្ហាញឯកសារ ប្រហែលជាខ្ញុំអាចចាំបាន ព្រោះខ្ញុំស្គាល់អក្សរក្រុមអ្នកសិក្សាស្រាវជ្រាវខ្ពស់ជាច្រើននាក់ដែរបាទ។

**ស៖** ខ្ញុំចង់ផ្តល់ឯកសារជូនលោក ក៏ប៉ុន្តែដោយមើលទៅនាឡិកា គឺខ្ញុំចង់សួរតាមអ្វីដែលលោកដឹង។ ថាតើលោក ស៊្វីរ ហេដឌ័រ ធ្លាប់សរសេរនៅលើឯកសារដើម ដែលជាឯកសារសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ មិនដឹងជាឯកសារមួយណា ប៉ុន្តែមូលហេតុដែលខ្ញុំចាំច្បាស់ លោក ប៉ែន យៀវនិន លោក ឆេនដ៍ល័រ និងលោក ហ្វូលីយ៉ូ ពីព្រោះគាត់បានសរសេរទៅលើកំណត់ហេតុគណៈអចិន្ត្រៃយ៍ ដែលខ្ញុំឧស្សាហ៍កំណត់ហេតុនេះ អ៊ីចឹងចំណាំបាន។ តែ ស៊្វីរ ហេដឌ័រ ខ្ញុំមិនច្បាស់ ទាល់តែឃើញឯកសារបានខ្ញុំអាចប្រាប់បាន។

[១៣:៤១:៣៤]

**ស៖** សូមអរគុណ។ នៅក្នុងពេលដែលលោកលើកឡើងនិយាយជាមួយនឹងចៅក្រមស៊ើបអង្កេត លោកបានប្រើពាក្យ "ឯកសារដែលវាមានគ្រោះថ្នាក់"។ ថាតើលោកអាចពន្យល់ទៅលើពាក្យហ្នឹងដែរឬទេ?

**ឆ៖** ឯកសារនេះយើងប្រើពាក្យ *"អែតវីស"* ពាក្យ *អែតវីស* ជាភាសាអង់គ្លេស បើកបកគ្រោះថ្នាក់ហ្នឹងវាគ្រោះបន្តិចជាភាសាខ្មែរ បាទ ភាសាអង់គ្លេសប្រែថា *អែតវីស* ។ ឯកសារ *អែតវីស* គឺយើងបានរៀបចំដំបូងភ្លាមៗ ដោយយើងមានការព្រួយបារម្ភ កាលនោះស្រុកយើងមានការប៉ះទង្គិចនៅក្នុងឆ្នាំ៩៧ ហើយខ្ញុំបានពិភាក្សាជាមួយនឹងលោកសាស្ត្រា-- ប្រវត្តិវិទូ ប៉ែន យៀវនិន ហើយនិងអ្នកស្រីហេឡែន ចាវីស ថាតើយើងត្រូវធ្វើយ៉ាងណា ដោយសារស្រុកយើងហាក់ដូចជាមានកលយុគ?

[១៣:៤២:២៤]

អ៊ីចឹងគាត់ក៏ប្រាប់ខ្ញុំថា គួរតែប្រមូលឯកសារណាដែលសំខាន់ៗម្តុំ រកវិធីយ៉ាងណាដើម្បីដាក់នៅកន្លែងមួយដែលសុវត្ថិភាព។ ពីព្រោះតាមដែលខ្ញុំចាំ នៅពេលនោះអគាររបស់យើងកំពុងតែទទួលរងនូវ

 

ការជួសជុល។ ហើយដូចលោកដឹងស្រាប់ហើយថា អគាររបស់យើងនៅខាងកើតវិមានឯករាជ្យ ជាតំបន់ ដែលពេលដែលមានបញ្ហានៅពេលនោះ មានរថក្រោះ មានទាហាននៅពាសពេញកន្លែងនោះឯង។

អ៊ីចឹងខ្ញុំបានបង្កើតឯកសារនេះមួយ ជម្រាបទៅលោក ប៉ែន យៀវនិន ថាខ្ញុំគិតថា ឯកសារនេះ *អែតរីស* បានន័យថា យើងត្រូវការរកកន្លែងសន្តិសុខ ទុកវាឲ្យបានច្បាស់លាស់ដើម្បីចៀសវាងបញ្ហាផ្សេងៗ។

[១៣:៤៣:០៦]

**ស៖** សូមអរគុណដែលលោកឆ្លើយបានយ៉ាងច្បាស់។ យើងបានពិភាក្សាក្នុងពីរថ្ងៃកន្លងមកហើយថា ឌី.ស៊ី.ខេម មានបេសកកម្មក្នុងការស្វែងរកការពិត ហើយបេសកកម្មមួយនោះ គឺថាស្វែងរកការពិតចំពោះអ្នកដែលស្លាប់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវបាទ។

**ស៖** នៅក្នុងការស្រាវជ្រាវរបស់លោក លោកធ្លាប់ជួបប្រទះឯកសារ ឬក៏ទម្រង់នៃភស្តុតាងណាមួយដែលពន្យល់អំពីការការស្លាប់ ដែលវាកើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[១៣:៤៤:០២]

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកចៅក្រម លោកប្រធាន ប្រសិនបើអាចឲ្យខ្ញុំឡើងជំទាស់នោះ ខ្ញុំសូមជំទាស់ទៅលើសំណួរនេះ ដោយសារតែវាមិនពាក់ព័ន្ធទៅនឹងសកម្មភាព និងវិធីសាស្ត្ររកឯកសាររបស់ ឌី.ស៊ី.ខេម។ យើងចងចាំថា មេធាវី កាណាវាស ជំទាស់កាលពីម្សិលមិញ ដែលថាយើងនៅទីនេះ គឺលើកឡើងសួរអំពីវិធីសាស្ត្រ និងការធ្វើកាតាឡុកទៅលើបញ្ហានៃការរៀបចំឯកសារតែប៉ុណ្ណោះ។ ដូច្នេះបញ្ហាសកម្មភាពផ្សេងទៀតរបស់ ឌី.ស៊ី.ខេម គឺមិនជាប់ពាក់ព័ន្ធនោះឡើយ។

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធានខ្ញុំសូមធ្វើការឆ្លើយតបការជំទាស់របស់ខាងសហព្រះរាជអាជ្ញានេះ មិនគួរមានប្រសិទ្ធភាពនោះទេ ដោយសារតែហេតុផលមួយចំនួន។ ពីព្រោះឯកសារទាំងឡាយដែលប្រមូលដោយ ឌី.ស៊ី.ខេម គឺពាក់ព័ន្ធនៅក្នុងការជំនុំជម្រះនេះ ហើយបញ្ហាហ្នឹងវានឹងលើកឡើងអំពីថា តើវាមានយថាភាពដែរឬទេ ចំពោះឯកសារដែលបានបញ្ជូនមកតុលាការ?

[១៣:៤៥:០៤]

ដូចដែលលោក កាណាវាស លើកឡើងកាលពីម្សិលមិញ ជំហររបស់មេធាវីការពារក្តីនោះ ខ្ញុំយល់ច្បាស់ ក៏ប៉ុន្តែខ្ញុំមិនដឹងជំហររបស់សហព្រះរាជអាជ្ញាយ៉ាងណានោះទេ។ អង្គជំនុំជម្រះបានសម្រេចគាំទ្រទៅខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហើយលើកឡើងថា ការប្រមូលឯកសារ យើងអាចយកមកពិភាក្សាគ្នាបាន។ ដូច្នេះ អ្វីដែលខ្ញុំសួរគឺពាក់ព័ន្ធទៅនឹងៗការប្រមូលឯកសារ មិនមែនការប្រមូលឯកសារដែលវាមិនបញ្ជូនមកតុលាការនោះទេ គឺខ្ញុំសុំសួរតែឯកសារដែលបញ្ជូនមកតុលាការ។

ដូច្នេះហើយ យើងដឹងហើយឯកសារដែលរកបាននិងឃើញនៅកន្លែងណាមួយនោះ យើងគួរតែពិភាក្សាគ្នា។ ហើយពេលខ្លះទៅឯកសារមួយចំនួនប្រមូលបាន ក៏ប៉ុន្តែមិនបានបញ្ជូនមកតុលាការនេះ។ ដូច្នេះហើយទើបយើងនៅទីនេះនិយាយអំពីបញ្ហានៃការប្រមូលឯកសារ។ សូមអរគុណ។

[១៣:៤៦:០៤]

**ប្រធានអង្គជំនុំ៖**

កុំទាន់ឆ្លើយសាក្សី។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៧:១៥]

**ប្រធានអង្គជំនុំ៖**

សាក្សីស្តាប់សំណួរដែលមេធាវីសួរបានច្បាស់លាស់ទេ?

**លោក ឆាំង យុ៖**

សូមលោកមេធាវីមានប្រសាសន៍ម្តងទៀត។ បាទ សូមអរគុណ។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** បាទ ជាការពិតលោក ឆាំង យុ សំណួររបស់ខ្ញុំគឺចង់សួរ-- ខ្ញុំសូមផ្តល់ជាសេក្តីផ្តើមសិនដើម្បីឲ្យលោកយល់ច្បាស់។ សម័យកម្ពុជាប្រជាធិបតេយ្យគឺចោទប្រកាន់អំពីការស្លាប់មនុស្សជាច្រើននាក់ ដូច្នេះហើយវាអាចមានមូលហេតុផ្សេងទៀតដែលបណ្តាលឲ្យមនុស្សស្លាប់ដូច្នេះ។ ដូច្នេះនៅក្នុងការស្រាវជ្រាវរបស់លោកដែលរកឃើញឯកសារណាមួយ ឬក៏ភស្តុតាងដែលអាចពន្យល់អំពីការស្លាប់របស់មនុស្សទាំងឡាយដែរឬទេ? ឧទាហរណ៍ថា ឯកសារនោះវាអាចពាក់ព័ន្ធទៅនឹងការទម្លាក់គ្រាប់បែករបស់អាមេរិកាំង ឬក៏ឯកសារដែលពាក់ព័ន្ធទៅនឹងការកាប់សម្លាប់សាហាវឃោរឃៅពីសម័យលន់ នល់។ តើមានធ្លាប់ជួបឯកសារប្រភេទហ្នឹងដែរឬទេ?

[១៣:៤៨:២៦]

**ប្រធានអង្គជំនុំ៖**

លោកសាក្សីអាចឆ្លើយនូវសំណួរនេះបាន ហើយការជំទាស់របស់សហព្រះរាជអាជ្ញាគ្មានប្រសិទ្ធភាពទេ។

**លោក ឆាំង យុះ៖**

**ឆ៖** យើងបានទទួលព័ត៌មានពីអ្នកស្រុកជាទូទៅនៅក្នុងខេត្តស្វាយរៀង ដែលជាតំបន់មួយដែលមានការទម្លាក់គ្រាប់បែកធ្ងន់ធ្ងរ ហើយយើងបានដឹងព័ត៌មាននេះ ហើយយើងក៏ធ្លាប់បានឃើញបំណែកគ្រាប់ដែលបានផ្ទុះ ដែលនៅសេសសល់។ ហើយក៏យើងបានធ្លាប់ឃើញអាវុធដែលសេសសល់ តាមដែលខ្ញុំចាំបានអាវុធមួយដែលបន្សល់ទុកកាលពីសង្គ្រាមនៅក្នុងលើភ្នំខេត្តរតនគិរី។ ហើយយើងបានជម្រាបបញ្ហានេះ មកពីសារមន្ទីរកងទ័ពនៅខេត្តសៀមរាប ដើម្បីប្រមូលទុក ថែរក្សាជានៅក្នុងសារមន្ទីរជាតិ។

ហើយយើងក៏បានធ្លាប់បានទទួលព័ត៌មានអំពីការស្លាប់របស់មនុស្ស មិនមែនការជាប់ពន្ធនាគារ តែដោយសារការអត់អាហារ ឬក៏មានការខ្វះថ្នាំសង្កូវជាដើម។

[១៣:៤៩:៣២]

**ស៖** សូមអរគុណ។ សំណួរពិតប្រាកដរបស់ខ្ញុំនោះ គឺថានៅពេលដែលលោកជួបភស្តុតាងបែបហ្នឹង ឧទាហរណ៍ថា៖ សំណល់នៃគ្រាប់បែកដែលធ្វើឲ្យមនុស្សស្លាប់នោះ នៅពេលនោះគឺលោកបានថតជារូបភាព ហើយយករូបថត ថតជារូបថត ហើយយករូបថតនោះមកទុកនៅ ឌី.ស៊ី.ខេម ដែរឬទេ?

**ឆ៖** មាន ខ្ញុំចាំថារហូតមានទៅសរសេរអត្ថបទទៀតផង នៅក្នុងទស្សនាវដ្ដីស្វែងរកការពិត។

**ស៖** នៅពេលដែលលោកចុះទៅតាមខេត្ត ទៅសម្ភាសប្រជាជន អំពីហេតុការណ៍ដែលកើតឡើងក្នុងយុគសម័យកម្ពុជាប្រជាធិបតេយ្យថា តើប្រជាជននោះ គាត់ស្ម័គ្រចិត្តនិយាយៗដោយស្ម័គ្រចិត្តអំពីបញ្ហានៃការទម្លាក់គ្រាប់បែករបស់អាមេរិកាំង នៅក្នុងសម័យ លន់ នល់ ដែរឬទេ?

**ឆ៖** ជាទូទៅ យើងឲ្យគាត់រៀបរាប់ប្រាប់អំពីជីវិតរបស់គាត់ ហើយគាត់ក៏ចាប់ផ្ដើមនិយាយ អ្នកខ្លះចាប់ផ្ដើមពីឆ្នាំ៥០ អ្នកខ្លះផ្ដើមឆ្នាំ៦០ អ្នកខ្លះចាប់ផ្ដើមនៃការទម្លាក់គ្រាប់បែកជាហូរហែ។ អ៊ីចឹងជាទូទៅ អ្នកសម្ភាសរបស់យើងអង្គុយស្ដាប់រឿងរ៉ាវទាំងអស់ដែលគាត់បានប្រាប់យើង ហើយថតទុកនៅក្នុងកាសែត។

[១៣:៥០:៥៧]

**ស៖** សូមអរគុណ ចម្លើយច្បាស់ណាស់ម្រាប់យើងខ្ញុំ។ ខ្ញុំសូមចូលទៅដល់ចំណុចមួយទៀត ដែលលោកបាននិយាយជជែកជាមួយនឹងខាងសហព្រះរាជអាជ្ញា។ យើងបានសួរលោក ពៅដារ៉ា មួយចំនួនរួចទៅហើយ តែវានៅតែមិនច្បាស់លាស់។ ដូច្នេះសំណួររបស់ខ្ញុំទីមួយ គឺដូចតទៅ៖

លោកបានទទួលលិខិតពីសហព្រះរាជអាជ្ញានៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៦ នៅក្នុងលិខិតនោះ គឺសហព្រះរាជអាជ្ញាស្នើសុំឲ្យខាង ឌី.ស៊ី.ខេម ផ្ទេរឯកសារជូនមកខាងសហព្រះរាជអាជ្ញា។ តើលោកមានចាំទេ ថាលោកបាននិយាយអំពីចំណុចហ្នឹងជាមួយនឹងចៅក្រមស៊ើបអង្កេត?

**ឆ៖** ខ្ញុំមិនចាំដែរ ព្រោះមានសំបុត្រមកច្រើនស្នើ បើនិយាយពីសំបុត្រស្នើសុំឯកសារមានច្រើន បើសិនជាលោកអាចបង្ហាញ ខ្ញុំអាចប្រាប់ជាក់លាក់។ ព្រោះជាទូទៅ យើងតម្រូវឲ្យភាគីទាំងអស់សរសេរសំបុត្រមកជាលាយលក្ខណ៍អក្សរ ដើម្បីសុំឯកសារ។

**ស៖** ដោយសារតែពេលវេលាគឺខ្ញុំមិនបង្ហាញលិខិតជូនលោកនោះទេ នៅក្នុងពេលដែលលោកឆ្លើយជូនចៅក្រមស៊ើបអង្កេត គឺលោកបានលើកឡើងថា នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៦ លោកទទួលលិខិតមួយច្បាប់ពីខាងសហព្រះរាជអាជ្ញា ដែលសហព្រះរាជអាជ្ញាស្នើសុំឲ្យ ឌី.ស៊ី.ខេម ផ្ទេរឯកសារមួយចំនួនមកកាន់សហព្រះរាជអាជ្ញា។ ខ្ញុំចង់សួរលោកថា មុនពេលដែលលោកទទួលលិខិតនេះពីសហព្រះរាជអាជ្ញា តើលោកធ្លាប់បានជួយប្រជុំមុន ជាមុនជាមួយនឹងខាតតំណាងពីសហព្រះរាជអាជ្ញាដែរទេ មុនពេលដែលទទួលបានលិខិត?

[១៣:៥២:៥៥]

**ឆ៖** យើងមិនដែលពិភាក្សាអំពីឯកសារណាដែលលោកចង់បានទេ។ ជាទូទៅ ខ្ញុំដឹងថានៅ អ.វ.ត.ក នេះ មានមន្ត្រីម្នាក់ដែលជា លោក គ្រេក អេតឆេសាន់ គាត់តែងតែណែនាំបុគ្គលិកនៅក្នុងការងារនេះឲ្យស្គាល់អំពីទិន្នន័យជាតាបេសរបស់យើង ហើយខ្ញុំបានបញ្ជាក់ច្បាស់ទៅអង្គភាពទាំងអស់ថាចង់បានឯកសារណា សុំឲ្យលេខ ផ្តល់លេខមកឲ្យយើង។ អ៊ីចឹងយើងគ្មានការពិភាក្សាលើឯកសារណាមួយទេ។ ហើយអ៊ីចឹងជាទូទៅសំបុត្រទាំងអស់មកពីសហព្រះរាជអាជ្ញាក្តី ចៅក្រមស៊ើបអង្កេតក្តី អង្គភាពការពារជនចុងចោទក្តី គឺត្រូវតែមានលេខឯកសារមកខ្ញុំ ហើយអាចរកឃើញនៅក្នុងគេហទំព័រ។ អ៊ីចឹង នេះគឺជាទម្លាប់ដែលយើងធ្វើ។

[១៣:៥៣:៤៤]

**ស៖** សូមអរគុណចំពោះការឆ្លើយរបស់លោក ក៏ប៉ុន្តែខ្ញុំចង់សួរថា មុនពេលដែលខាងសហព្រះរាជអាជ្ញាស្នើសុំឯកសារពី ឌី.ស៊ី.ខេម តាមលិខិតផ្លូវការ។ ដូច្នេះតើលោកមានជួបប្រជុំជាមួយនឹងអ្នកតំណាងពីខាងការិយាល័យសហព្រះរាជអាជ្ញា នៅពេលមុនពេលលិខិតនោះបញ្ជូនមកលោកជាផ្លូវការដែរឬទេ?

**ឆ៖** បើនិយាយអំពីការជួបប្រជុំអំពីឯកសារ គ្មានទេ។ ប៉ុន្តែបើសិននិយាយអំពីការជួប ដោយសារថាគាត់ទៅធ្វើការនៅកន្លែងខ្ញុំ ហើយមានការិយាល័យមួយសម្រាប់ភាគីទាំងអស់នោះ គឺមាន បាទ គឺគាត់ចូលទៅ គាត់សួរថាទូរនៅកន្លែងណា? រកឯកសារនៅកន្លែងណា? បន្ទប់ទឹកនៅកន្លែងណា? ជាដើម។ ប៉ុន្តែគ្មានការពិភាក្សាណាមួយទៅលើឯកសារទេ។

**ស៖** សូមអរគុណ។ តាមការចងចាំរបស់លោក ថាតើលោកបានជួបអ្នកតំណាងពីខាងការិយាល័យសហព្រះរាជអាជ្ញាជាលើកទីមួយនៅពេលណាដែរ?

[១៣:៥៥:០០]

**ឆ៖** ខ្ញុំដូចជា មិនចាំទេ។ ខ្ញុំមិនចាំដែរ ព្រោះអង្កាល់ហ្នឹងជំនាន់លោក ពើទីត លោក ពើទីត ខ្ញុំ-- ដូចជាមិនចាំទេបាទ ប៉ុន្តែខ្ញុំធ្លាប់ជួបទាំងលោក ពើទីត ទាំងអ្នកស្រី ជា លាង ពេលដែលគាត់នៅក្នុងកម្មវិធីផ្សេងៗបាទ តែលើកទីមួយតែម្តងខ្ញុំមិនចាំទេបាទ។ ហើយខ្ញុំបាននិយាយថា នៅក្នុងអំឡុងពេលដែលមានតុលាការ អ៊ីចឹងនិយាយនៅក្នុងពេលណាមួយ។

[១៣:៥៥:៤០]

**ស៖** តើលោកចាំដែរឬទេ នៅពេលដែលលោកជួបជាលើកដំបូងជាមួយនឹងលោក រ៉ូប៊ីត ពើទីត ឬក៏លោកស្រី ជា លាង ខ្ញុំមិនដឹងថា ពួកគាត់ទាំងពីរមានវត្តមាន ឬក៏យ៉ាងណានោះទេ។ តើលោកបានពិភាក្សាគ្នាអ្វីដែរ?

**ឆ៖** អូ៎ លោក ពើទីត យ៉ាប់ណាស់ គាត់មិនសូវនិយាយទេ ហើយអ៊ីចឹងគ្មានអីពិភាក្សាសោះជាមួយគាត់ ហើយអ្នកស្រី ជា លាង គាត់ក៏ដោយសារគាត់មានតួនាទីមួយនៅក្នុងរាជរដ្ឋាភិបាលអ៊ីចឹងគាត់មានលក្ខណៈមួយគម្លាតពីខ្ញុំតែម្តង។ អ៊ីចឹងកម្រណាស់ ជួនកាលខ្ញុំជួបគាត់ដោយចៃដន្យ ខ្ញុំចាំបានថា ខ្ញុំធ្លាប់បានជួបលោក ពើទីត ម្តងនៅ*ម៉ូនូមិនប៊ុក* នៅកន្លែងលក់សៀវភៅ ហើយជាទូទៅគាត់មានអាកប្បកិរិយាមួយមិនសូវជារាក់ទាក់ទេ គ្រាន់តែ *"សេយ៍ហេឡូ"* អីអ៊ីចឹង ហើយកាលហ្នឹងខ្ញុំមានការភ្ញាក់ផ្អើលព្រោះជាលើកទីមួយ ដែលខ្ញុំឃើញគ្រួសាររបស់គាត់ កាលនោះជាជនជាតិស្បែកខ្មៅ។ អ៊ីចឹងខ្ញុំចាំ

បានប៉ុណ្ណឹងបាទ ក្រៅពីហ្នឹងគ្មានបានពិភាក្សាអីទេជាមួយនឹងលោក ពើទីត។

[១១:៥៦:៣៥]

**ស៖** តើលោកមានធ្លាប់បានពិភាក្សាជាមួយនឹងលោក រូបឺត ពើទីត នៅក្នុងពេលណាមួយ ពាក់ព័ន្ធទៅនឹងឯកសារដែលត្រូវផ្ទេរមក ខាងការិយាល័យសហព្រះរាជអាជ្ញាដែរឬទេ?

**ឆ៖** អត់ទេបាទ។

**ស៖** តើលោកធ្លាប់ស្នើទៅកាន់ខាងការិយាល័យសហព្រះរាជអាជ្ញាថា ឯកសារជាក់លាក់ណាមួយដែលគេគួរមើលដើម្បីធ្វើការចោទប្រកាន់កាត់ទោស ចំពោះបុគ្គលដែលត្រូវបានយកកាត់ទោសនៅ អ.វ.ត.ក នេះ?

**ឆ៖** អត់ទាល់តែសោះបាទ។

[១៣:៥៧:២១]

**ស៖** តាមដែលលោកដឹង តើលោកដឹងថា តើឯកសារសម្រេចយ៉ាងម៉េច ថាឯកសារណាមួយគួរតែទៅប្រមូលពីខាង ឌី.ស៊ី.ខេម នោះ?

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់ទៅលើសំណួរមួយនេះ ដោយសារតែសំណួរនេះគឺវាមិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលខាងសាក្សីគាត់ចាំនោះទេ ទៅលើឯកសារណាមួយដែលខាងសហព្រះរាជអាជ្ញា គាត់ប្រើប្រាស់ដើម្បីចោទប្រកាន់នោះ។

**លោក ហ្សាស្តេី ប៉ោ៖**

គឺខ្ញុំសូមលើកឡើងដោយសារតែ មានអ្នកតំណាងពី អូ.ស៊ី.ភី គឺគាត់បានជួបជាមួយនឹងលោក ឆាំង យុ ដូច្នេះហើយគឺ ខ្ញុំសូមអនុញ្ញាតសួរទៅលើសំណួរមួយនេះ។

[១៣:៥៨:០៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៨:៥០]

**ប្រធានអង្គជំនុំ៖**

ជំទាស់មានប្រសិទ្ធភាព។ លោកមេធាវីអាចតាំងសំណួរផ្សេងទៀត ឬក៏សំណួរណាដែលជាក់លាក់ច្បាស់លាស់។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបន្តសួរទៅមុខទៀត។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** តើខាងការិយាល័យសហចៅក្រមស៊ើបអង្កេត ឬក៏សហព្រះរាជអាជ្ញា ធ្លាប់សួរលោកអំពីឯកសារដែលលោកមិនមានការកាន់កាប់ដែរឬទេ?

[១៣:៥៩:៣៤]

**ឆ៖** និយាយទៅខ្ញុំមិនដែលពិភាក្សារឿងឯកសារ ទាល់តែមានសំណើបានយើងថតចម្លងជូន។

**ស៖** ខ្ញុំទុកចំណុចនេះសិន។ ខ្ញុំសូមសួរទៅចំណុចប្រធានបទមួយទៀត គឺអ្វីដែលយើងបានពិភាក្សាគ្នាកាលពីព្រឹកមិញ។ យើងបានពិភាក្សាគ្នាយ៉ាងច្រើនអំពីពាក្យថា វាយតម្លៃ ឬការវិភាគ ឬក៏ការកំណត់តម្លៃទៅលើឯកសារ នៅក្នុងភាសាខ្មែរគឺមានភាពច្រឡូកច្រឡំដូចតែជា-- ដូចនឹងភាសាអង់គ្លេសដែរ ក៏ប៉ុន្តែខ្ញុំចង់ឲ្យបានច្បាស់ទៅលើសំណួរដែលខ្ញុំសួរ។ សំណួររបស់ខ្ញុំចង់សួរដូចតទៅ៖ នៅពេលដែល ឌី.ស៊ី.ខេម ទទួលបាននូវឯកសារ លោកបាននិយាយកាលពីព្រឹកមិញថា លោកជាអ្នកវាយតម្លៃទៅលើឯកសារ ហើយបន្ទាប់មក លោកកំណត់ជា *កាតេហ្គោរី* ថាវាជារូបថត ឬក៏ជាប្រវត្តិរូប ឬក៏ជាឯកសារពាក់ព័ន្ធទៅនឹងផ្នូររួម រណ្តៅសាកសពរួម តើត្រឹមត្រូវដែរឬទេ ចំណុចហ្នឹង?

**ឆ៖** ត្រឹមត្រូវបាទ។

**ស៖** នៅពេលដែលលោកទទួលបានឯកសារ ថាតើ ឌី.ស៊ី.ខេម បានវាយតម្លៃ ថាឯកសារនោះមានភស្តុតាងដាក់បន្ទុកដែរឬទេ?

**ឆ៖** អត់ទេបាទ ដោយសារថាយើងមើលសំដៅទៅលើអំពីប្រភេទឯកសារ ដើម្បីបញ្ចូលទៅក្នុងទិន្នន័យ។

**ស៖** តើលោកធ្វើការវិភាគ ថាតើឯកសារនោះ មានព័ត៌មានដាក់បន្ទុកដែរឬទេ? ខ្ញុំគ្រាន់តែដូរពាក្យទេ ដើម្បីឲ្យលោកបញ្ជាក់លើចំណុចហ្នឹង។

**ឆ៖** យើងមានធ្វើសេចក្តីសង្ខេប ដែលមាននៅក្នុង *រ៉ឺកស៊ីត* បាទ ដើម្បីឲ្យដឹងថាឯកសារនេះនិយាយពីអ្វីខ្លះ ហើយព័ត៌មាននេះ គឺដាក់នៅក្នុង-- បង្ហោះនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា យើងហៅវាថា “*សាំម៉ឺរី*” ។

[១៤:០១:៤៧]

អ៊ីចឹង ដើម្បីឲ្យដឹងថា ឯកសារនេះ និយាយអំពីអ្វី? អ្នកណាជាអ្នកនិពន្ធ? នៅកន្លែងណា? គឺយើងបានឲ្យបុគ្គលិកដែលជាអ្នកធ្វើកិច្ចការខាងឯកសារនេះ សង្ខេប ដើម្បីថាអ្នកដែលស្វែងរកនេះ អាចដឹងថា អូ៎ ឯកសារនេះមានប៉ុន្មានទំព័រ? នៅតំបន់កន្លែងណាអ៊ីចឹង? ហើយលោកអាចរកមើល ឃើញនៅក្នុងគេហទំព័ររបស់យើងដែរ។

**ស៖** ដូច្នេះ ខាងលោកគឺធ្វើជាសេចក្ដីសង្ខេប ក៏ប៉ុន្តែក្រៅពីការធ្វើឯកសារសង្ខេបនេះ តើខាងលោកមានការវិភាគទៅលើព័ត៌មានក្នុងហ្នឹង ថាព័ត៌មានហ្នឹង ជាព័ត៌មានដាក់បន្ទុកដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន គឺខ្ញុំសូមជំទាស់ទៅលើសំណួរនេះ។ ខ្ញុំមានការស្ទាក់ស្ទើរអម្បាញ់មិញ ក៏ប៉ុន្តែខាងមេធាវីការពារក្ដីព្យាយាមលើកឡើងសួរទៀត គឺវាស្ថិតនៅក្រៅវិសាលភាពនៃអង្គហេតុ។ ដាក់បន្ទុក ឬក៏ដាក់ដោះបន្ទុក ខ្លឹមសារនៃឯកសារវិភាគដោយ ឌី.ស៊ី.ខេម នោះ គឺមិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលយើងពិភាក្សាគ្នាអំពីភាពទុកចិត្តបាននៃឯកសារ ភាពពាក់ព័ន្ធ ឬយថាភាពនៃឯកសារនោះទេ។

[១៤:០២:៥៩]

**លោក ហ្សាស្តេ ប៉ោ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឆ្លើយតប។ ជាការពិត យើងមានការយល់ច្រឡំទៅលើពាក្យវិភាគ ការកំណត់តម្លៃ និងការវាយតម្លៃ។ ដូច្នេះហើយ គ្រាន់តែខ្ញុំចង់សួរបញ្ជាក់ទៅលើពាក្យទាំងអស់នេះតែប៉ុណ្ណោះ ថាតើ ឌី.ស៊ី.ខេម គឺធ្វើយ៉ាងម៉េចទៅលើឯកសារ? ហើយលោក ដារ៉ា ប្រហែលជាគាត់លើកឡើងច្បាស់កាលពីសប្ដាហ៍មុនដែរ ដោយសារតែបកប្រែ ទើបយើងមិនបានទទួលចម្លើយច្បាស់លាស់។ ដូច្នេះហើយ នៅទីនេះ គឺខ្ញុំចង់សួរបញ្ជាក់ទៅលើសំណួរដែលខ្ញុំនៅសល់ ហើយខ្ញុំមិនច្បាស់លាស់តែប៉ុណ្ណោះ។ ដូច្នេះហើយ ខាងមេធាវីការពារក្ដី គឺខ្ញុំគ្រាន់តែចង់សួរទៅកាន់ខាងសាក្សីថា ក្រៅពីការសង្ខេប ថាតើខាង ឌី.ស៊ី.ខេម នោះ មានការវិភាគទៅលើព័ត៌មាន ថាព័ត៌មាននោះ ជាព័ត៌មានដាក់បន្ទុកដែរឬទេ? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៥:៤៥]

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់ព្រះរាជអាជ្ញាមានប្រសិទ្ធភាព ហើយសាក្សីមិនបាច់ឆ្លើយតបនឹងសំណួរដែលមេធាវីការពារសួរចុងក្រោយនេះទេ។ មេធាវីអាចតាំងសំណួរផ្សេងទៀតបាន។

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងសួរបន្តទៅទៀត។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោក ឆាំង យុ ពីម្សិលមិញលើកឡើងថា សកម្មភាពមួយដ៏សំខាន់របស់ ឌី.ស៊ី.ខេម គឺការខិតខំស្វែង-- គឺការចង់ឲ្យបានមានការជំនុំជម្រះក្តីមួយប្រកបដោយឯករាជ្យទៅលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើអ៊ីចឹង មែនទេលោក?

**ឆ៖** ជាការពិតបាទ។

[១៤:០៦:៤៣]

**ស៖** តើបុគ្គលជាក់លាក់ណាមួយដែល ឌី.ស៊ី.ខេម ចង់ឲ្យមានការផ្តន្ទាទោសនោះ?

**លោក អាប់ឌុលឡាក់ ចារីក៖**

លោកប្រធាន ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ គឺសំណួរនេះមិនពាក់ព័ន្ធទេ។

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ប្រសិនជាណាខ្ញុំ សូមលើកឡើងដោយសារវាពាក់ព័ន្ធទៅនឹងការប្រមូលភស្តុតាងអ្វីដែល ស៊ី.ឌី.ខេម ទទួលបាន គឺជាបញ្ហាសំខាន់នៅក្នុងរឿងនេះ។ ដូច្នេះ ខ្ញុំសួរថា តើ ឌី.ស៊ី.ខេម មានបានគិតថាមានបុគ្គលជាក់លាក់ណាមួយ ដែលត្រូវប្រឈមមុខទៅនឹងការជំនុំជម្រះនោះទេ? ជាពិសេសខ្ញុំសួរលោក ឆាំង យុ ដើម្បីធ្វើការសំអាងថា តើមានការយល់ឃើញថាបុគ្គលណាត្រូវប្រឈមនឹងការផ្តល់ផ្តន្ទាទោសនេះ។ ដូចនេះ ខ្ញុំសូមជំទាស់ទៅនឹងការជំទាស់របស់សហព្រះរាជអាជ្ញា។

[០៩:០៧:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១០:០៤]

**ប្រធានអង្គជំនុំ៖**

បាទ ពាក់ព័ន្ធនឹងបញ្ហាសួរ ហើយនិងបញ្ហាជំទាស់អម្បាញ់មិញនេះ ឃើញថាមិនទាន់មានភាព

ច្បាស់លាស់ទេ ហើយដើម្បីឲ្យកាន់តែច្បាស់លាស់ទៀត អង្គជំនុំជម្រះសូមប្រគល់ភារជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌ ដើម្បីសួរបញ្ជាក់បញ្ហានេះបន្ថែម ចំពោះមេធាវីការពារក្ដី។

សូមអញ្ជើញលោកស្រីចៅក្រម!

[១៤:១០:២៩]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

សូមអរគុណលោកប្រធាន។ មេធាវីការពារក្ដី នួន ជា អង្គជំនុំជម្រះយល់ឃើញថា លោកគួរតែរៀបសំណួរឡើងវិញ ក្នុងនាមសាក្សីជានាយករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក យុ ឆាំង មិនដែលបង្ហាញជាជំហរជាសាធារណៈថា អ្នកណាដែលត្រូវតែផ្ដន្ទាទោសនៅចំពោះមុខអង្គជំនុំជម្រះនោះទេ។ គឺគាត់មិន-- ឌី.ស៊ី.ខេម មិនដែលបង្ហាញជំហរជាសាធារណៈនោះទេ។ តើនេះពាក់ព័ន្ធទៅនឹងសំណួររបស់លោក ការបារម្ភរបស់លោក--

**លោក ហ្សាស្តេី ប៉ោ៖**

លោកស្រីចៅក្រម ខាតវ៉ាយថ៌ បើសិនណាខ្ញុំ-- លោកស្រី-- ខ្ញុំត្រេកអរណាស់បើសិនខ្ញុំរៀបសំណួរដូចដែលលោកស្រីបានរៀបឡើង ដើម្បីសួរទៅសាក្សីម្ដងវិញ--

[១៤:១១:២៣]

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

**ស៖** លោក យុ ឆាំង ក្នុងនាមលោកជានាយកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា តើលោកមានដែលធ្វើសេចក្ដីថ្លែងជាសាធារណៈណាមួយ ថាតើមានមនុស្សជាក់លាក់ណាដែលត្រូវប្រឈមមុខនឹងការចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក ដែរឬទេ ក្នុងឋានៈលោកជាប្រធានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា?

**លោក ឆាំង យុ៖**

**ឆ៖** សូមអរគុណលោកស្រីចៅក្រម។ ខ្ញុំបាទធ្លាប់និយាយថា មេដឹកនាំខ្មែរក្រហមណាមួយដែលប្រព្រឹត្តបទល្មើស ហើយធ្វើឲ្យប្រជាជនកម្ពុជាស្លាប់បាត់បង់ជីវិត គួរតែត្រូវយកមកធ្វើការវិនិច្ឆ័យទោសនៅមុខអង្គតុលាការមួយ។ ខ្ញុំធ្លាប់និយាយនេះច្រើនដង មិនមែនតែម្ដងទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីអាចបន្តសំណួរតទៅទៀតបានហើយ!

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

មេធាវីការពារក្តីសូមអរគុណលោកប្រធាន សូមអរគុណលោក ឆាំង យុ ចំពោះចម្លើយនេះ។

**ស៖** ការស្វែងរកការពិត គឺជាអ្វីដែល ឌី.ស៊ី.ខេម បានធ្វើការបោះពុម្ពផ្សាយ។ តើនេះជាការពិតទេ?

[១៤:១២:៤៩]

**លោក ឆាំង យុ៖**

**ឆ៖** ការពិតបាទ។

**ស៖** តើជាការពិតទេ ដែលលោកបានសរសេរនូវអត្ថបទមួយចំនួននៅក្នុងទស្សនាវដ្តីនេះ?

**ឆ៖** ជាការពិតបាទ។

**ស៖** ហើយនៅក្នុងទស្សនាវដ្តីស្វែងរកការពិតនេះ តើលោកមានការអំពាវនាវឲ្យមានការផ្តន្ទាទោសមកលើរូប នួន ជា ដែរឬទេ?

[១៤:១៣:២៣]

**ឆ៖** ដូចខ្ញុំជម្រាបលោកចៅក្រមអ៊ីចឹង គឺខ្ញុំចង់ឲ្យមេដឹកនាំខ្មែរក្រហមណាមួយដែលតុលាការរកឃើញថា មានកំហុសយកមកធ្វើការវិនិច្ឆ័យទោស។

**ស៖** ខ្ញុំយល់អំពីជំហររបស់លោកហើយលោក ឆាំង យុ។ ប៉ុន្តែសំណួររបស់ខ្ញុំ ថាតើលោកដែលនិយាយចំៗតែម្តងមកលើកូនក្តីរបស់ខ្ញុំ នៅក្នុងពេលដែលលោកសរសេរអត្ថបទនៅក្នុងទស្សនាវដ្តីស្វែងរកការពិត ដែលត្រូវកូនក្តីខ្ញុំប្រឈមមុននឹងការផ្តន្ទាទោស ចំពោះមុខតុលាការនេះដែរទេ?

**ឆ៖** ខ្ញុំធ្លាប់បានសរសេរ និងនិយាយប៉ុន្តែខ្ញុំមិនចាំថានៅក្នុងអត្ថបទណាមួយ នៅក្នុងលេខទីប៉ុន្មាន តែខ្ញុំធ្លាប់និយាយ។ បាទ ខ្ញុំធ្លាប់និយាយ។

[១៤:១៤:១៤]

**ស៖** នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានចាប់ដំណើរការរបស់ខ្លួននៅដើមដំបូងបំផុតនោះ ថាតើលោក ឬក៏អ្នកណាម្នាក់ទៀតនៅមជ្ឈមណ្ឌលឯកសារកម្ពុជារំពឹងថា មន្ត្រីធ្វើការនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យត្រូវនាំខ្លួនមកផ្តន្ទាទោសដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលអស់ក្តីសង្ឃឹមថា ថ្ងៃណាមួយនឹងមានតុលាការនេះដើម្បីយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសទេ។ អ៊ីចឹងតាំងពីដំបូងឡើង គឺខ្ញុំគិតអ៊ីចឹង។ ខ្ញុំចង់មានតុលាការមួយ ហើយខ្ញុំដឹងខ្លួនឯង

ថា ខ្ញុំមិនមែនជាតុលាការ មិនមែនជាចៅក្រម មិនមែនជាអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់។ អ៊ីចឹងហើយ ខ្ញុំបានកម្រិតតួនាទីរបស់ខ្ញុំត្រឹមតែដើរប្រមែប្រមូលឯកសារ ដើម្បីឱ្យសាធារណជន ឱ្យតុលាការមើល ធ្វើការវិនិច្ឆ័យទោស។ អ៊ីចឹងតាំងពីថ្ងៃទីមួយ បាទថ្ងៃទីមួយដែលខ្ញុំចាំ គឺថ្ងៃសុក្រ ទី១៣ ខែមករា ឆ្នាំ៩៥ គឺជាថ្ងៃដែលខ្ញុំចាប់ផ្ដើមធ្វើការដំបូងនៅសាកលវិទ្យាល័យយែល គឺខ្ញុំមានគំនិតអ៊ីចឹង។ ខ្ញុំចង់ឱ្យមានតុលាការនេះនៅស្រុកខ្មែរ ដើម្បីវិនិច្ឆ័យទោសអ្នកណាមួយឱ្យ ដែលទទួលខុសត្រូវអំពីការសម្លាប់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។

**ស៖** សូមអរគុណលោក។ លោកបាននិយាយថា លោកបានប្រមូលឯកសារនានា ហើយឯកសារនេះគឺថាសម្រាប់បម្រើបម្រាស់សាធារណជននិងតុលាការ។ តើលោកមានចាត់វិធានការជាក់លាក់ណាមួយ ដើម្បីត្រៀមទុកឱ្យតុលាការនេះប្រើប្រាស់-- តុលាការណាមួយ ដោយសារពេលនោះគឺមិនមទាន់មាន អ.វ.ត.ក នៅឡើយ។ តើមានអ៊ីចឹងទេ?

[១៤:១៦:០៦]

**ឆ៖** នៅពេលនោះមានអ្នកសិក្សាស្រាវជ្រាវជាច្រើន ដែលចាប់អារម្មណ៍លើបញ្ហានេះ ហើយខ្ញុំមានសំណើជាច្រើនពីជាបុគ្គល មានពីអង្គការសហប្រជាជាតិ មានពីមន្ត្រីច្បាប់នានា ដែលចាប់អារម្មណ៍លើបញ្ហានេះ ហើយគេបានស្នើឱ្យខ្ញុំរៀបចំ ឬក៏រក-- ជួយរកឯកសារផ្សេងៗ ដើម្បីគេយកទៅធ្វើការសិក្សាស្រាវជ្រាវ។ នៅក្នុងនោះគឺមានលោក ស្ទីវ ហេដឌ័រ ដែរ ដែលគាត់ចាប់អារម្មណ៍ទៅលើការសិក្សាស្រាវជ្រាវអំពីបញ្ហានេះ ហើយខ្ញុំក៏បានជួយគាត់អស់ពីដៃពីជើង ប្រមែប្រមូលឯកសារជូនទៅគាត់ ដើម្បីគាត់ធ្វើការជាសរសេរ ឬវិភាគទៅលើឯកសារទាំងអស់នេះ។

**ស៖** ចម្លើយនេះគឺមិនឆ្លើយតបទៅនឹងសំណួរខ្ញុំទាំងស្រុងនោះទេ។ នៅពេលដែលលោកប្រមូល និងចងក្រងឯកសារទាំងអស់នេះ ថាតើលោកមានចាត់វិធានការពិសេសណាមួយ ដើម្បីរៀបចំឱ្យសម្រាប់ការប្រើប្រាស់នូវឯកសារនេះ ដោយតុលាការណាមួយដែរឬទេ?

**ឆ៖** ខ្ញុំមិនច្បាស់នឹងសំណួរ។ លោកចង់និយាយអំពីដូចជាកាលពីលើកមុនអ៊ីចឹង សំណុំរឿង សំណុំអី ខ្ញុំមិនច្បាស់ សំណួរនេះលោកចង់និយាយថា ខ្ញុំបានមានគម្រោងរៀបជាសំណុំរឿងរបស់បុគ្គលម្នាក់ៗសម្រាប់តុលាការណាមួយ? លោកចង់សួរថាអ៊ីចឹង?

**ប្រធានអង្គជំនុំ៖**

លោកមេធាវីសួរ តាំងសំណួរម្ដងទៀត ហើយអាចសម្រួលសំណួរហ្នឹងឱ្យកាន់តែងាយយល់

ហើយនិងច្បាស់។ ចៀសវាងការឆ្លើយមានការភ័ន្តច្រឡំ។ ស្តាប់ច្រឡំ នាំឲ្យការឆ្លើយភ័ន្តច្រឡំ។

[១៤:១៧:៥៤]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** ខ្ញុំសូមសួរត្រង់នេះ ថាតើលោកមានបានប្រមូលឯកសារ ហើយរៀបចំជាសំណុំឯកសារទាក់ទងទៅនឹងបុគ្គលជាក់លាក់ណាម្នាក់ដែរឬទេ?

**លោក ឆាំង យុ៖**

**ឆ៖** ខ្ញុំបានរៀបសំណុំឯកសារនេះទៅតាមសំណើរបស់អ្នកសិក្សាស្រាវជ្រាវ ដែលពាក់ព័ន្ធទៅនឹងបុគ្គលដែលអ្នកសិក្សាស្រាវជ្រាវយល់ថា គេចាប់អារម្មណ៍ក្នុងការធ្វើការវិនិច្ឆ័យទៅលើបុគ្គលនោះ។

**ស៖** លោកអាចរៀបរាប់អំពីឈ្មោះបុគ្គលដែលគេដាក់រៀបចំជាសំណុំឯកសារហ្នឹងបានទេ?

**ឆ៖** មានច្រើនបាទ។ មានច្រើន ខ្ញុំអាចរៀបរាប់បានច្រើន ដូចជា ឧទាហរណ៍ មានអ្នកខ្លះសំណើសុំរកបងប្អូនដែលបានស្លាប់ ឬក៏ប្រធានភូមិ ប្រធានឃុំ ដែលខ្លួនពេញចិត្ត មានរហូតដល់ថ្នាក់កម្មាភិបាល ថ្នាក់មូលដ្ឋាន មានអ្នកខ្លះជា-- ខ្ញុំអាចស្វែងរកឯកសារចំពោះទាក់ទងនឹងមន្ត្រីសន្តិសុខនានាដែលខ្លួនធ្លាប់ពន្ធនាគារ រហូតមកដល់អ្នកផ្សេងៗទៀត ដែលមាននៅជួរថ្នាក់ដឹកនាំ មានលោក អៀង សារី ឬក៏អ៊ំវ៉ាន់, អ៊ំនួន, បងហែម មានមនុស្សផ្សេងៗទៀត។ នៅក្នុងនោះគឺមានតាមសំណើគឺយើងបានប្រមូល ហើយយើងបានថតចម្លងឯកសារដែលមានស្រាប់ដាក់ចូលទៅក្នុងកន្លែងនោះ ដើម្បីងាយស្រួល ពីព្រោះទាំងអស់នេះសុទ្ធសឹងតែជាមនុស្សភាគច្រើនចាប់អារម្មណ៍។ អ៊ីចឹង បើសិនជាមានអ្នកសិក្សាស្រាវជ្រាវផ្សេងៗទៀតមក យើងងាយស្រួល គឺថាយើងឲ្យឯកសារហ្នឹងតែម្តងទៅ។ ដូចជាលោក ស្ទីវ ហេដឌ័រ គាត់ឲ្យខ្ញុំប្រមូលឯកសារទាំងឡាយណាដែលទាក់ទងនឹងទូរលេខ។ ហើយខ្ញុំចាំថា អង្កាល់នោះខ្ញុំប្រមូលបានដល់ទៅពីរទូបាទ។ ពីរទូហ្នឹងគឺមិនមែនប្រមូលពីកន្លែងផ្សេងទេ មកពីក្នុងទិន្នន័យដែលយើងមានស្រាប់ គ្រាន់តែខ្ញុំជួយសម្រួលការសិក្សាស្រាវជ្រាវរបស់គាត់។ ហើយពីរទូនេះគាត់យកទៅសរសេរចេញជាសៀវភៅមួយដែលមានចំណងជើងថា *"សេវេន ខេនឌីដេត"* ហើយយើងក៏បានបោះពុម្ពឯកសារសៀវភៅហ្នឹងទៀត។ អ៊ីចឹងជាទូទៅអ្នកសិក្សាស្រាវជ្រាវមានសំណើខុសៗគ្នា ហើយដោយសារតែសំណើនេះជាទូទៅ ជាសំណើដែលៗចាប់អារម្មណ៍ អ៊ីចឹងយើងក៏ទុកឯកសារនេះថតចម្លងមួយផ្នែក

E1/38.1

ទៀត ដើម្បីថ្ងៃក្រោយបើសិនជាមានអ្នកសួរមានហើយស្រេចតែម្តង។

ខ្ញុំសូមជូនឧទាហរណ៍មួយទៀតដូចជាការសិក្សារបស់លោក ស៊្ទីវ ហេដឌ័រ អ៊ីចឹងនៅពេលដែលខាងតុលាការចង់ត្រូវការរឿងឯកសារតួលេខ យើងមានហើយស្រេច ខ្ញុំផ្តល់ជូនសឹងតែតិចជាងពីរម៉ោង ពីព្រោះយើងបានមានអានេះរួចស្រេចទៅហើយនៅក្នុងទូរបស់យើង តាមរយៈការសិក្សាស្រាវជ្រាវរបស់លោក ស៊្ទីវ ហេដឌ័រ។

[១៤:២០:៤៦]

**ស៖** សំណួរបន្តទៅទៀតនោះថា តើនៅ ឌី.ស៊ី.ខេម នៅពេលនោះនៅក្នុងទសវត្សរ៍ជាង៩០នេះ តើមានសំណុំឯកសារ ឬការប្រមូលឯកសារណាមួយដែល ឌី.ស៊ី.ខេម ហៅថា "សំណុំឯកសារសម្រាប់ នួន ជា" តើមានអ៊ីចឹងទេ?

**ឆ៖** យើងមាន *ហ្វូលឌ័រ* មួយដែលមានឈ្មោះ នួន ជា ហើយឯកសារសំណុំរឿង នួន ជា នេះក៏យើងបានប្រគល់ជូនទៅខាងសហ-- ក្រុមមេធាវីការពារកូនក្តីដែរ គឺលោក វីរ៉ាត រ៉ូជ្ជី បានស្នើឲ្យខ្ញុំប្រមូលឯកសារទាំងឡាយណាដែលមានពាក់ព័ន្ធ បន្ថែមទៅលើអ្វីដែលខ្ញុំបានធ្វើពីមុនហើយ យកមកជូនគាត់។ ហើយយើងបានរៀបចំធ្វើ ស្កេនវាស៊ីឌី ដូចខ្ញុំប្រាប់កាលពីម្សិលមិញអ៊ីចឹង យើងឲ្យទាំងអស់អ្វីដែលគាត់សុំរួមទាំងឯកសារណាដែលពាក់ព័ន្ធទៅនឹងតួលេខ ទៅនឹង អ៊ំវ៉ាន់,អ៊ំនួន ឯកសារណាដែលទាក់ទងទៅនឹងរណ្តៅសាកសព និងផ្សេងៗទៀត គឺយើងបានប្រគល់មកខាងក្រុមមេធាវីការពារជនចុងចោទ ពីព្រោះគាត់សុំឲ្យខ្ញុំជួយសិក្សាស្រាវជ្រាវ រួមទាំងបន្ថែម--

[១៤:២១:៥១]

**ស៖** លោក ឆាំង យុ ខ្ញុំសូមរំខានលោក ដោយសារខ្ញុំសល់ពេលតិចពេកនៅពេលរសៀលនេះ។ ខ្ញុំយល់អំពីចម្លើយរបស់លោកហើយ លោកថាមានសំណុំឯកសារសម្រាប់ នួន ជា។ តើលោកអាចបញ្ជាក់ទេថា តើសំណុំឯកសារនេះបង្កើតឡើងដំបូងបំផុតនៅពេលណា អាចនៅក្នុងឆ្នាំណា បើលោកចាំ?

**ឆ៖** ចាប់តាំងពីយើងកកើតមជ្ឈមណ្ឌលឯកសារកម្ពុជាឆ្នាំ៩៥ គឺមានសំណើជារាងរហូត។ អ៊ីចឹង ខ្ញុំមិនចាំថាក្នុងរយៈពេលណាមួយទេ។ ហើយការសំណើសុំនេះបង្កឲ្យខ្ញុំមានគំនិតមួយទុកឯកសារមួយដុំ ដើម្បីងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ ដោយសារថាតែពេលនោះយើងមានកន្លែងតូច មានមនុស្សតិច។ អ៊ីចឹងគំនិតនេះអាចមានជាយូរមកហើយ មិនមែនថ្មីៗទេ ដោយសារថាមានអ្នកសារ-

ព័ត៌មានក្តី អ្នកផ្សេងៗក្តី។ ហើយខ្ញុំទម្លាប់និយាយទៅលើឯកសារ។ អ៊ីចឹងវាជួយឲ្យខ្ញុំដែរ បើសិនជាមានសារព័ត៌មានសួរអំពីបញ្ហាណាមួយ ខ្ញុំយោងឯកសារបានខ្ញុំនិយាយ។ អ៊ីចឹងឯកសារនេះអាចមានយូរហើយ។ សំណុំនេះ តាមការស្នើសុំរបស់សាធារណជន។

[១៤:២៣:០២]

**ស៖** ខ្ញុំយល់លោកមិនច្រឡំទេ គឺថាសំណុំឯកសាររបស់ នួន ជា គឺត្រូវរៀបចំឡើងដោយមានអ្នកស្នើសុំមកពីខាងក្រៅ អ៊ីចឹងមែនទេលោក?

**ឆ៖** បាទ។

**ស៖** ហើយបន្ទាប់ពីលោកបង្កើតហ្វូលឌ័រ សម្រាប់ នួន ជា នេះ? តើគោលបំណងតែមួយគត់សម្រាប់ហ្វូលឌ័រ នួន ជា គឺសម្រាប់អ្នកសិក្សាស្រាវជ្រាវមកពីខាងក្រៅ ដែលស្នើសុំនូវឯកសារនៅក្នុងហ្វូលឌ័រ នេះមែនទេ?

**ឆ៖** អ្នកខាងក្នុងក៏សុំដែរ។ គឺដូចខ្ញុំជម្រាបពីព្រឹកមិញអ៊ីចឹង ខាងគណៈបក្សប្រឆាំងក៏ធ្លាប់សុំដែរ ខ្ញុំធ្លាប់ជូនគាត់មួយពាន់សន្លឹកទៅតាមសំណើរបស់គាត់អំពីលេខឯកសារដែលគាត់ស្នើសុំ។

**ស៖** នៅមជ្ឈមណ្ឌលឯកសារកម្ពុជា តើលោកដែលវិភាគទៅលើខ្លឹមសារនៅក្នុងហ្វូលឌ័រឯកសារ របស់ នួន ជា ទាក់ទងទៅនឹងភស្តុតាងដាក់បន្ទុក ឬក៏ព័ត៌មានដាក់បន្ទុក ឬក៏ព័ត៌មានដោះបន្ទុក ឬក៏ព័ត៌មានអព្យាក្រឹតដែរឬទេ?

**ឆ៖** ទីមួយ ខ្ញុំស្គាល់ខ្លួនឯងច្បាស់ណាស់ ខ្ញុំមិនមែនជាមេធាវីទេ។ អ៊ីចឹងខ្ញុំមិនសូវចាប់អារម្មណ៍ពីរឿងវិភាគទៅក្នុងផ្លូវច្បាប់ ហើយទីមួយទៀត ខ្ញុំមិនមែនជាអ្នកច្បាប់។ ជាទូទៅ ខ្ញុំចូលចិត្តអានឯកសារនៅក្នុងន័យប្រវត្តិសាស្ត្រ ប៉ះកន្លែងខ្លះ ខ្ញុំចាប់អារម្មណ៍ ខ្ញុំក៏សួរអ្នកសិក្សាស្រាវជ្រាវដូចជាឧទាហរណ៍នៅក្នុងឯកសាររបស់គាត់ មានឯកសារខ្លះដែលខ្ញុំមិនយល់និយាយអំពី ម-២៥០, ៨១, ៨២, ៨៩ អ៊ីចឹង ខ្ញុំចាប់ផ្តើមអារម្មណ៍ ហើយក៏សួរគាត់។ ប៉ុន្តែនៅក្នុងន័យថា ពិភាក្សាជាផ្លូវច្បាប់ ខ្ញុំមិនដែលទាល់តែសោះ ពីព្រោះស្គាល់ខ្លួនឯងថា ខ្ញុំមិនមែនជាមេធាវី មិនមែនជាអ្នកច្បាប់ទេ។

[១៤:២៥:១២]

**ស៖** អ៊ីចឹងបើតាមដែលខ្ញុំយល់ពីចម្លើយរបស់លោក គឺលោកខ្លួនឯងផ្ទាល់មិនដែលវិភាគ ឬក៏វាយតម្លៃទៅលើឯកសារទាំងអស់នេះ ថាតើវាមានព័ត៌មានដាក់បន្ទុកនោះទេ។ អ៊ីចឹងមែនទេ?

**ឆ៖** ភាសាអង់គ្លេស *ខនវីអូហ្វស៊ីធី* ខ្ញុំឆ្ងល់ ខ្ញុំចាប់អារម្មណ៍ ហើយលោកអាចគិតថា ជាការ

វិភាគក៏បាន ព្រោះជួនកាល ខ្ញុំឃើញឯកសារខ្លះមានស៊ីញ៉េមានអីអ៊ីចឹង ខ្ញុំចាប់អារម្មណ៍មែនទែន។ អ៊ីចឹងខ្ញុំស្វែងយល់ថាវាយ៉ាងម៉េច ព័ត៌មានទាំងអស់នេះ? ដែលខ្ញុំសាកសួរអ្នកជំនាញផ្សេងៗ។

**ស៖** យើងមិនគួរបន្ថែមពាក្យទីបួនទៀត ទាក់ទងទៅនឹងឯកសារនៅ ឌី.ស៊ី.ខេម នោះទេ។ អ៊ីចឹង ខ្ញុំរៀបសំណួរឡើងវិញ គឺខ្ញុំសុំឲ្យអ្នកបកប្រែភាសាខ្មែរប្រើពាក្យ-- ភាសាអង់គ្លេសថា "*អាន់ណាឡាយ*" គឺវិភាគ ថាតើលោកមានវិភាគទៅលើឯកសារទាំងអស់នេះ ក្រែងឯកសារទាំងអស់នេះវាមានព័ត៌មានណាមួយដែលជាព័ត៌មានដាក់បន្ទុកដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសុំជំទាស់ចំពោះសំណួរនេះ សំណួរនេះមិនអាចទទួលយកបាននោះទេ។

[១៤:២៦:២៧]

**ប្រធានអង្គជំនុំ៖**

ជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរចុងក្រោយនេះទេ។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** នៅក្នុងការប្រមូលភស្តុតាងដោយមជ្ឈមណ្ឌលឯកសារកម្ពុជានេះ ថាតើខ្លួនលោកផ្ទាល់ ឬក៏ ឌី.ស៊ី.ខេម ដែលផ្តោតទៅលើព័ត៌មានណា ដែលពាក់ព័ន្ធទៅនឹងបុគ្គលជាក់លាក់ណាម្នាក់ដែរឬទេ?

**ឆ៖** ខ្ញុំយល់ថាច្បាប់មិនបាន មិន *ម៉ូណូប៉ូលី* ពាក្យភស្តុតាងទេ។ អ៊ីចឹងជាទូទៅ ចំពោះយើងៗស្វែងរកការពិត អ្វីដែលបានកើតឡើងពីអតីតកាល។ អ៊ីចឹងលោកអាចហៅថាជាភស្តុតាងក៏បាន យើងលោកអាចហៅថាជាយ៉ាងម៉េចក៏បានដែរ។ អ៊ីចឹង ខ្ញុំមានការចាប់អារម្មណ៍ក្នុងការចង់ដឹងការពិតនៅក្នុងន័យនេះ ហើយគ្រប់មនុស្សទាំងអស់នៅក្នុងឯកសារដែលខ្ញុំអាន មិនថាជាថ្នាក់ខ្ពស់ ថ្នាក់ទាប ថ្នាក់ភូមិ ថ្នាក់ឃុំ ខ្ញុំចាប់អារម្មណ៍ដូចៗគ្នា។ ដូចខ្ញុំភ្លេចជម្រាបលោកអ៊ីចឹង មានៗសំណុំរឿងផ្សេងៗទៀតដែលខ្ញុំចាប់អារម្មណ៍ ហើយមានការស្នើសុំ។ ខ្ញុំក៏ចាប់ផ្តើមអានឯកសារទាំងអស់នោះជាញឹកញាប់។

[១៤:២៨:១៣]

**ស៖** ខ្ញុំឮលោកឡើងថានៅ ឌី.ស៊ី.ខេម មិនប្រើពាក្យ "ភស្តុតាង" ទេ មិនបានប្រើពាក្យនេះទេ។ ហើយថា ខ្ញុំដឹងថា អនុប្រធានរបស់លោកក៏បានលើកឡើងប្រហាក់ប្រហែលគ្នានេះដែរ កាលពីសប្តាហ៍

មុននោះ។ បើសិនណាជាខ្ញុំបង្ហាញឯកសារផែនការយុត្តិសាស្ត្រសម្រាប់ឆ្នាំ២០០៩ ទៅ២០១១ ដែលអនុប្រធាន របស់លោកបានប្រើពាក្យ “*អេវីឌិន*” គឺ “ភស្តុតាង” នេះតែម្តង។

**ឆ៖** ខ្ញុំថា មានការច្រឡូលច្របល់បន្តិចក្នុងការវិភាគពាក្យនេះ។ ឯកសារនោះ គឺខ្ញុំអ្នកសរសេរផ្ទាល់ បាទនេះរូបថតបីសន្លឹក បើសិនជាលោកបង្ហាញទាំងអស់មានរូបថតបីសន្លឹក ហើយមានរូបថតខ្ញុំមួយសន្លឹក ដូចជាថតនៅក្នុងឆ្នាំ៩៥ នៅខេត្តតាកែវ។ ខ្ញុំចាំច្បាស់ណាស់ឯកសារនេះ ហើយដូចខ្ញុំជម្រាបលោកអ៊ីចឹង ច្បាប់មិនបាន *ម៉ូណូប៉ូលី* ពាក្យ “ភស្តុតាង” ទេ។ ពាក្យនេះ គឺត្រូវបានប្រើឡើងដោយអ្នកសង្គមវិទ្យា អ្នកប្រវត្តិសាស្ត្រ ដើម្បីកំណត់បញ្ជាក់រឿងអតីតកាល-- ការពិតនៃអតីតកាលមួយ។ ហើយយើងប្រើពាក្យនេះនៅក្នុងន័យដូច្នេះ។ ហើយបើសិនជាលោកមើលទៅលើសំណេរផ្សេងៗទៀត ដែលយើងសរសេរ១៧ឆ្នាំ មានរាប់រយរាប់លានពាក្យ ប៉ុន្តែលោកបានរកឃើញពាក្យមួយនេះនៅក្នុង*ផូស្ទ័រ* ដែលខ្ញុំធ្វើ។ អ៊ីចឹងចំពោះខ្ញុំ ខ្ញុំគិតអ៊ីចឹង លោកអាចប្រហែលជាគិតផ្សេង ហើយខ្ញុំគិតថាច្បាប់មិន-- *ឌី ឡូ ដឹសណេត ម៉ូណូប៉ូលី ធូវើត អេវីឌិន* (និយាយភាសាអង់គ្លេស)។ អ៊ីចឹងខ្ញុំដែលជាអ្នក *សុះស្យូលសាយអុិន* ជាអ្នកស្រាវជ្រាវ ខ្ញុំគិតផ្សេង ហើយការដែលយើងយកមកមើល យកមកអាននេះ គឺយើងចង់ដឹងថា យើងហៅប្រើពាក្យថា “*អាន់ណាឡាយ*” ក៏បាន “សិក្សាស្រាវជ្រាវ”ក៏បាន ព្រោះយើងចង់ដឹងថាហេតុអីនៅក្នុងបរិបទប្រវត្តិសាស្ត្រមានអំពើនេះកើតឡើង? ហើយមូលហេតុដែលយើងចង់ដឹងពីព្រោះយើងមិនចង់ឲ្យអំពើនេះកើតឡើង។ ហើយមូលហេតុដែលយើងមិនចង់ឲ្យអំពើនេះកើតឡើងពីព្រោះខ្ញុំផ្ទាល់បានរស់នៅឆ្លងកាត់របបនេះ។ អ៊ីចឹងខ្ញុំមានន័យអ៊ីចឹង។ តែលោកបកស្រាយទៅផ្សេងមួយទៀត ជារឿងមួយផ្សេងទៀតបាទ។

[១៤:៣០:១៩]

**ស៖** សូមអរគុណលោក ឆាំង យុ។ ខ្ញុំថា មានការយល់ច្រឡំ នៅមានការយល់ច្រឡំ ខ្ញុំបាននិយាយជាមួយនឹងអនុប្រធានរបស់លោក គឺលោក ដារ៉ា អំពីភាពគម្រោងនៃការទទួលទទួលខុសត្រូវថាតើលោកអាចនិយាយអំពី “*អាក់ខោនធីប៊ីលីធី ប្រូចិច*” នេះបានទេ?

**ឆ៖** កម្មវិធីនេះ គឺយើងដូចខ្ញុំបានឃើញដែរ គឺយើងមានកម្រងសំណួរ ហើយកម្រងសំណួរនេះគឺយើងបានផ្ញើប្រគល់ជូនទៅខាងតុលាការ ខាងចៅក្រមស៊ើបអង្កេត ហើយកម្រងសំណួរនេះធ្វើឡើងដោយទីប្រឹក្សារបស់ខ្ញុំម្នាក់ គឺលោក ចន ឆរឈីអារី ហើយយើងក៏បានពិភាក្សាជាមួយនឹងមន្ត្រីសិទ្ធិមនុស្សអន្តរជាតិផ្សេងៗទៀត។ គឺយើងធ្វើយ៉ាងណាដើម្បីបញ្ចៀស ក្នុងការសួរសំណួរមនុស្សឲ្យដាក់

កំហុសខ្លួន ឬក៏រំលោភសិទ្ធិរបស់គេ ពីព្រោះយើងបានដឹង អ្នកទាំងអស់នេះតាមរយៈព័ត៌មានដែលយើងមានរួចមកហើយ។ អ៊ីចឹងបានន័យថា ចំពោះដែលយើងចាប់អារម្មណ៍រឿង ដែលទាក់ទងទៅនឹង--

**ស៖** លោក ឆាំង យុ សូមអធ្យាស្រ័យខ្ញុំរំខានលោក។ ខ្ញុំមិននិយាយអំពីរបៀបរបប ឬក៏ថា នីតិវិធីរបៀបធ្វើការទេ ខ្ញុំនិយាយពីគោលបំណងនៃគម្រោងជំរុញឲ្យមានការទទួលខុសត្រូវនេះ។ សូមផ្តល់ចម្លើយឲ្យខ្លីមកខ្ញុំលោក។

[១៤:៣១:៤១]

**ឆ៖** យើងចង់ដឹងអំពីប្រវត្តិសាស្ត្រ ដែលបានកើតឡើងនៅក្នុងបទឧក្រិដ្ឋនានា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**ស៖** កាលពីសប្តាហ៍មុននេះ ខ្ញុំបានបង្ហាញឯកសារដែលអាចរកឃើញនៅលើគេហទំព័ររបស់អង្គការលោក។

ខ្ញុំសូមដកស្រង់៖ "គម្រោងនេះ គឺពាក់ព័ន្ធទៅនឹងករណីប្រឆាំងទៅនឹងមេដឹកជាន់ខ្ពស់ ដែលនៅរស់រានមានជីវិតរបស់កម្ពុជាប្រជាធិបតេយ្យ ដើម្បីបង្ហាញនូវខ្សែសង្វាក់នៃការបញ្ជា ស្ថាប័នរបស់កម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យមេដឹកនាំជាន់ខ្ពស់ទទួលខុសត្រូវទៅលើអ្វីដែលបានកើតឡើងនេះ"។ បញ្ចប់ការដកស្រង់សម្តី។

ខ្ញុំសូមសួរទៅលោកថា គោលបំណងមួយនៃគម្រោងជំរុញឲ្យមានទទួលខុសត្រូវ គឺដើម្បីឲ្យមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ទទួលខុសត្រូវទៅលើការកាប់សម្លាប់រង្គាលដែលបានកើតប្រកាន់ឡើងនោះ។ សំណួររបស់ខ្ញុំ ថាតើលោក ឬក៏ ឌី.ស៊ី.ខេម នេះមានរកមើលព័ត៌មានណាដែលពាក់ព័ន្ធទៅនឹងមេដឹកនាំជាន់ខ្ពស់ ចំពោះការសម្លាប់រង្គាលនេះដែរឬទេ?

[១៤:៣៣:០៨]

**ឆ៖** យើងមានបំណងនៅក្នុងគម្រោងនេះ ប្រមូលព័ត៌មានប្រវត្តិសាស្ត្រ ដើម្បីផ្តល់ជូនតុលាការជួយដល់តុលាការរកឲ្យឃើញជនណាដែលប្រព្រឹត្តបទល្មើសនៅក្នុងសម័យនោះ។ អ៊ីចឹងពេលដែលយើងចេញទៅនេះ ដូចលោក វ៉ាន់ថាន់ ពៅដារ៉ា បានជម្រាបលោកអ៊ីចឹង គឺយើងផ្អែកទៅលើឯកសារដែលយើងមាននៅក្នុងដៃ។ ហើយឯកសារនេះគឺជាឯកសារប្រវត្តិរូប អ៊ីចឹងតាមរយៈឯកសារនេះ គឺយើងទៅសួរមនុស្សហ្នឹង ថាកាលពីសម័យខ្មែរក្រហមនៅកន្លែងណាធ្វើអីខ្លះ? ហើយជាព័ត៌មានជាប្រវត្តិសាស្ត្រ ហើយព័ត៌មាននេះ យើងដឹង យើងគិតថា ព័ត៌មានអាចជួយសម្រួលការងាររបស់តុលាការឲ្យកាន់តែ

លឿន។ ប៉ុន្តែយើងមិនមែនទៅដៅរកមនុស្សនេះ ឬមនុស្ស “ក” ឬ “ខ” ទេ គឺដៅទៅលើមនុស្សដែលមានឈ្មោះនៅក្នុងឯកសាររបស់យើងនៅក្នុងគេហទំព័រ*ដេតាបេស* ប្រវត្តិរូប ហើយតាមដែលខ្ញុំចាំមានប្រហែលជាពម៉ឺននាក់ឯណោះ។ នៅក្នុងចំណោមមនុស្សទាំងអស់នេះ ដែលយើងបានទៅរកអ្នកខ្លះក៏ស្លាប់បាត់បង់ជីវិត អ្នកខ្លះក៏នៅរស់ អ្នកខ្លះក៏សល់សាច់ញាតិ ហើយយើងក៏ចេះតែសម្ភាសសួរទៅ។ ហើយព័ត៌មានទាំងអស់នេះ យើងប្រមូលថតជាកាសែត ហើយយើងធ្វើជា*ត្រេនស្រ្គីប* មាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា បើកទូលាយទៅគ្រប់អ្នកសិក្សាស្រាវជ្រាវនានាដែលចង់ដឹងអំពីរឿងរ៉ាវទាំងអស់នេះ។

[១៤:៣៤:២១]

**ស៖** សូមអរគុណ។ គឺវាបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ នៅក្នុងឯកសារដែលខ្ញុំដកស្រង់សម្តីអម្បាញ់មិញនេះ គឺវាពាក់ព័ន្ធទៅនឹងការបង្ហាញឲ្យមានឃើញនូវខ្សែសង្វាក់នៃការទទួលខុសត្រូវ។ ហេតុអ្វីបានជាការពន្លិចពន្លឺឲ្យចេញពីខ្សែសង្វាក់ នៃការទទួលខុសត្រូវនោះវាសំខាន់នោះ?

**លោក អាប់ឌុលឡាក់ ចារីក៖**

នៅពេលនេះគឺថាយើងស្តាប់តែសំណួរ ដែលវាមិនពាក់ព័ន្ធទៅនឹងប្រភពនៃឯកសារ ហើយនិងដំណើរការរបស់ ឌី.ស៊ី.ខេម។ ដូច្នេះហើយ នៅក្នុងពេលនេះ គឺអង្គជំនុំជម្រះគួរតែបង្គាប់ទៅដល់ខាងមេធាវីការពារក្តីសួរសំណួរដែលពាក់ព័ន្ធទៅនឹងការប្តេជ្ញារបស់ ឌី.ស៊ី.ខេម ក្នុងការប្រមូលឯកសារ។ ការដែលសួរថា ជំរុញចង់ឲ្យមានការទទួលខុសត្រូវបុគ្គលណាមួយនោះ គឺវាមិនពាក់ព័ន្ធទៅនឹងសំណួរនេះទេ។ គឺយើងគ្រាន់តែដឹងថាតើឯកសារមានការក្លែងបន្លំ ឬក៏យ៉ាងណា? ដូច្នេះហើយ ទុកឲ្យអង្គជំនុំជម្រះជាអ្នកសម្រេចឲ្យបានច្បាស់ទៅលើចំណុចហ្នឹង។

**លោក ហ្សាស្តេ ប៉ោ៖**

លោកប្រធាន បើសិនអនុញ្ញាតឲ្យខ្ញុំឆ្លើយតប គឺខ្ញុំមិនមែនលើកឡើងថា ឌី.ស៊ី.ខេម គឺចាប់ផ្តើមលើកឡើងមិនជាក់លាក់ទៅលើឯកសារណាមួយនោះទេ។ ក៏ប៉ុន្តែយើងគ្រាន់តែសួរអំពីវិធីសាស្ត្រដែល ឌី.ស៊ី.ខេម ប្រមូលឯកសារតែប៉ុណ្ណោះ។ ដូច្នេះហើយ ករណីហ្នឹង គឺវាផ្អែកទៅលើភស្តុតាង។ រឿងក្តីរបស់យើង គឺផ្អែកទៅលើភស្តុតាងដែលផ្តល់ជូនដោយ ឌី.ស៊ី.ខេម។ ដូច្នេះហើយ វាសំខាន់ណាស់ដែលយើងត្រូវសួរថា តើឌី.ស៊ី.ខេម នោះ មានបានមើលទៅលើព័ត៌មានភស្តុតាងជាក់លាក់មួយចំនួនដែរឬទេ? ប្រហែលជាយើងអាចមើលរំលង។ វាសំខាន់ផងដែរ ដែលយើងត្រូវដឹងចិត្តគំនិតរបស់ខាង

ឌី.ស៊ី.ខេម ថាតើគេគិតយ៉ាងម៉េច នៅពេលដែលគេរកប្រមូលឯកសារនោះ? ដូច្នេះហើយ វាចំណុចនេះ វាសំខាន់ណាស់ ដូចដែលលោក លោកស្រីចៅក្រម ដឹងយ៉ាងច្បាស់រួចមកហើយ ថាមេធាវីការពារក្តីគឺ បានជំទាស់ទៅអ្វីនឹងដែលសហព្រះរាជអាជ្ញាបានធ្វើឡើងពាក់ព័ន្ធទៅនឹងឯកសារ និងការប្រើប្រាស់ ឯកសារ។

[១៤:៣៦:៣២]

ចៅក្រមស៊ើបអង្កេត គឺគាត់បានគិត និងទទួលបានទៅលើការជំទាស់របស់ខាងមេធាវីការពារ ក្តី។ មេធាវីការពារក្តីបានលើកឡើងរួចមកហើយ ថាយើងហាក់ដូចជាមិនមានតម្លាភាព។ ដូច្នេះហើយ នៅពេលនេះ គឺយើងត្រូវតែពិនិត្យមើលទៅលើករណីរឿងក្តីរបស់យើង ថាតើអ្នកដែលទទួលខុសត្រូវ ក្នុងការប្រមូលភស្តុតាងពីដើមនោះ គាត់គិតយ៉ាងម៉េច ក្នុងការប្រមូលឯកសារ? ដូច្នេះហើយ ប្រសិនបើ លើកថា មិនពាក់ព័ន្ធ-- សំណួរនេះ មិនពាក់ព័ន្ធនោះ យើងហាក់ដូចជាមិនសួរចំណុចដែលយើងចង់សួរ នៅក្នុងរឿងក្តីនេះ។ ដូច្នេះហើយ ទើបខ្ញុំសុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្ញុំសួរទៅលើចំណុច ដែលថា-- ចំណុចដែលវាពាក់ព័ន្ធទៅនឹងពន្លិចពន្លឺនៃការទទួលខុសត្រូវនោះ។

[១៤:៣៧:៣២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤០:៤៩]

**ប្រធានអង្គជំនុំ៖**

ជំទាស់គ្មានប្រសិទ្ធភាព ហើយសាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលមេធាវីបានសួរ ហើយ អង្គជំនុំជម្រះសូមរំឭកមេធាវីថា សំណួរប្រហាក់ប្រហែលគ្នា គឺនៅលើកក្រោយនេះ យើងមិនឲ្យសួរ ប្រហាក់ប្រហែលគ្នា ឬក៏ដដែលៗនោះឡើយ។

**លោក ផាំង យុះ៖**

សូមអរគុណលោកប្រធាន។ សូមលោកមេធាវីមេត្តាសួរម្តងទៀត ដោយសារថារយៈពេល--

**ប្រធានអង្គជំនុំ៖**

បើកៗក្បាលមេក្រូ។

**លោក ផាំង យុះ៖**

សូមគោរពលោកប្រធាន។ សូមអធ្យាស្រ័យលោកមេធាវី សូមមេត្តាសួរម្តងទៀត ព្រោះថា

យើងមានរយៈពេលពីរបីនាទី ដែលឆ្លងកាត់នេះធ្វើឲ្យ ខ្ញុំចង់បានការរំឭកម្តងទៀត។

**សួរដោយលោក ហ្សាស្តេ ប៉ោះ**

**ស៖** សូមអរគុណលោកប្រធាន។ លោក ផាំង យុ អ្វីដែលខ្ញុំសួរគឺដូចតទៅ នៅក្នុងឯកសារដែលខ្ញុំទើបតែដកស្រង់សម្តី គឺពាក់ព័ន្ធទៅនឹងគម្រោងនៃជំរុញការទទួលខុសត្រូវ ដែលក្នុងនោះលើកឡើងថា គោលបំណងនេះនៃគម្រោងនេះ គឺដើម្បីផ្តល់ជាពន្លឺនៃខ្សែសង្វាក់នៃការបញ្ជា។ ដូច្នេះហើយខ្ញុំសូមសួរហេតុអ្វីបានជាសំខាន់សម្រាប់ ឌី.ស៊ី.ខេម ក្នុងការពន្លិចជាពន្លឺអំពីខ្សែសង្វាក់នៃការបញ្ជា?

**លោក ផាំង យុ៖**

**ឆ៖** ពីព្រោះយើងចង់ដឹងថា តើអ្នកណាសម្លាប់ប្រជាជនខ្មែរពីរលាននាក់ នៅក្នុងតាមការសម្ភាសរបស់យើង មនុស្សប្រហែលជារាប់ពាន់ គ្មានអ្នកណាម្នាក់សោះឆ្លើយថាបានសម្លាប់មនុស្ស។ អ៊ីចឹងយើងចង់ដឹង បាទយើងចង់ដឹងថាប្រវត្តិសាស្ត្រអ្នកណាបានធ្វើអំពើទាំងអស់នេះ។

[១៤:៤២:៣៧]

**ស៖** សូមអរគុណលោក ផាំង យុ។ ខ្ញុំកត់សម្គាល់ឃើញយោបល់របស់លោក ផាំង យុ ខ្ញុំចង់បន្តទៀត ក៏ប៉ុន្តែខ្ញុំមើលនាឡិកាទៅ វាហាក់ដូចជា វាអាស្រ័យទៅលើអង្គជំនុំជម្រះ ថាតើគួរតែឈប់សម្រាកនៅពេលនេះសិន ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលសមល្មមនឹងឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សីរូបនេះឲ្យបានសមរម្យ ហើយនិងអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មឲ្យបានមុនពេលអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សូមផ្តល់វេទិកាទៅសហមេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសក្នុងការបន្តសួរដេញដោលចំពោះសាក្សីរូបនេះតទៅទៀត។

សូមអញ្ជើញ!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះបង្ហាញជូនឯកសារមួយទៅដល់លោក ឆាំង យុ គឺឯកសារ D366/7.68 ERN គឺ 0044387 ដល់ 0044488។ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះបង្ហាញនូវក្របមុខនៃឯកសារនេះ។

[១៥:០៣:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** លោក ឆាំង យុ នៅលើអេក្រង់កុំព្យូទ័រ ឯកសារដែលខ្ញុំអានលេខជូនមកនេះ គឺជាឯកសារសម្ងាត់បំផុត មិនឲ្យធ្វើការផ្សព្វផ្សាយនេះទេ ដែលនិយាយអំពីការសិក្សារបស់បក្សកុម្មុយនីស្តកម្ពុជា។ ឈ្មោះរបស់លោកគឺមាននៅលើទំព័រនេះ ហើយកាលបរិច្ឆេទគឺខែឧសភា ឆ្នាំ២០០០។ តើលោកអាចចាំឯកសារនេះបានទេ? ថាតើឯកសារនេះគេនិយាយអំពីអ្វី?

[១៥:០៤:៣៦]

**លោក ឆាំង យុ៖**

ឯកសារនេះ គឺខ្ញុំជាអ្នកធ្វើដោយខ្លួនឯងផ្ទាល់។ បាទ ដោយសារថាមានសំណួរជាច្រើនអំពីរដ្ឋបាលរបស់គណបក្ស-- បក្សមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា។ នៅក្នុងកម្រងឯកសារនេះ ខ្ញុំបានហ្វូតូកូពី ថតចម្លងគំនិតផ្សេងៗរបស់លោក អ្នកស្រី ហេឡែន ចាវីស របស់លោក ប៊ែន ឃៀរនិន របស់លោក ក្រេក អេតធេសាន់ របស់លោក ស្ទីវ ហេដឌ័រ ដាក់បញ្ចូលគ្នា។ មូលហេតុដែលខ្ញុំដាក់ ហៅ "*លីស្ត អូហ្វ ខន់ហ្វីដិនស្យល*" នេះ ព្រោះជាទូទៅយើងគិតថា ឯកសារមួយចំនួនដែលយើងផ្តល់មកឲ្យតុលាការត្រូវបានបុគ្គលិកដែលជា*អ៊ីនធើន* យកទៅប្រើប្រាស់ដោយផ្ទាល់ខ្លួន។ អ៊ីចឹងហើយជាទូទៅ មុននឹងខ្ញុំប្រគល់ឯកសារមកខាងតុលាការ ខ្ញុំប្រើពាក្យខាងលើនេះ គឺដើម្បីចៀសវាងទោះបីជាយើងបានប្រាប់មកការិយាល័យផ្សេងៗក៏ដោយ ថាសូមមេត្តាកុំឲ្យប្រើប្រាស់ឯកសារដោយផ្ទាល់ខ្លួន។ យើងបាន

ឃើញឯកសារមួយចំនួនប្រើចេញទៅក្រៅ។ នៅក្នុងឯកសារនេះគឺសុទ្ធសឹងតែជាហ្វូតូកូពី ជាអ៊ីម៉ែល ដែលខ្ញុំចាំជាអ៊ីម៉ែល ជារបៀបក្រដាសដែលអ្នកស្រី ហៅឡែន បានធ្វើ។ ជាអ៊ីម៉ែលមកពី ប៉ែន ឃៀរនិន ខ្ញុំសួរគាត់ថា តើគណៈ-- បក្សមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជានេះវាយ៉ាងដូចម្តេច? ព្រោះខ្ញុំបាន ឃើញគាត់សរសេរនៅក្នុងសៀវភៅមួយដែលមានចំណងជើងថា "*ជេណូសាយ អ៊ិន ខេមបូឌា*" នៅក្នុង ទំព័រ១៣ និង១៤ ហើយអ៊ីចឹង ខ្ញុំចង់មកឲ្យគាត់ពន្យល់ថា តើហេតុអីបានជាគាត់ចេញជាតារាងនេះមក?

អ៊ីចឹងនៅក្នុងនេះសុទ្ធសឹងតែជាឯកសារហ្វូតូកូពី ដែលខ្ញុំបានពីអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់មួយ ចំនួន ហើយខ្ញុំចងក្រងវាជាហ្វូលឌ័រ មួយ សម្រាប់ខ្ញុំសិក្សាខ្លួនឯង ដើម្បីស្វែងយល់ថែមទៀតអំពីបក្ស មជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជានេះ។

[១៥:០៦:២៨]

**ស៖** បើខ្ញុំយល់លោកមិនច្រឡំទេ ការប្រមូលនូវឯកសារនេះ គឺដើម្បីឲ្យជួយឲ្យយល់អំពីមុខងារ របស់គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាមែនទេ?

**ឆ៖** ជាការត្រឹមត្រូវ ព្រោះខ្ញុំចង់ដឹងថា តើរចនាសម្ព័ន្ធនេះរៀបចំឡើងដោយដូចម្តេច?

**ស៖** សំណួរមួយទៀត តើលោកនៅតែមានឯកសារផ្សេងទៀតនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាឯកសារសម្ងាត់បំផុត ដែលសាធារណជនមិនអាចចូលមើលបាននោះ តើលោកនៅតែមានទេ?

**ឆ៖** តាមពិតទៅឯកសារទាំងអស់នេះមាននៅក្នុងបណ្ណាល័យរបស់យើង ហើយមិនមែនជា ឯកសារសម្ងាត់បំផុតទេ។ ដូចខ្ញុំជម្រាបលោកអ៊ីចឹង មូលហេតុដែលខ្ញុំដាក់ថា "ឯកសារសម្ងាត់" នេះ ដោយសារនៅទីនេះ នៅតុលាការនេះ បុគ្គលមួយចំនួនដែលជា*អ៊ីនធើន* បានយកឯកសារនេះទៅប្រើ ប្រាស់ដោយផ្ទាល់ ហើយមានអ្នកខ្លះទៀតស្នើសុំឯកសារខ្ញុំដោយផ្ទាល់ទៀត។ អ៊ីចឹងខ្ញុំបារម្ភចំពោះ ឯកសារនេះអត់មានជាសេចក្តីសន្និដ្ឋាន ឬសេចក្តីសង្ខេបណាមួយទេ ខ្ញុំបារម្ភថាអ្នកធ្វើកម្មសិក្សាទាំង អស់នោះយកឯកសារទៅប្រើប្រាស់ខុសទិសដៅ ព្រោះយើងចង់ឲ្យមកតុលាការ។ អ៊ីចឹងហើយឲ្យតែ ឯកសារមកតុលាការ ខ្ញុំដាក់ពាក្យហ្នឹងទាំងអស់ មិនមែនបានន័យថា នេះជាឯកសារសម្ងាត់ទេ។ ឯកសារទាំងអស់នេះ មាននៅក្នុងបណ្ណាល័យរបស់យើង ពីព្រោះវាជាលំដាប់ទីពីរ ជា*សេខិនឌើរីសៃស* ជា ឯកសារដែលយើងប្រមូលមកតាមការសរសេរវិភាគរបស់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់។ ហើយខ្ញុំចាំ ច្បាស់ណាស់ឯកសារនេះ ព្រោះខ្ញុំធ្វើខ្លួនឯង គឺលោក ប៉ែន ឃៀរនិន, ក្រេក អេតឆេសាន់, ហៅឡែន ចារីស ហើយនិង ស្ទីវ ហេដឌ័រ ដែលខ្ញុំសុំតាមអ៊ីម៉ែលរបស់គាត់មកដាក់។

[១៥:០៨:១៥]

**ស៖** ខ្ញុំឮថាឯកសារនេះគឺដាក់សម្ងាត់បំផុតនេះ គឺសម្រាប់តែឲ្យគោលបំណងប្រើប្រាស់ដោយតុលាការនេះតែប៉ុណ្ណោះ។ តើត្រឹមត្រូវអ៊ីចឹងទេ?

**ឆ៖** មុនពេលដែលខ្ញុំផ្ញើមកឲ្យតុលាការ ខ្ញុំដាក់ពាក្យនេះ ពីព្រោះខ្ញុំមិនចង់ឲ្យឯកសារទាំងអស់នេះធ្លាក់ទៅលើដៃអ្នកមកធ្វើកម្មសិក្សាជាបុគ្គល ហើយវាធ្វើឲ្យព័ត៌មានទាំងអស់នេះដែលមិនទាន់ធ្វើការសេចក្តីសម្រេច ឬសន្និដ្ឋានណាមួយ។ ដូចលោកឃើញស្រាប់ហើយ ខ្ញុំប្រើពាក្យថា *ដ្រាហ្វត៍* គឺមិនទាន់យកជាការបានទេ ហើយខ្ញុំមិនចង់ឲ្យធ្លាក់ទៅលើអ្នកផ្សេងទៀត ក្រៅពីការិយាល័យដែលបានធ្វើការស្នើសុំ។

[១៥:០៩:០០]

**ស៖** សូមអរគុណលោក។ ខ្ញុំសូមចុះមកក្រោមបន្តិច សូមមើលទំព័របួននៃឯកសារនេះ ERN គឺ 493។ តើយើងអាចមើលទំព័របួន គឺនៅផ្នែកខាងលើ គឺមកពី ប៉ែន យៀរនិន ផ្ញើជូនទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបន្ទាប់មកសូមចូលទៅទំព័រទីប្រាំពីរនៃឯកសារដដែល គឺទំព័រទីប្រាំពីរនៅខាងក្រោម។ យើងឃើញដាក់ថា ជាសំណេរខ្លីមួយ ខ្ញុំគិតថាជាសំណេររបស់ ប៉ែន យៀរនិន ដោយសារមាននៅខាងដើមមានឈ្មោះគាត់។ ប៉ែន យៀរនិន សួរទៅលោកថា ភី.អេស តើលោកមានទទួលបានទំព័រចុងក្រោយដែលផ្សព្វផ្សាយនៅក្នុងសារព័ត៌មានភ្នំពេញប៉ុស្តិ៍ដែរឬទេ?

សំណួររបស់ខ្ញុំ សួរថាតើឯកសារអី ដែលលោកបានស្នើសុំមកពីខាងកាសែតភ្នំពេញប៉ុស្តិ៍នុ៎ង?

**ឆ៖** ខ្ញុំចាំមិនច្បាស់ដែរ។ តាមដែលខ្ញុំចាំ មានឯកសារពីរយ៉ាងដែលខ្ញុំស្នើសុំពីសារព័ត៌មានភ្នំពេញប៉ុស្តិ៍។ ទីមួយគឺរូបថត ខាធីរីន ហេ ដែលជា *ខូអេឌីទ័រ* នៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍នេះ ខ្ញុំដឹងថាមានរូបថតខ្មែរក្រហមជាច្រើន ហើយកាលហ្នឹង ខ្ញុំបានស្នើសុំឲ្យគាត់ ធ្វើការបោះពុម្ពជាសៀវភៅមួយអំពីរូបថត។ រូបថតទាំងអស់នេះ មិនមែនជារូបថតមកពីសារមន្ទីរទួលស្លែងទេ គឺជារូបថត អ្នកមេដឹកនាំជាន់ខ្ពស់ ធ្វើដំណើរនៅក្នុងប្រទេសកម្ពុជា។ ហើយខ្ញុំបានទាមទារសុំគាត់ជាច្រើនដង ហើយមកទល់សព្វថ្ងៃនេះ ខ្ញុំមានតែហ្វូតូកូពី របស់រូបថតាំងអស់នោះទេ គឺយើងមិនបានឈានទៅដល់ការសហការមួយ បោះរូបថតនេះចេញផ្សាយ។ ទីពីរទៀត ខ្ញុំចាំថា នៅមានឯកសារមួយ ដែលគេបានប្រាប់ខ្ញុំថាភ្នំពេញប៉ុស្តិ៍បានទទួលមកពីអន្លង់វែង បាទពីអន្លង់វែង ហើយជាឯកសារសរសេរដៃ ហើយខ្ញុំបានស្នើសុំជាច្រើនលើកច្រើនសា ខ្ញុំសូមទៅលោក ម៉ៃឃល ហេ ជាច្រើនលើកច្រើនសា តាមដែលខ្ញុំចាំ--

[១៥:១១:១៧]

**ស៖** លោក ឆាំង យុ លោកកំពុងព្យាយាមឆ្លើយទៅនឹងសំណួររបស់ខ្ញុំ ខ្ញុំអរគុណច្រើនណាស់។ ខ្ញុំគ្រាន់លើកសង្ខេបការព្រួយរបស់ខ្ញុំទាក់ទងទៅនឹងរូបថត ដែលលោកស្នើសុំពីភ្នំពេញប៉ុស្តិ៍ តើមានឯកសារដទៃទៀតដែលលោកស្នើសុំពីភ្នំពេញប៉ុស្តិ៍ក្រៅពីរូបថត ដើម្បីជាការប្រមូលរបស់លោកទេ?

**ឆ៖** ខ្ញុំកំពុងនិយាយតែលោកបានកាត់ សម្តីរបស់ខ្ញុំ។ ខ្ញុំកំពុងតែនិយាយថា មានឯកសារទៀត គឺជាឯកសារដែលគេប្រាប់ខ្ញុំថា ភ្នំពេញប៉ុស្តិ៍បានមកពីតំបន់អន្លង់វែង ហើយនៅក្នុងឆ្នាំ៩៨នោះ គឺថាតំបន់អន្លង់វែងនេះ គឺជាតំបន់មួយដែលមានអតីតកម្មាភិបាលខ្មែរក្រហមរស់នៅច្រើន។ អ៊ីចឹង ខ្ញុំចាប់អារម្មណ៍ ខ្ញុំបានសរសេរជាអ៊ីម៉ែលជាទូរស័ព្ទ ស្នើសុំទៅលោក ម៉ៃខល ហេ ជាច្រើនលើកច្រើនសា។ បាទ អ៊ីចឹងអានេះគឺសំដៅទៅលើឯកសារទាំងពីរប្រភេទនោះឯង។ ហើយខ្ញុំចាំថា នៅមានរូបថតមួយប្រភេទទៀត ដែលខ្ញុំត្រូវបានដែលប្រធាន អេ.ភី នៅបាងកក បានផ្ញើមកឲ្យខ្ញុំតាមរយៈភ្នំពេញប៉ុស្តិ៍។ ខ្ញុំចាំថា លោកគឺឈ្មោះ ដេនីស គ្រេ លោក ដេនីស គ្រេ គឺជាមិត្តភក្តិរបស់លោក ស្មីរ ហេដឌ័រ ហើយគាត់បានប្រាប់ខ្ញុំថា គាត់មានរូបថតមួយចំនួន ដែលគាត់គិតថា ជារូបថតរបស់--

[១៥:១២:៣៣]

**ស៖** លោក ឆាំង យុ ខ្ញុំសូមរំខានលោកម្តងទៀត។ ខ្ញុំសូមសួរលោកសង្ខេបទេ តើលោកចាំទេលោកមានបានទទួលរូបថតណាមួយ ឬក៏ឯកសារណាមួយពីកាសែតភ្នំពេញប៉ុស្តិ៍ដែរឬទេ? តើលោកពិតជាបានទទួលរូបថត ឬឯកសារណាមួយពីភ្នំពេញប៉ុស្តិ៍ដែរឬទេ?

**ឆ៖** ខ្ញុំបានទទួលរូបថតជាហ្វូតូកូពីនៅលើក្រដាសព្រីន អេ.ហ្វ័រ (A4) ព្រោះ កាធីរីន គាត់បានស្កេន ដាក់នៅលើក្រដាស អេ.ហ្វ័រ ហើយក៏ខ្ញុំមានសំណៅរូបថតនេះមួយសំណៅ តាមពិតទៅបីសំណៅបាទ ខ្ញុំមាន។

[១៥:១៣:១៤]

**ស៖** ហើយតើលោកបានទទួលឯកសារ ជាឯកសារចម្លង ឬក៏ឯកសារដើមពីកាសែតនេះដែរឬទេ?

**ឆ៖** លោកចង់និយាយពី ឯកសារមកពីអន្លង់វែង?

**ស៖** បាទ។

**ឆ៖** ដូចខ្ញុំជម្រាបលោកអ៊ីចឹង ខ្ញុំនិយាយមិនទាន់ចប់ តែលោកកាត់ខ្ញុំពីរដង ខ្ញុំចង់និយាយឲ្យ

ច្បាស់។ បាទថា ខ្ញុំបានស្នើសុំគាត់ប៉ុន្តែវាមិនបាន បានតែហ្វូតូកូពីរូបថត។ ឯឯកសារនោះខ្ញុំអត់បានទេ។

**ស៖** ខ្ញុំបានកត់ត្រាថា កាសែតភ្នំពេញប៉ុស្តិ៍គឺមិនបានបង្ហាញថា ជាប្រភពនៃឯកសារនៅក្នុងករណីនេះទេ ដូច្នេះ ខ្ញុំសូមសួរសំណួរបន្ថែមទៅទៀតនៅថ្ងៃចន្ទ។ ខ្ញុំចង់បង្ហាញទំព័រទី១២ នៃឯកសារដដែលនេះ។ ខ្ញុំគិតថា យើងអាចឃើញនៅលើអេក្រង់កុំព្យូទ័រនេះហើយ។ នៅខាងដើមនោះ ខ្ញុំសូមអានជូនលោកតែម្តង សេចក្តីសង្ខេប ក្រេក អេតឆេសាន់ ទំនាក់ទំនងជាឯកជន បានផ្តល់នូវបញ្ជីនៃជនល្មើសសំខាន់ៗ ដូចខាងក្រោមនេះ។

**ឆ៖** សូមទោសសំណួរថាម៉េច បាទ?

[១៥:១៥:០៣]

**ស៖** សំណួររបស់ខ្ញុំថាតើលោកនៅចាំឯកសារបានទេ នៅលើអេក្រង់នេះ?

**ឆ៖** អ៊ូ ចាំច្បាស់ណាស់ បាទ។ ខ្ញុំធ្វើការឯកសារនេះខ្លួនឯង។ ខ្ញុំប្រមូលខ្លួនឯង ខ្ញុំស្គាល់ឯកសារនេះ។

**ស៖** លោកអាចពន្យល់បានទេ ហេតុអ្វីបានជាលោក ក្រេក អេតឆេសាន់ បាននិយាយអំពីពាក្យថា "*ឃឹ ខាលព្រីតស៍*" នេះ និយាយពីជនល្មើសសំខាន់ៗនេះ?

**ឆ៖** បាទ ក្រេក គាត់គឺជាសកម្មជនម្នាក់ ដែលធ្លាប់ជាប្រធានយុទ្ធនាការនៃប្រឆាំង និងការត្រឡប់មកវិញនូវរបបខ្មែរក្រហម។ អ៊ីចឹង អានេះ គឺជាសម្តីរបស់គាត់ ហើយលោកអាចសួរគាត់បានគាត់នៅតុលាការនេះតែម្តង។ បាទ នៅការិយាល័យសហព្រះរាជអាជ្ញា។

**ស៖** សូមអរគុណច្រើន ចំពោះការដែលលោកសំណូមពរឲ្យសួរទៅលោក ក្រេក អេតឆេសាន់នេះ។ ខ្ញុំគ្រាន់តែសួរថា តើលោកដឹងទេ ហេតុបានជាលោក ក្រេក អេតឆេសាន់ ប្រើពាក្យ "*ខាលព្រីតស៍*" នៅក្នុងឯកសារនេះ?

[១៥:១៦:០៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមជំទាស់ចំពោះការលើកឡើងនេះ ម្តងហើយម្តងទៀត។ វាប្រាសចាកពីវិធានបទ ដែលវាមិនទាក់ទងទៅនឹងឯកសារនៅក្នុងសំណុំរឿង។ ដូច្នេះ ខ្ញុំគិតថា សំណួរបែបនេះ គឺថាមិនគួរសួរនោះទេ។ ហើយខ្ញុំចង់ឲ្យសួរចំៗនៅលើបញ្ហានេះតែម្តង ដើម្បីឲ្យមានការជាប់ពាក់ព័ន្ធជាមួយនឹងរឿង ក៏ដូចជា យុ ឆាំង ដែរ ថាតើហេតុអ្វីបានជាលោក ក្រេក អេតឆេសាន់ គាត់ប្រើពាក្យនេះយ៉ាង

ដូច្នេះ?

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ប្រសិនជាលោកប្រធានអនុញ្ញាត នេះគឺជាប្រធានបទដដែលទេ។ វាពាក់ព័ន្ធទៅនឹងឥរិយាបទរបស់ ឌី.ស៊ី.ខេម ក្នុងការប្រមូលឯកសារភស្តុតាង ហើយចំណែកនៃឯកសារណាមួយដែលខ្លួនត្រូវប្រមូល។ ដូច្នេះ នេះគឺជាចំណុចស្នូលនៃរឿងក្តីនេះ។ ដូច្នេះ សហការីខ្ញុំនៅការិយាល័យសហព្រះរាជអាជ្ញាថា តើសាក្សីអាចនឹងផ្តលសក្ខីកម្មទៅលើនេះឬក៏អត់? ហេតុអ្វីបានជាលោក ក្រេក អេតឆេសាន់ ប្រើពាក្យថា ឧក្រិដ្ឋជនសំខាន់ៗនេះ។ អ៊ីចឹង ខ្ញុំសូមការឆន្ទានុសិទ្ធិពីអង្គជំនុំជម្រះ។ ខ្ញុំសង្ឃឹមថា នេះគឺចំណុចនឹងបង្ហាញឲ្យឃើញច្បាស់ ថាហេតុអ្វីបានជាសំណួរនេះ វាសំខាន់ ហើយមានការពាក់ព័ន្ធនោះ ពាក់ព័ន្ធទៅនឹងការប្រមូលរបស់ ឌី.ស៊ី.ខេម នេះតែម្តង។ ដូច្នេះ ខ្ញុំនឹងមានសេចក្តីរីករាយណាស់ ប្រសិនណា ខ្ញុំអាចទទួលបាននូវចម្លើយ ថាហេតុអ្វីបានជាលោក ក្រេក អេតឆេសាន់ ប្រើពាក្យនេះ?

[១៥:១៧:៥៣]

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញនេះ គឺសាក្សីឆ្លើយរួចហើយ ពីព្រោះសំណោរនោះ ជាសំណេររបស់ ក្រេក អេតឆេសាន់។ អ៊ីចឹង បើចង់ដឹងពីមូលហេតុ គឺទៅសួរម្ចាស់សំណេរ។ ចម្លើយនេះច្បាស់ហើយ ជាភាសាខ្មែរ ច្បាស់លាស់ហើយ។

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តេ ប៉ៅ៖**

**ស៖** ខ្ញុំបន្តទៅទំព័របន្ទាប់ទៀត គឺទំព័រ១៣។ ខ្ញុំសុំមើលមើល៍ ថាតើអាចមើលឃើញនៅលើអេក្រង់ទេ។ នៅទំព័រ១៣ យើងអាចចុះនៅក្រោមផ្នែកខាងក្រោមនៃទំព័រនេះ។ យើងឃើញមានដាក់ក្នុងរង្វង់នេះ ដាក់ថាចងក្រងដោយ អេច.ជី (HG) ថ្ងៃទី២០ មេសា ឆ្នាំ២០០០។ ថាតើលោកអាចបញ្ជាក់បានទេ ថាតើ អេច.ជី នេះ ជាអ្នកណាដែរ?

**ឆ៖** ហេឡែន ចាវីស។

**ស៖** ហើយបើលោកមើលឃើញកាលបរិច្ឆេទថ្ងៃទី២០ មេសា ឆ្នាំ២០០០ នៅពេលនោះ ថាតើលោក ក្រេក អេតឆេសាន់ ជានិយោជិកម្នាក់របស់ ឌី.ស៊ី.ខេម ឬក៏យ៉ាងណា?

[១៥:១៩:២៦]

**ឆ៖** មិនមែនទេ បាទ។ មិនមែនជាបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ទាំងអ្នកស្រី ហេឡែន ទាំងលោក ក្រេក អេតឆេសាន់។

**ស៖** តើលោកអាចពន្យល់ ថាតើលោក ក្រេក អេតឆេសាន់ មានតួនាទីយ៉ាងម៉េចដែរ ជាប់ទាក់ទងទៅនឹងមជ្ឈមណ្ឌលឯកសារកម្ពុជានៅពេលនោះ?

**ឆ៖** លោក គឺជាអ្នកស្រាវជ្រាវឯករាជ្យម្នាក់ ហើយជាមិត្តភក្តិចាស់របស់ខ្ញុំ ហើយជាទូទៅលោកចេញចូលប្រទេសកម្ពុជា ផ្តល់ឯកសារផ្សេងៗដើម្បីជួយដល់ការសិក្សាស្រាវជ្រាវរបស់ខ្ញុំ ដូចជាលោកឃើញស្រាប់ហើយ ថានៅក្នុងគម្រប នៅក្នុងឯកសារនេះ ខ្ញុំដាក់ថា *ស្តាឌី* គឺការសិក្សាស្រាវជ្រាវអំពីគណៈមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា។ អ៊ីចឹងគាត់មានសរសេរសៀវភៅគាត់ គាត់សិក្សាស្រាវជ្រាវអី ហើយឯកសារផ្សេងៗដែលគាត់មានគាត់ឲ្យមកខ្ញុំ។

**ស៖** សូមអរគុណលោក។ នៅក្នុងឯកសារនេះដដែល សូមឡើងទៅខាងលើបន្តិច គឺទំព័រ១២ ទាក់ទងទៅនឹងឯកសារដែលចងក្រងដោយលោកស្រី ហេឡែន ចារីស បើយើងមើលលើអេក្រង់នៅក្នុងប្រអប់ពណ៌ក្រហមនេះ យើងអាចមើលឃើញ ខ្ញុំសូមអានជូនលោក *ម៉ាន់ដេយ៍* នៅលើ ម៉ម ណៃ នៅលើបញ្ជីរបស់ខ្ញុំនេះ គឺថាដោយសារគាត់ជាលេខពីរ នៅគណៈកម្មាធិការ ស-២១ ហើយឃាតកបែបនេះរួមទាំងខ្ញុំគិតថា គាត់គួរតែរក្សានូវតួនាទីជានគរបាលនៅខេត្តបាត់ដំបង។ តើខ្ញុំនិយាយអំពីបញ្ជីរបស់ ហេឡែន ចារីស ក៏ដូចជាបញ្ជីរបស់ ចងក្រងដោយ ហេឡែន ចារីស ក៏ដោយលោកដែរ។ តើលោកអាចបញ្ជាក់នូវពាក្យពេចន៍នេះបានទេ?

[១៥:២១:១៥]

**ឆ៖** លោកចង់សួរថា ខ្ញុំមានបញ្ជីអ្នកដែលនៅ ស-២១? សូមទោស សូមសួរម្តងទៀត។

**ឆ៖** បាទ ជាការពិតហើយ ប្រសិនណាសូមបង្ហាញនូវលើអេក្រង់ម្តងទៀតនូវឃ្លាដើមតែម្តង បើលោកអានមកដាក់ថា ម៉ម ណៃ នៅលើបញ្ជីរបស់ខ្ញុំដោយសារគាត់លេខពីរ ខ្ញុំមិនដឹងថា តើឯកសារដែលយើងបង្ហាញនេះនិយាយអំពីបញ្ជីរបស់លោក ក្រេក អេតឆេសាន់ ឬក៏បញ្ជីរបស់ ហេឡែន ចារីស ឬក៏បញ្ជីឯកសាររបស់លោកតែម្តង? សូមលោកជួយបញ្ជាក់លោក ឆាំង យុ។

**ឆ៖** ខ្ញុំមិនច្បាស់ដែរ តែបើសិនជាយើងមើលពីខាងលើថា គាត់ផ្ញើទៅឲ្យអ្នកណាបាន ប្រហែលជាខ្ញុំអាចជួយប្រាប់បាន។ នេះហាក់ដូចជានិយាយអំពីបញ្ជីរបស់គាត់ ឬគាត់បញ្ចេញយោបល់

ថា គាត់ដឹងមនុស្សណាដែលគួរតែធ្វើ-- ទទួលការកាត់ទោសក៏អាចថាបាន។ ប៉ុន្តែបើលោកឡើងទៅខាងលើ តើលិខិតមួយនេះ ព្រោះខ្ញុំបានភ្លេចដែរ តើគាត់សរសេរទៅឲ្យអ្នកណាបាទ? លោខ្ញុំអាចជួយឆ្លើយបានល្អជាងនេះ។

[១៥:២២:២៨]

សូមរំកិលទៅខាងលើបន្តិច។

**ស៖** យើងអាចបង្ហាញបាន ប៉ុន្តែឯកសារនេះ ដោយសារវាជាឯកសារ D366 ខ្ញុំសូមពិនិត្យមើលឯកសារនេះ។ បើសិនយើងចូលទៅទំព័រទីដប់ ខ្ញុំសូមឲ្យសហការីខ្ញុំជួយបង្ហាញនូវទំព័រនេះ។ បាទនេះគឺជាឯកសារដែលបង្ហាញ។ ដូច្នេះបើសិនណាជាលោកមិនដឹងពីឯកសារនេះ លោកមិនដឹងថាតើជាបញ្ជីរបស់អ្នកណានោះទេ ខ្ញុំនឹងមិនសួរលោកឲ្យលោកស្មានៗថាជាបញ្ជីអ្នកណាទេ។ ខ្ញុំគ្រាន់តែចង់លើកឡើងចង្អុលបង្ហាញជូនលោកថា សម្រាប់ខ្ញុំនៅពេលដែលខ្ញុំអានឯកសារនេះទៅ ហាក់បីដូចជាថាមានអ្នកណាម្នាក់ជាអ្នកជ្រើសរើសជនសង្ស័យដែលត្រូវនាំខ្លួនយកមកធ្វើការផ្តន្ទាទោស។ ដូច្នេះបើយើងមើលភាសាដែលបានប្រើប្រាស់នៅក្នុងឯកសារនេះ ខ្ញុំដែលថាគាត់មិនគួរនៅទទួលតួនាទីជានគរបាលនៅបាត់ដំបងនោះទេ។ តើលោកយល់ស្របជាមួយនឹងការវាយតម្លៃនៅក្នុងប្រអប់នេះដែរឬទេ?

[១៥:២៤:០៦]

**ឆ៖** ខ្ញុំដោយសារថា វាអត់មានសរសេរទៅអ្នកណាអ៊ីចឹង ខ្ញុំគិតថានៅក្នុងអ្នកសិក្សាស្រាវជ្រាវម្នាក់ៗគឺគេមានការប្រកួតប្រជែង ឬក៏ការសិក្សាស្រាវជ្រាវរវាងគ្នា នឹងគ្នា ហើយម្នាក់ៗគេមានបញ្ជីរៀងៗខ្លួន។ ហើយខ្ញុំគិតថា អ្នកស្រី ហេឡែន ចាវីស គឺគាត់មានបញ្ជីរបស់គាត់ដែរ។ លោក គ្រេក អេតឆេសាន់ ក៏មានបញ្ជីរបស់គាត់។ លោក ប៉ែន ឃៀរនិន ក៏មានបញ្ជីរបស់គាត់ដែលបានបោះពុម្ពផ្សាយនៅក្នុងសៀវភៅដែលមានចំណងជើងថា "*ជេណូសាយ អ៊ិន ខេមបូឌា*" ទំព័រ១៣ និងទំព័រ១៤។ អ៊ីចឹងម្នាក់ៗជជែកគ្នាថា តើអ្នកជាអ្នកណា។ អ៊ីចឹងខ្ញុំគិតថា នេះប្រហែលជាសំដៅទៅលើបញ្ជីរបស់គាត់ផ្ទាល់។

**ស៖** សូមអរគុណលោក ឆាំង យុ ថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាមានបញ្ជីឯកសារ តើឌី.ស៊ី.ខេម មានបញ្ជីឯកសារនៅក្នុងទសវត្សរ៍១៩៩០ ដែលថាអ្នកណាដែលត្រូវតែនាំខ្លួនមកផ្តន្ទាទោសនោះដែរឬទេ?

[១៥:២៥:០៤]

**ឆ៖** ខ្ញុំដូចជាប្រាប់ពីម្សិលមិញហើយ ខ្ញុំធ្លាប់បានទទួលបញ្ជីម្នាក់អំពីមិត្តភក្តិរបស់ខ្ញុំ ដែលជាជនជាតិអាមេរិកាំង ដែលមានឈ្មោះ ដាកក្លាស ចនសុន។ នៅក្នុងបញ្ជីនោះ គឺខ្ញុំបានធ្វើជាប្រមូលអ៊ីចឹងដែរ មានចំណងជើងថា ដូចជាតាមដែលខ្ញុំចាំ *បាយអ័រក្រាហ្វី អូហ្វ ឌី ខ្មែរ រូស្ស លីដឌ័រ*។ អ៊ីចឹងអ្នកណាមួយ ការសិក្សាណាមួយដែលគេប្រាប់ខ្ញុំ ដែលគេមានការសង្ស័យ ឬក៏គេឲ្យយោបល់ ខ្ញុំបញ្ចូលទៅក្នុងហ្នឹងទាំងអស់ នៅក្នុងបញ្ជីមួយហ្នឹង។ ដូចជាខ្ញុំប្រាប់ហើយអ៊ីចឹង គឺជាការប្រមូលចងក្រងឯកសារផ្សេងៗ ដើម្បីស្វែងយល់។

[១៥:២៥:៣៦]

បញ្ជីហ្នឹងមានមែន តែខ្ញុំចាំថា អត់មានជាចំណងជើងជាភាសាខ្មែរទេ។ សូមបញ្ជាក់ម្តងទៀត ខ្ញុំដូចជាហៅថា *បាយអ័រក្រាហ្វី អូហ្វ ឌី ខ្មែរ រូស្ស លីដឌ័រ*។ បើសិនជាមិនភ្លេចទ--

**ស៖** លោក ឆាំង យុ ខ្ញុំសូមរំខានលោក បង្អាក់លោក ដោយសារតែលោកមិនឆ្លើយទៅនឹងសំណួររបស់ខ្ញុំទេ។ សំណួរ ខ្ញុំសួរដោយសារលោកនិយាយអំពីអ្នកសិក្សាស្រាវជ្រាវ មានបញ្ជីផ្ទាល់ៗខ្លួនសំណួររបស់ខ្ញុំនោះ គឺតើនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០នោះ មជ្ឈមណ្ឌលឯកសារកម្ពុជា មានបញ្ជីឈ្មោះមនុស្សដែលត្រូវនាំខ្លួនមកយកផ្តន្ទាទោសនោះដែរឬទេ?

**ឆ៖** បញ្ជី! ដូចខ្ញុំជម្រាបលោកអ៊ីចឹង បើសិនជាលោក ឆ្នាំ៩០ លោកសាស្ត្រាចារ្យ ប៊ែន ឃៀរនិន ជាប្រធានរបស់ខ្ញុំ គាត់បានបោះផ្សាយបញ្ជីនេះនៅក្នុងសៀវភៅ មានចំណងជើងថា "*ជេណូសាយ អ៊ីន ខេមបូឌា*"។ អ៊ីចឹងលោកអាចថាបញ្ជីដែរ ពីព្រោះកាលណោះយើងជាការិយាល័យមួយរបស់សាកលវិទ្យាល័យយ៉ែល ហើយលោក ប៊ែន ឃៀរនិន ជាប្រធានរបស់ខ្ញុំ។ អ៊ីចឹងយើងមានបញ្ជី បើសិនជាលោកសំដៅទៅលើបញ្ជីបែបនោះបាទ។ យើងមាន ទំព័រ១៣ និងទំព័រ១៤។

[១៥:២៦:៥៥]

**ស៖** ចំណុចនេះប្រហែលជាអាចពិតហើយ ប៉ុន្តែលោកមិនទាន់ឆ្លើយសំណួររបស់ខ្ញុំទេ សំណួរខ្ញុំថាតើ ឌី.ស៊ី.ខេម មានបញ្ជីឈ្មោះមនុស្សដែលត្រូវនាំខ្លួនមកផ្តន្ទាទោសដែរឬទេនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០នោះ?

**ឆ៖** ខ្ញុំគិតថា ដោយសារចំណងជើងរបស់លោក ហាក់ដូចជាទាញឲ្យនិយាយថា យកទៅកាត់ទោស ហើយបានខ្ញុំខំប្រាប់មកវិញថាវាមាន ប៉ុន្តែចំណងជើងវាអ៊ីចេះ។ តែលោកទាញទៅដដែលថាយើងមានឈ្មោះយកទៅកាត់ទោស។ ចំណងជើងបញ្ជីឈ្មោះមនុស្សទាំងអស់ហ្នឹង គឺមានន័យថា

“*បាយអ័រក្រាហ្វី អូហ្វ ឌឹ ខ្មែរ រូស្ស លីដឌ័រ*” មានមែន។ មានពិតប្រាកដ ខ្ញុំធ្លាប់មើល ធ្លាប់អាន និងធ្លាប់បញ្ចូលព័ត៌មាន។

**ស៖** ខ្ញុំយល់មិនច្រឡំ គឺយោងទៅឯកសារដែលបានរៀបចំដោយលោក ប៉ែន យៀវនិន ខ្ញុំសួរលោក ថាតើ ឌី.ស៊ី.ខេម ខ្លួនឯងផ្ទាល់នេះមានបញ្ជីសម្រាប់គោលបំណងផ្ទៃក្នុងរបស់ ឌី.ស៊ី.ខេម គឺបញ្ជីឈ្មោះមនុស្សដែល ឌី.ស៊ី.ខេម មានបំណងចង់ឲ្យទទួលនូវការចោទប្រកាន់ ឬកផ្តន្ទាទោសនោះ?

**ឆ៖** លោកចៅក្រម ខ្ញុំថាសំណួរដដែល។ ព្រោះលោក ប៉ែន យៀវនិន នៅក្នុងទសវត្សរ៍៩០ គាត់ជាប្រធាន ហើយបញ្ជីហ្នឹងមានមែន ហើយបោះផ្សាយទៀតផង។ ហើយខ្ញុំប្រាប់ទៀតថា យើងចេញបញ្ជីនោះ យើងបានប្រមូលបន្ថែមទៀតដាក់ថា ប្រវត្តិរូបមេដឹកនាំខ្មែរក្រហម។ ហើយគាត់ចេះតែចង់ទាញថា យកទៅកាន់ទោស ទៅកាន់ទោសទាល់តែតុលាការ។ តុលាការ ហើយខ្ញុំបានជូនទៅតុលាការ អ៊ីចឹងតុលាការមើលខ្លួនឯងទៅ ថាតើអ្នកណាមួយ សំណេរទាំងអស់នេះ គួរយកមកកាត់ទោស ក៏កាត់ទោសទៅតាមផ្លូវច្បាប់ទៅ។

[១៥:២៨:៤២]

អ៊ីចឹងសំណួរវាដដែល លោក ប៉ែន យៀវនិន ឌី.ស៊ី.ខេម យ៉ាងម៉េច? បើគាត់ប្រធានកាលឆ្នាំ៩៥-៩៦។ ខ្ញុំធ្វើប្រធានឆ្នាំ៩៧។ ៩៥-៩៦ យើងមានបញ្ជីហ្នឹងបោះផ្សាយជាសាធារណៈនៅក្នុងសៀវភៅដែលមានចំណងជើងថា “*ដេណូសាយ អ៊ីន ខេមបូឌា*” ទំព័រ១៣ ទំព័រ១៤។

ក្រោយមកទៀត ចេញពីបញ្ជីនេះ ខ្ញុំក៏អានឯកសារបន្ថែមទៀត ព្រោះនៅក្នុងហ្នឹងមានតែឈ្មោះ ហើយយើងបានបង្កើតជាហ្វូលឌ័រ អ៊ីចឹងមួយដែរ ដើម្បីស្វែងយល់ថាតើបុគ្គលនោះជាអ្នកណាខ្លះ ហើយមានលើសពី២០, ៣០នាក់ ឯណោះ។ ហើយយើងឲ្យឈ្មោះថា ប្រវត្តិរូបមេដឹកនាំខ្មែរក្រហម។ យើងមានអ៊ីចឹងមែន លោកចៅក្រម។

[១៥:២៩:២៤]

**ប្រធានអង្គជំនុំ៖**

ឆ្លើយតបរួចហើយ ហើយបើមិនច្បាស់ទេទៅរកបច្ចេកទេសសំណួរ ដែលសួរមានខ្លឹមសារផ្សេងពីនេះ ដើម្បីឲ្យដែលមានមូលដ្ឋានគ្រប់គ្រាន់នៅក្នុងការតាំងសំណួរ។ តាមធម្មតាតាំងសំណួរយើងមានមូលដ្ឋានគ្រប់គ្រាន់ហើយ ហើយតាំងសំណួរយ៉ាងណាគឺឲ្យចេញទៅតាមបំណងដែលខ្លួនឯងមានមូលដ្ឋាន។ ឥឡូវចម្លើយនេះ គឺគេបានឆ្លើយរួចហើយ។ ប្រសិនបើមានការពាក់ព័ន្ធផ្សេងទៀត ក្រៅពីនេះ

គឺលោកមេធាវីគប្បីប្រើប្រាស់បច្ចេកទេស ដើម្បីតាំងសំណួរផ្សេង ដើម្បីឲ្យផ្អែកលើមូលដ្ឋាន ឬប្រភពព័ត៌មានដែលខ្លួនមាន ដើម្បីឲ្យបានការឆ្លើយតបជាក់ច្បាស់ពីគោលដៅនៃការសួរ។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់អំពីប្រសាសន៍របស់លោកហើយ។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** ខ្ញុំសូមបន្តទៅបង្ហាញអំពីទំព័រ២៨ នៃឯកសារដដែលនេះ ដែលនិយាយអំពីអ៊ីម៉ែល ដែលយើងអាចមើលឃើញទេ។ តើបានបង្ហាញជូនសាក្សីមើលលើអេក្រង់ទេ គឺជាអ៊ីម៉ែលដែលឆ្លើយឆ្លងរវាងទៅនឹងអ្នកដទៃទៀត។ លោកអាចចាំទេ អ្នកដែលលោកឆ្លើយឆ្លងទៅជាមួយនឹង តើលោកស្រីជាអ្នកណា?

[១៥:៣១:០០]

**លោក ឆាំង យុ៖**

**ឆ៖** អាន់ណេត គឺគាត់ជាអ្នកសារព័ត៌មាននៅកាសែតភ្នំពេញប៉ុស្តិ៍។ ខ្ញុំផ្ញើអត្ថបទនេះទៅលោកស្ទីវ ហេដឌ័រ, លោក ក្រេក អេតឆេសាន់ ហើយនិង អាន់ណេត។

**ស៖** សូមអរគុណ។ អ៊ីចឹងយើងចូលទៅទំព័រ២៩ ដែលជាគឺជាអ៊ីម៉ែលដដែល។ យើងមើលទៅក្នុងប្រអប់ហ្នឹង នៅក្នុងកំណត់ចំណាំ ឬក៏សេចក្តីបន្ថែមរបស់លោក គឺខ្ញុំហាក់បីដូចជាមានអារម្មណ៍មានវិវេកភាពក្នុងការនិយាយទៅនឹងឈ្មោះណាម្នាក់ ទៅបង្ហាញឈ្មោះណាម្នាក់ទៅនឹង អាន់ណេត នោះ។ តើលោកចង់និយាយថាម៉េច នៅពេលប្រើលោកថា កំណត់ឈ្មោះមនុស្សដូច្នេះ?

[១៥:៣១:៥១]

**ឆ៖** ពីព្រោះជាទូទៅអ្នកសារព័ត៌មានសួរខ្ញុំ ថាអ្នកណាខ្លះ? ហើយខ្ញុំមិនចូលចិត្តនិយាយឈ្មោះគេទេ ហើយខ្ញុំទទួលរងសម្ពាធនេះ ដោយសារថាខ្ញុំនៅទីក្រុងភ្នំពេញ ប្រធានរបស់ខ្ញុំលោក ប៉ែន យៀវនិន កាលពេលនោះនៅសាកលវិទ្យាល័យ។ អ៊ីចឹងហើយជាទូទៅ ខ្ញុំតែងចម្លងជូនអ្នកដែលខ្ញុំបាននិយាយ។ នៅក្នុងកន្លែងនេះ ខ្ញុំអ៊ំ អាន់ណេត ប្រហែលជាសួរខ្ញុំអំពីមនុស្សផ្សេងទៀតនៅក្នុងសម័យខ្មែរក្រហម ខ្ញុំឃើញមានដូចជាលោកឈ្មោះលោក ជួន ប្រាសិទ្ធ, សួង ស៊ីគឿន បាទ អ្នកផ្សេងៗទៀត។ ហើយខ្ញុំប្រាប់ទៅគាត់ថា ខ្ញុំមិនចូលចិត្តនិយាយឈ្មោះអ្នកដទៃទេ ហើយខ្ញុំគិតថា ឌី.ស៊ី.ខេម ហ្នឹងមិនគួរធ្វើអ៊ីចឹងទេ។

[១៥:៣២:៣២]

ហើយខ្ញុំបាននិយាយទៀតនៅខាងក្រោម បើសិនជាលោកអនុញ្ញាត។ ខ្ញុំបាននិយាយថា មើលទៅគួរឲ្យចង់សើចណាស់ ឲ្យ ក្រេក ទៅចូលរួមក្នុងបញ្ហានេះ ពីព្រោះវាតម្រូវឲ្យអានឯកសារខ្មែរក្រហមឲ្យច្រើន ហើយ ក្រេក នេះមិនចេះភាសាខ្មែរទេ ចេះតែពីរបីម៉ាត់។

**ស៖** ខ្ញុំបានអានចំណុចខាងក្រោម ខ្ញុំគិតថា វាជាការអស់សំណើចដែរ។ ក៏ប៉ុន្តែចំណុចមួយទៀត ដែលលោកបាននិយាយថា ឌី.ស៊ី.ខេម មិនគួរប្រាប់ឈ្មោះបុគ្គលណាមួយនោះទេ លើកលែងតែគម្រោងរបស់យើងនោះបានចាប់ផ្តើម។ អ៊ីចឹងគម្រោងច្បាប់ដែលថា បានចាប់ផ្តើមនោះ គឺជាគម្រោងអ្វីដែរ?

[១៥:៣៣:១៨]

**លោក អាប់ឌុលឡាក់ ចារីក៖**

លោកប្រធាន ខ្ញុំសូមជំទាស់សាជាថ្មី មេធាវីការពារក្តីហ្នឹង គឺត្រូវចាកចេញពីប្រធានបទទៀតហើយ។ គឺសំណួររបស់យើង គឺពាក់ព័ន្ធទៅនឹងការទទួល ការវិភាគ និងការចាត់ថែងទៅលើឯកសារ។ អ្វីដែលមេធាវីការពារក្តីដូចពីមុនដែរ គឺគាត់ព្យាយាមយកវិធីសាស្ត្រធ្វើឯកសាររបស់ ឌី.ស៊ី.ខេម នេះយកមកធ្វើការវិនិច្ឆ័យនៅទីនេះ។ វាមិនពាក់ព័ន្ធទៅនឹងគោលបំណងនៃសវនាការរបស់យើងនៅក្នុងថ្ងៃនេះទេ។ អ្វីដែលយើងចោទសួរនៅទីនេះ គឺពាក់ព័ន្ធទៅនឹងភាពទុកចិត្ត ភាពពាក់ព័ន្ធនៃឯកសារដែលមាននៅក្នុងសំណុំរឿង។

[១៥:៣៤:០០]

ដូច្នេះហើយមេធាវីការពារក្តីអ្វីដែលគាត់អាចធ្វើបាននោះ គឺផលប៉ះពាល់ទៅភាពទុកចិត្តបានភាពពាក់ព័ន្ធនៃឯកសារ។ ដូច្នេះចំណុចទាំងអស់នោះ វាជាចំណុចសមរម្យ។

មេធាវីការពារក្តីគាត់មិនបានចោទប្រកាន់ថា ឯកសារនោះមានការក្លែងបន្លំ ឬក្លែងក្លាយនោះទេ ក៏ប៉ុន្តែសំណួររបស់គាត់ ខ្ញុំសង្កេតឃើញថាមិនពាក់ព័ន្ធ។

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបដោយសង្ខេប។ គឺយើងលើកឡើងម្តងហើយម្តងទៀត ដដែលៗ សារការបង្គាប់របស់អង្គជំនុំជម្រះ គឺច្បាស់លាស់ហើយ គឺអនុញ្ញាតឲ្យមានការតាំងសំណួរបែបនេះ។ គឺខ្ញុំចង់អានប្រតិចារឹកដែរ តែខ្ញុំមិនអាចធ្វើទៅបាន។

សហព្រះរាជអាជ្ញាគាត់លើកឡើងចំណុចដែលថាមិនពាក់ព័ន្ធ ក៏ប៉ុន្តែគាត់មិនបានបញ្ជាក់ថាសំណួររបស់ខ្ញុំ សួរអំពីការប្រមូលឯកសារ។ ការប្រមូលឯកសារគឺវាពាក់ព័ន្ធទៅនឹងការពិភាក្សា ពាក់ព័ន្ធទៅនឹងវិធីនៃឯកសារដែលយើងប្រមូល ដូច្នេះវាពាក់ព័ន្ធ។

ដូច្នេះហើយយើងចង់ដឹងឥរិយាបថ និងវិធីសាស្ត្ររបស់ ឌី.ស៊ី.ខេម គឺវា គាត់ធ្វើយ៉ាងម៉េចដែរទៅនឹងចំណុចហ្នឹង? ដូច្នេះហើយខ្ញុំចង់សួរថា តើគម្រោងច្បាប់នោះគឺជាគម្រោងច្បាប់អ្វីដែរ ដែលគេលើកឡើងនៅទីនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយ។

[១៥:៣៥:១៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៩:១៥]

**ប្រធានអង្គជំនុំ៖**

ការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិមានប្រសិទ្ធភាព។ ដូច្នេះសាក្សីមិនចាំបាច់ឆ្លើយទៅនឹងសំណួរចុងក្រោយរបស់មេធាវីការពារក្តីទេ ហើយអង្គជំនុំជម្រះសូមជម្រាបថា មេធាវីគប្បីប្រើប្រាស់នូវសំណួរផ្សេងទៀត។ ហើយសំណួរប្រភេទបែបនេះគប្បីបញ្ចប់ត្រឹមនេះទៅ ហើយបញ្ហាដែលលើកឡើងស្រដៀងៗគ្នានូវការចង្អុលបង្ហាញពាក់ព័ន្ធនឹងឯកសារ ការចង្អុលបង្ហាញអម្បាញ់មិញនេះឃើញថាច្រើនចំណុចហើយ។ ហើយអង្គជំនុំជម្រះបានស្តាប់បាននូវគោលបំណង នូវការបង្ហាញហេតុផលទាំងនេះហើយ។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបន្តទៅមុខ ក៏ប៉ុន្តែខ្ញុំផ្តោតទៅលើឯកសារដដែល ខ្ញុំសូមចូលទៅដល់ទំព័រ៣៥ បាទ សូមឲ្យបញ្ចាំង។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** លោក ឆាំង យុ នេះហាក់ដូចជាអ៊ីម៉ែលពី ស្ទីវ ហេដឌ័រ ដែលផ្ញើជូនទៅលោកគឺ ឆាំង យុ ហើយបុគ្គលដទៃៗទៀត គឺជនមួយចំនួន ដែលយើងស្គាល់ហើយគឺ ដេវីដ ឆេនដ័ល័រ, ក្រេក អេតឆេ-សាន់ ហេឡែន ចាវីស។ លោកបានលើកឡើងហើយថា លោកស្ទាក់ស្ទើរក្នុងការអានជាភាសាអង់គ្លេស

ដូច្នេះហើយ ខ្ញុំសូមអានកថាខណ្ឌនេះជូនលោក ស្ទីវ ហេដឌ័រ បានសរសេរថា “ខ្ញុំជឿថា វាការខុសសម្រាប់ ឌី.ស៊ី.ខេម ដែលគាត់ចូលរួមពាក់ព័ន្ធទៅនឹងការព្យាយាមកំណត់និយមន័យ និងធ្វើការវិនិច្ឆ័យទៅលើការចោទប្រកាន់ គឺការធ្វើនេះ គឺដើម្បីធ្វើការស្វែងរកការពិត គ្មានអ្វីក្រៅពីស្វែងរកការពិត។ ដូច្នេះហើយវាហាក់ដូចជាជំរុញឲ្យ ឌី.ស៊ី.ខេម ចូលរួមទៅនឹងរបៀបវារៈមួយ។” ដូច្នេះថាតើមានន័យយ៉ាងម៉េចនៅពេលដែល ឌី.ស៊ី.ខេម គាត់និយាយថា ខ្ញុំជឿថា វាខុសសម្រាប់ ឌី.ស៊ី.ខេម ក្នុងការចូលរួមកំណត់និយមន័យ និងវិសាលភាពនៃការចោទប្រកាន់? ដូច្នេះ ត្រង់ចំណុចនេះ តើវាមានន័យយ៉ាងម៉េច? សូមឲ្យលោកជួយពន្យល់។

[១៥:៤៦:០៧]

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោក លោកស្រីក្រុម គឺខ្ញុំសូមជំទាស់ទៅលើចំណុចនេះដោយសារតែវាមិនពាក់ព័ន្ធ។

**លោក ហ្សាស្តើ ប៉ោ៖**

លោកប្រធាន បើសិនជាខ្ញុំអាចឆ្លើយតបអ៊ីម៉ែលនេះ គឺវាពាក់ព័ន្ធទៅនឹងការជ្រៀតជ្រែកពីខាងក្រៅចូល ឌី.ស៊ី.ខេម ដូចដែលភាគីបាននិយាយកាលពីម្សិលមិញ ដែលថាវាមានការជ្រៀតជ្រែកពីខាងក្រៅចូលក្នុងការងាររបស់ ឌី.ស៊ី.ខេម ហើយអង្គជំនុំជម្រះ លើកឡើងថា វាមិនពាក់ព័ន្ធ។ អ៊ីម៉ែលនេះនៅពេលដែលយើងមើលបន្តទៀតទៅ ព្រោះវាបង្ហាញអំពីសម្ពាធពីខាងក្រៅមកលើ ឌី.ស៊ី.ខេម។ ដោយសារតែអង្គជំនុំជម្រះបានអនុញ្ញាតឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សួរសំណួរហ្នឹង ដូច្នេះហើយគួរតែឲ្យមេធាវីការពារក្តីសួរផងដែរ។ យើងគ្រាន់តែសួរថាតើមានការគាបសង្កត់ជ្រៀតជ្រែកពីខាងក្រៅដែរឬទេ ទៅលើ ឌី.ស៊ី.ខេម ដើម្បីឲ្យលោក ឆាំង យុ នេះជួយធ្វើការស្រាយបំភ្លឺទៅលើចំណុចហ្នឹង។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៣:៤៧]

**ប្រធានអង្គជំនុំ៖**

បាទជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ មានប្រសិទ្ធភាព ហើយលោកមេធាវីមិនគប្បីយកអត្ថបទអ្នកដទៃ ហើយមកឲ្យសាក្សីធ្វើការបញ្ជាក់នោះឡើយ មិនមែនជាអត្ថបទរបស់សាក្សីរូបនេះទេ។

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** ថ្មីៗនេះលោក ឆាំង យុ ខ្ញុំបានអានឯកសារមួយ ដែលវាហាក់ដូចបង្ហាញថា ឌី.ស៊ី.ខេម នៅក្នុងទសវត្សរ៍ចុងឆ្នាំ៩០ គឺបានចូលរួមនៅក្នុងគម្រោងមួយចំនួន ដែលគម្រោងនោះកំណត់កម្រិតទៅលើការចោទប្រកាន់ មេ មន្ត្រីកម្មាភិបាលជាន់ទាបរបស់កម្ពុជាប្រជាធិបតេយ្យ។ ឯកសារនេះគឺខ្ញុំចង់បង្ហាញជូនលោក ដូច្នេះខ្ញុំបើសិនមិនជំទាស់ទេ ខ្ញុំសូមសួរលោកថាតើ ឌី.ស៊ី.ខេម មានបានចូលរួមក្នុងការកំណត់យុត្តាធិការបុគ្គលនៃសាលាក្តី ដែលនឹងធ្វើការជំនុំជម្រះធ្វើការកាត់ទោស ទៅលើកម្មា-ភិបាលកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមគោរពលោកចៅក្រម គឺខ្ញុំសូមជំទាស់ទៅលើការសួរសំណួរនេះ។ សំណួរនេះ គឺមិនពាក់ព័ន្ធទៅនឹងប្រធានបទ ដែលយើងដេញដោលនៅក្នុងថ្ងៃនេះទេ។ ប្រធានបទរបស់យើងគឺពាក់ព័ន្ធទៅនឹង ឌី.ស៊ី.ខេម និងការប្រមូលឯកសារ និងជំហររបស់ ឌី.ស៊ី.ខេម ហើយការសួរថា កាត់ទោស កំណត់ការកាត់ទោសទៅលើបុគ្គលណានោះ វាជាចំណុចមួយគួរឲ្យចាប់អារម្មណ៍ ប៉ុន្តែមិនពាក់ព័ន្ធនៅក្នុងចំណុចនេះទេ។

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំសូមធ្វើការឆ្លើយតប ខ្ញុំហាក់ដូចជាទើបតែដឹងថា សហព្រះរាជអាជ្ញាគឺកំពុងតែមានភាពឆ្ងល់ទៅនឹងម្ចាស់ អ្នកដែលផ្តល់ឯកសារទៅឲ្យ ឌី.ស៊ី.ខេម យើងបានចង់លើកឡើងបញ្ជាក់ដោយសារតែ ឌី.ស៊ី.ខេម បញ្ជាក់ថា គាត់មិនលម្អៀង។ ដូច្នេះហើយទើបយើងចង់បញ្ជាក់សួរឲ្យបានច្បាស់លាស់ថា គាត់មិនលម្អៀង ឬក៏យ៉ាងណា? ប្រសិនបើយើងចង់ពិចារណាទៅលើភាពទុកចិត្តបាននៃឯកសារ ភាពពាក់ព័ន្ធនៃឯកសារ និងភស្តុតាងនៅក្នុងសំណុំរឿង យើងត្រូវតែដឹងអំពីឯកសារផ្សេងទៀតនឹងត្រូវតែស៊ើបសួរ ស៊ើបអង្កេតផ្សេងទៀតដើម្បីឲ្យយើងអាចដឹង។ ដូច្នេះទាំងអស់នេះគឺជាសំណុំឯកសារដែលប្រមូលបាន នៅពេលដែលប្រមូលបាន គឺគេប្រាកដជាធ្វើសេចក្តីសម្រេចជាក់លាក់ វាដូចទៅនឹងករណីមិនប្រមូលឯកសារមួយចំនួនផងដែរ។ ដូច្នេះយើងត្រូវដឹងអំពីចិត្តគំនិតថា តើគេសម្រេចយ៉ាងម៉េចក្នុងការប្រមូលឯកសារ។ ដូច្នេះមេធាវីការពារក្តីចង់បង្ហាញថាតើ ឌី.ស៊ី.ខេម នោះមានរបៀបវារៈ ឬក៏

មាគ៌ារបស់ខ្លួនយ៉ាងម៉េច? ឌី.ស៊ី.ខេម បានចូលរួមនៅក្នុងសកម្មភាពមួយចំនួន តាមរយៈអ៊ីម៉ែលនេះគឺមានការពិភាក្សា អំពីកម្មវត្ថុយុត្តាធិការបុគ្គលនៃសាលាក្តីនេះ។ មានបុគ្គលពីខាងក្រៅបានផ្តល់យោបល់ទៅលើចំណុចហ្នឹង។ ស្ទីវ ហេដឌ័រ គាត់ដឹងការងារ ឌី.ស៊ី.ខេម យ៉ាងច្បាស់លាស់។

ដូច្នេះហើយខ្ញុំមិនដាក់ឯកសារនេះ នៅចំពោះមុខអង្គជំនុំជម្រះនោះទេ ដោយសារតែអង្គជំនុំជម្រះសម្រេចរួចហើយ ក៏ប៉ុន្តែចំណុចនេះវាសំខាន់ចាប់អារម្មណ៍ដែលយើងត្រូវដឹង ហេតុអ្វីបានជាលោក ស្ទីវ ហេដឌ័រ បានលើកឡើងទៅលើមតិយោបល់ដូច្នេះ។ ដូច្នេះហើយខ្ញុំគ្រាន់តែចង់ឲ្យលោក ឆាំង យុ ផ្តល់ជាចម្លើយតែប៉ុណ្ណោះ។ ជាថ្មីម្តងទៀត ខ្ញុំចង់ដឹង ខ្ញុំចង់សួរថាតើ ឌី.ស៊ី.ខេម មានបានចូលរួមក្នុងការកំណត់យុត្តាធិការបុគ្គលរបស់សាលាក្តីនេះដែរឬទេ? ជាពិសេសយុត្តាធិការក្នុងការចោទប្រកាន់ទៅលើកម្មាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះហើយខ្ញុំសូមអនុញ្ញាតពីលោកប្រធាន សាកសួរសំណួរនេះ។

[១៥:៤៨:១៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់ឆ្លើយនឹងសំណួរនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៩:៣៦]

**ប្រធានអង្គជំនុំ៖**

ជំទាស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះការតាំងសំណួរចុងក្រោយអម្បាញ់មិញនេះរបស់មេធាវីការពារក្តី គឺមានប្រសិទ្ធភាព។ ដូច្នេះសាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរអម្បាញ់មិញនេះទេ។ ហើយដើម្បីបញ្ជាក់បន្ថែមឲ្យកាន់តែច្បាស់លាស់ថែមទៀត លើកិច្ចដំណើរការទៅមុខទៀត។ អង្គជំនុំជម្រះសូមផ្តល់-- ប្រគល់ភារកិច្ចជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីឆ្លើយបំភ្លឺបញ្ជាក់ទៅនឹងខាងមេធាវីការពារក្តីលោក នួន ជា។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោកមេធាវីការពារក្តីលោក នួន ជា ហេតុផលដែលការជំទាស់របស់សហព្រះរាជអាជ្ញាមានប្រសិទ្ធភាពនោះ គឺថាអង្គជំនុំជម្រះយល់អំពីហេតុផលដែលលោកចង់ចោទ

សំណួរនៅក្នុងនេះ។ អង្គជំនុំជម្រះមានភាពសង្ស័យអំពីទឹកចិត្តជំរុញរបស់ ឌី.ស៊ី.ខេម និងរបៀបដែល ឌី.ស៊ី.ខេម ប្រមូលឯកសារ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះគិតថា ការសួរទៅលើប្រធានបទហ្នឹង គឺគ្រប់គ្រាន់រួចហើយ។ ដូច្នេះហើយ ស្នើសុំឲ្យលោកចូលទៅដល់វិធានបទផ្សេងនៃការតាំងសំណួររបស់លោក។ ចំណុចដែលសំខាន់ជាសារវន្តនោះ គឺសាក្សីមិនអាចផ្តល់ជាយោបល់ទៅលើចិត្តគំនិតអ្នកដែលសរសេរមកកាន់គាត់នោះឡើយ។

[១៥:៥១:៣៤]

ដូច្នេះហើយ មិនអាចសុំឲ្យសាក្សីព្យាករណ៍ទស្សន៍ទាយទៅលើចំណុចហ្នឹងទេ។ ខ្ញុំគិតថា ខ្ញុំបញ្ជាក់ច្បាស់លាស់ជូនលោកហើយ ដូច្នេះហើយអង្គជំនុំជម្រះចង់ឲ្យលោកបន្តសួរសំណួររបស់លោកត្រង់ចំណុចផ្សេងទៀត។ សូមឲ្យលោកយល់ទៅលើចំណុចនេះ។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយថ៍។ ខ្ញុំយល់អំពីសេចក្តីបង្គាប់របស់លោកស្រី និងអង្គជំនុំជម្រះ។ ដូច្នេះហើយ ខ្ញុំបានបង្គាប់ឲ្យទុកការសារសួរសំណួររបស់ខ្ញុំត្រឹមនេះ ខ្ញុំមានការភ្ញាក់ផ្អើលដែរ ដោយសារតែសំណួររបស់ខ្ញុំពាក់ព័ន្ធទៅនឹងចំណុចនេះ ហើយគ្មានចម្លើយឆ្លើតបទៅនឹងសំណួររបស់ខ្ញុំ។ ខ្ញុំរក្សាសិទ្ធិសួរសំណួរនេះទៀត ទៅតាមសំណើររបស់ខ្ញុំ។ នៅពេលនេះ គឺខ្ញុំសូមបន្ត--

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សុំមួយភ្លែតលោកប្រធាន ធ្វើការពិភាក្សាគ្នាទៅលើបញ្ហានីតិវិធីជាមុនសិន។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥៣:១៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីអង្គុយចុះ!

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ វាសមល្មមនឹងត្រូវសម្រាកហើយ ប៉ុន្តែមុននឹងសម្រាកអង្គជំនុំជម្រះសូមសម្រេចបញ្ហាមួយ ដែលពាក់ព័ន្ធទៅនឹងមេធាវី នួន ជា ដែរ។ អ៊ីចឹង សូមអញ្ជើញលោកមេធាវី ផេសមិន ដែលជាមេធាវីអន្តរជាតិការពារក្តីឲ្យ នួន ជា អញ្ជើញក្រោកឈរ!

សេចក្តីសម្រេចលើការជំទាស់របស់មេធាវីការពារក្តី-- មេធាវីអន្តរជាតិការពារក្តី នួន ជា ទាក់ទិនទៅនឹងការអត្ថាធិប្បាយសាធារណៈអំពីអត្ថិភាពនៃពិរុទ្ធភាពលើកូនក្តីរបស់ខ្លួន។

អង្គជំនុំជម្រះបានកត់សម្គាល់នូវការជំទាស់របស់មេធាវីការពារក្តី ទៅនឹងសេចក្តីអត្ថាធិប្បាយជាសាធារណៈតាមអត្ថបទសារព័ត៌មាន ដោយបានចោទប្រកាន់ នួន ជា កូនក្តីរបស់ខ្លួន ថាមានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មដែលជនជាប់ចោទរូបនេះ កំពុងត្រូវបានជំនុំជម្រះ។

អង្គជំនុំជម្រះសាលាដំបូង សូមបញ្ជាក់ថាតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា ជនជាប់ចោទក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ ដូច្នេះ ការកំណត់អំពីអត្ថិភាព ឬ នត្ថិភាពនៃពិរុទ្ធភាពរបស់ជនជាប់ចោទណាម្នាក់ គឺជាភារកិច្ចរបស់អង្គជំនុំជម្រះដែលត្រូវសម្រេច-- ដែលនឹងត្រូវសម្រេចនៅពេលបញ្ចប់សវនាការ ដោយផ្អែកលើកិច្ចពិភាក្សាដេញដោលលើអង្គហេតុ និងភស្តុតាងនានា ដែលត្រូវបានបង្ហាញនៅក្នុងសវនាការ និងផ្អែកតាមច្បាប់ជាធរមាន ដែលអនុវត្តនៅ អ.វ.ត.ក ប៉ុណ្ណោះ។

[១៥:៥៥:១១]

ដូច្នេះ អង្គជំនុំជម្រះមិនយកសេចក្តីអត្ថាធិប្បាយសាធារណៈណាមួយ ពាក់ព័ន្ធនឹងអត្ថិភាព ឬនត្ថិភាពនៃពិរុទ្ធភាពរបស់ជនជាប់ចោទណាម្នាក់មកពិចារណានៅពេលខ្លួន ពិចារណាចេញសាលក្រមនោះឡើយ។

មេធាវីអាចអង្គុយចុះបាន!

បាទ ឥឡូវនេះ ពេលវេលាសមល្មមនឹងសម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ កិច្ចដំណើរការសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី៦ ខែកុម្ភៈ ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយអរគុណលោក ឆាំង យុ ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការ-- និងពេលវេលា ក្នុងការអញ្ជើញមកផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះ។ ប៉ុន្តែដោយសារបញ្ហាពាក់ព័ន្ធទៅនឹង ស៊ី.ឌី.ខេម ទៅនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ជាបញ្ហាធំ ហើយច្រើនមិនទាន់អាចបញ្ចប់នូវកិច្ចដំណើរសវនាការបានទេ។ អ៊ីចឹង អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទ សប្តាហ៍ក្រោយ ចាប់ពីម៉ោងប្រាំបួនព្រឹក ហើយទំនងតែជាមួយថ្ងៃទៀតទេនឹងចប់ហើយ។

[១៥:៥៦:៣៥]

ហើយមន្ត្រីតុលាការ សូមជួយសម្របសម្រួលនូវការធ្វើដំណើរវិលត្រឡប់របស់សាក្សីរូបនេះផង។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនឹងឲ្យនាំខ្លួនពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃចន្ទ ទី៦ ខែកុម្ភៈ ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៧ នាទី)*